ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ គម្រប់ខួប ១០០ ព្រះវស្សា សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ
ទស្សនាធាននៃពិព័រណ៍៖ "ក្តីសុបិនកម្ពុជា"

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧៤ ខែតុលា ឆ្នាំ២០២២

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧៤ ខែតុលា ឆ្នាំ២០២២



សម្ដេចព្រះ នរោត្ដម សីហនុ ព្រះបរមរតនកោដ្ឋ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាតិកា

## សំបុត្រ

◆ គម្រប់ខួប ១០០ ព្រះវស្សា សម្ដេចព្រះនរោត្ដម សីហនុ ព្រះបរមរតនកោដ្ឋទស្សនាទាននៃពិព័រណ៌៖ "ក្ដីសុបិនកម្ពុជា"..................១
◆ លោកស្រី ម៉ា ទីន ហ្សាកាំង មេធាវីតំណាង... ៥

## ផ្នែកឯកសារ

◆ ចាប ណម ៖ ប្រធានមន្ទីរសន្ដិសុខ..........៧

## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ឡឿន គីមសាន ៖ អតីតប្រធានក្រុម ........ ១០
◆ មួយទសវត្សរ៍ធ្វើទាហានបីរបប.......... ១២
◆ ស្លេះ ហានីហ្វះ ៖ គ្រួសារខ្ញុំគឺជាអ្នកតម្បាញ..១៤
◆ រស់ សៀត ៖ អតីតយុទ្ធនារីខ្មែរក្រហម ... ១៦
◆ សេង សឿ ៖ បង្រៀននយោបាយ ......... ១៨
◆ ផន ភឿន ៖ កងចល័តជីកប្រឡាយ ....... ២០
◆ មាស ផាត ៖ កម្មករស្រែអំបិលកែប..... ២២
◆ រស់ ទូច ៖ អតីតប្រធានក្រសួងវប្បធម៌.. ២៤
◆ ហ៊ុន សាន ៖ ឪពុកខ្ញុំកាន់សីល៨.......... ២៦
◆ អ៊ុក ឡាន ៖ កូនខ្ញុំធ្លាក់ទឹកប្រឡាយ....... ២៨
◆ ប្រជាជនភូមិសំរោងវត្តហូបចុកគ្រប់ ...... ៣០
◆ អួន អាត ៖ កាន់ម៉ាស៊ីនបូមទឹកដាក់ស្រែ ...៣២
◆ តក់ តុប ៖ ពិការជើងដោយសារជាន់មីន..៣៤
◆ ស៊ិន ហឿង ៖ អតីតកងចល័តនៅស្រុក... ៣៦
◆ ខ្នាំងរបស់អង្គការ ........................ ៣៨
◆ កុយ សុខ ៖ កងនេសាទត្រី ................ ៤០
◆ គីម ចយ ៖ យោធាក្នុងភូមិភាគពិសេស.. ៤២
◆ គុយ អឹម ៖ កងទ័ពនារី ........................៤៤
◆ ញៀនរីន ៖ កងចល័តស្រុក............... ៤៦
◆ រឿង ផែន ៖ យោធា....................... ៤៧
◆ សំ មឿន ៖ អ្នកធ្វើក្បឿង................... ៤៩

## ផ្នែក វេទិកាពិភាក្សាសាធារណៈ

◆ ក្រុមការងាររថតខ្សែភាពយន្តឯកសារនៃក្រសួងព័ត៌មានទស្សនកិច្ចមជ្ឈមណ្ឌល ...........៥២

## ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ «ទួលពិឃាដ» (ត) ........................៥៤

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដា៉រដ្ឋ មេត្តា, អេង វណ្ណីកា, ផេង ពង្ស៉ាស៊ី, មីន សាណាស់, ភា រស្មី, គាត ស្រីឡែន, សូ ហាន់, រីម ស្រីស្រស់, ថុន ស្រីពេជ្រ, សៀង កញ្ញា, ភួង សុខថា, យន់ ឃីម, សួត វិចិត្រ, មេក វិន, ហ៊ាន ពិសី, ឈុំ រ៉ា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាក ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# គម្រប់ខួប ១០០ ព្រះវស្សា

## សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ទស្សនាធាននៃពិព័រណ៍៖ "ក្តីសុបិនកម្ពុជា"

**ឆាំង យុ**



*ពិព័រណ៍៖ "ក្តីសុបិនកម្ពុជា" ព្រះរាជសកម្មភាព និងស្នាព្រះហស្តរបស់ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

បណ្ណាល័យសម្តេចម៉ែនៃវិទ្យាស្ថានស្លឹករឹត ដែលបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា មានកិត្តិយសសូមធ្វើការរំឭកគម្រប់ខួបមួយរយព្រះវស្សា (១៩២២-២០២២) របស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គបានបូជាអស់ព្រះកម្លាំងកាយចិត្តក្នុងអំឡុងពេលដែលព្រះអង្គគង់នៅមានព្រះជន្ម ដើម្បីសម្រេចនូវក្តីសុបិនកម្ពុជា។

ក្តីសុបិនកម្ពុជា គឺមិនមែនជាកម្មសិទ្ធិបុការបង្កើតឡើងរបស់បុគ្គលណាម្នាក់នោះទេ ប៉ុន្តែផ្ទុយទៅវិញនេះគឺជាក្តីសង្ឃឹម ការបួងសួង និងចក្ខុវិស័យដ៏ថ្លៃថ្លារួមគ្នារបស់ប្រជាជនកម្ពុជា ដែលបានបង្កើតដួងព្រលឹងជាតិនាអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។ ក្នុងនាមជាអ្នកតំណាង និងជាអ្នកមើលថែរក្សាប្រជាជាតិកម្ពុជា ព្រះរាជវង្សានុវង្សបានអមដំណើរប្រជាជនកម្ពុជាក្នុងដំណើរឆ្ពោះទៅកាន់ក្តីសុបិនដែលបន្តចម្រើនទៅមុខនេះ។

បណ្ណាល័យ សម្តេចម៉ែ មានកិត្តិយសសូមរំឭកអំពីដំណើរនេះ តាមរយៈពិព័រណ៍រូបថត ពីព្រោះថាអនាគតរបស់កម្ពុជា គឺមិនត្រឹមតែពឹងផ្អែកទៅលើការបន្តជំនឿទៅលើក្តីសុបិនកម្ពុជាប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ពឹងផ្អែកទៅលើការយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់មនុស្សជំនាន់មុនដែលពលីជីវិតរបស់ខ្លួនដើម្បីសម្រេចក្តីសុបិន ។



ពិព័រណ៍៖ “ក្តីសុបិនកម្ពុជា” ព្រះរាជសកម្មភាព និងស្នាព្រះហស្ត សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ពិព័រណ៍៖ “ក្តីសុបិនកម្ពុជា” ព្រះរាជសកម្មភាព និងស្នាព្រះហស្ត សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ពិព័រណ៍៖ “ក្តីសុបិនកម្ពុជា” ព្រះរាជសកម្មភាព និងស្នាព្រះហស្ត សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ពិព័រណ៌៖ “ក្តីសុបិនកម្ពុជា” ព្រះរាជសកម្មភាព និងស្នាព្រះហស្ត របស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំពិព័រណ៍៖ “ក្តីសុបិនកម្ពុជា”។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកសារ និងចម្រៀង ដែលជាស្នាព្រះហស្តព្រះរាជនិពន្ធរបស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នរោត្តម កែវ រស្មី ប៉ូនីតា យាងទត ពិព័រណ៍៖ “ក្តីសុបិនកម្ពុជា” ដែលរៀបចំដោយបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# លោកស្រី ម៉ាទីន ហ្សាកាំង មេធាវីតំណាង
## ដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បរិច្ចាគឯកសារចំនួន១៨០០ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា

ឆាំង យុ



*លោកស្រី ម៉ាទីន ហ្សាកាំង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បរិច្ចាគឯកសារចំនួន១៨០០ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃចន្ទ ទី១០ ខែតុលា ឆ្នាំ២០២២ លោកស្រី ម៉ាទីន ចាកឃ្វីន មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បរិច្ចាគឯកសារចំនួន១៨០០ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។

មជ្ឈមណ្ឌលឯកសារកម្ពុជា មានសេចក្តីសោមនស្សប្រកាសអំពីការបរិច្ចាគដ៏វិសេសវិសាលនូវឯកសារនៃដើមបណ្តឹងរដ្ឋប្បវេណី ចំនួន១៨០០ ដល់បណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកស្រី ម៉ាទីន ហ្សាកាំង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ បានធ្វើការបរិច្ចាគយ៉ាងសប្បុរសនូវឯកសារទាំងនេះ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជា រំពឹងយ៉ាងមុតមាំក្នុងការធ្វើការជាមួយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ, ជនរងគ្រោះ, សមាជិកគ្រួសារដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ដើម្បីសម្របសម្រួលដល់ការវិភាគ ការចែកផ្សាយជូនសាធារណជនលើឯកសារជាក់លាក់ និងការប្រើប្រាស់ទូលំទូលាយជាងនេះក្នុងការអប់រំ និងការ

ស្រាវជ្រាវ លើឯកសារប្រវត្តិសាស្ត្រដែលបង្កប់ព័ត៌មានដ៏វិសេសវិសាល ប៉ុន្តែមានសារប្រយោជន៍មហិមានេះ។

យុត្តិធម៌មិនគួរ ឬមិនអាចបញ្ចប់ទៅ នៅពេលដែលតុលាការចេញសេចក្តីវិនិច្ឆ័យទោសចុងក្រោយទេ។ ការសម្របសម្រួលដល់ការវិភាគនានា និងការផ្សព្វផ្សាយនូវព័ត៌មានជាក់លាក់ ក៏ដូចជាការប្រើប្រាស់បន្ថែមក្នុងគោលបំណងអប់រំ និងការចែកចាយឯកសារទាំងអស់នេះ សបញ្ជាក់អំពីជំហានឆ្ពោះទៅមុខបន្ទាប់ ដើម្បីធ្វើឲ្យកម្ពុជាឈានទៅសម្រេចបានយុត្តិធម៌ពិតប្រាកដសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម។ ចាប់តាំងពីឆ្នាំ១៩៩៥មកមជ្ឈមណ្ឌលឯកសារកម្ពុជា បានជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនក្នុងការដាក់ពាក្យបណ្តឹងនិងប្រមែប្រមូលចងក្រងសាច់រឿងនានា ដែលគាំពារដល់ការចងចាំជាសាធារណៈ ការអប់រំពីអំពើប្រល័យពូជសាសន៍ និងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ឬសាលាក្តីខ្មែរក្រហម)។ ការបរិច្ចាគឯកសារនេះ គឺជាសក្ខីភាពនៃជំហានឆ្ពោះទៅមុខបន្ទាប់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើនអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី, ជនរងគ្រោះ និងសមាជិកគ្រួសារដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីធានាថា យុត្តិធម៌មិនមែនបញ្ចប់ទៅនៅពេលដែលតុលាការខ្មែរក្រហមបិទបញ្ចប់ប្រតិបត្តិការរបស់ខ្លួនទេ។

ជាមួយនឹងការបរិច្ចាគដ៏វិសេសវិសាលរបស់លោកស្រី ម៉ាទីន ហ្សាកាំង មជ្ឈមណ្ឌលឯកសារកម្ពុជា រំពឹងយ៉ាងមុតមាំក្នុងការបំពេញបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ, ជនរងគ្រោះ ក៏ដូចជាសមាជិកគ្រួសារដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីធានាថា សាច់រឿងជីវិតរបស់បុគ្គលទាំងនេះ នឹងនៅតែបន្តចូលរួមនៅក្នុងការអប់រំមនុស្សជំនាន់ក្រោយ ព្រមទាំងចំពោះការសម្រេចបានយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ហើយដើរតួនាទីជាកេរដំណែលនៃច្បាប់អន្តរជាតិសម្រាប់សង្គមក្រោយជម្លោះនានា។



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត។
(តាំង ជិនសុធី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ចាប ណាម ៖ ប្រធានមន្ទីរសន្តិសុខ តំបន់៣២ ភូមិភាគបស្ចិម ៤០១

***ដារ៉ាវឌ្ឍ មេត្តា***



*កម្មាភិបាលខ្មែរក្រហមនៅមូលដ្ឋាន។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ចាប ណាម ភេទប្រុស អាយុ៣១ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧) មានស្រុកកំណើតនៅឃុំដើមរាំង (ស្រុកខទ្បុង) ខេត្តកំពង់ស្ពឺ។ នៅពេលខ្ញុំមានអាយុ១៧ឆ្នាំ ខ្ញុំបួសជាព្រះសង្ឃនៅក្នុងវត្តស្រះផុល ស្ថិតនៅក្នុងឃុំដើមរាំង។ នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំរៀននៅវត្តសុខារាម បាត់ដឹង។ នៅក្នុងឆ្នាំ១៩៦៧ អាចារ្យ ទេព សាអ៊ុម ចូលមកបង្រៀននៅក្នុងវត្តសុខារាម។ ទេព សាអ៊ុម គឺជាភ្នាក់ងារ សេ-អ៊ី-អា បានអប់រំខ្ញុំជាហូរហែរួមទាំងមនោគមវិជ្ជានាយទុនចក្រពត្តិ។ ទេព សាអ៊ុម នៅតែបន្តអប់រំខ្ញុំជាសម្ងាត់ ហើយក៏បានចាត់តាំងខ្ញុំជា សេ-អ៊ី-អា។ ភារកិច្ច ទេព សាអ៊ុម កំណត់ឲ្យយើងធ្វើ មានដូចជា បង្កប់ បំបែក បំបាក់ កសាងកម្លាំងក្នុងជួរបដិវត្តន៍។ ទេព សាអ៊ុម បានផ្តល់ប្រាក់ខបត្តម្ភឲ្យខ្ញុំចាយចំនួន១០០០រៀលក្នុងមួយខែ ហើយប្រាក់ខបត្តម្ភអាចឡើងជាបន្តបន្ទាប់នៅពេលធ្វើការងារបានសម្រេច។

នៅចុងឆ្នាំ១៩៦៧ អាចារ្យ ទេព សាអ៊ុម បានបែកទៅនៅកុដិសេះI វត្តស្រះចក ភ្នំពេញ។ ខ្ញុំក៏មកនៅវត្តទេពប្រណម្យ ប៉ុន្តែខ្ញុំនៅតែរក្សាទំនាក់ទំនងជាមួយអាចារ្យ ទេព សាអ៊ុម។ អាចារ្យ

ទេព សាអ៊ុម ខទេ្ទសនាម ខ្ញុំឲ្យស្គាល់ខ្មែរគាត់ធ្លាប់ទាក់ទងកាលពីមុននៅវត្តស្រះចក ភ្នំពេញ គឺអាចារ្យសំអុន ហៅ គិម សំអុន គឺជាព្រះចៅអធិការវត្តស្រះធុល ដែលមានទីតាំងស្ថិតនៅក្នុងឃុំជើងចាស់ ខេត្តកំពង់ស្ពឺ។ នៅក្នុងឆ្នាំ១៩៦៨ ក្រោមរូបភាពទេសនាអប់រំ និងព្រោកប្រាជ្ញ ខ្ញុំកសាងបានកម្លាំងចំនួន២នាក់ រួមមាន ឆេន គឺជាវរសេនាតូចលេខ១១៣៦ និរតីចាស់, អឿន ឈ្មោះប្រើក្នុងបដិវត្តន៍ បង់ត្រឡោក នៅវរសេនាតូចលេខ១១១០ ហើយមកជាប់ជាមួយកងពិសេសនៅឆ្នាំ១៩៧២។ នៅក្នុងវត្តស្រះធុលនេះមាន សេ-អ៊ី-អា សម្ងាត់ម្នាក់ឈ្មោះ គល់ ណែម ដែលជាកម្លាំងខទេ្ទសនាមមកពីភ្នំពេញ។

នៅចុងឆ្នាំ១៩៦៩ ខ្ញុំសឹក ហើយក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំ, គល់ ណែម និង តាញ៉ែម ចូលធ្វើជាកងឈ្លប។ នៅក្នុងឆ្នាំ១៩៧១ ខ្ញុំ និង គល់ ណែម ចូលបក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងឆ្នាំ១៩៧២ គល់ ណែម ត្រូវបានអង្គការចាត់តាំងឲ្យមកភូមិភាគនិរតីវិញ ហើយខ្ញុំមានតួនាទីជាប្រធានវរសេនាតូចរបស់តំបន់៣២។ ក្រោយមកខ្ញុំមកនៅមន្ទីរ៩៩ ដែលមានឈ្មោះ តាំង ខែត ហៅ ខាន់ គឺជាលេខា។ ខ្ញុំដាច់ខ្សែទាក់ទងពី គល់ ណែម ហើយចាប់ផ្តើមទំនាក់ទំនងជាមួយ តាំង ខែត វិញ។ ខ្ញុំបានធ្វើសកម្មភាពជាចំហគឺដោះលែងអ្នកទោសវាយប្រហារលើកម្មាភិបាលថ្នាក់លើ បង្កសកម្មភាពដឹកទឹកត្នោតជូរជាប្រចាំ។ បក្ខពួកដែលដឹកទឹកត្នោតជូរជាមួយខ្ញុំមានតាំង ខែត លេខាមន្ទីរ៩៩, ហេង គឺជាលេខាមហាសាំង, ផន គឺជាប្រធានក្រុមធំស៊ីងឃៀច។

នៅខែឧសភា ឆ្នាំ១៩៧៥ អង្គការបានដក តាំង ខែតឲ្យទៅកសិដ្ឋានឈ្លើយសឹក ត្រពាំងដោរ ស្ថិតនៅឃុំត្រពាំងដោរ ស្រុកឱរ៉ាល់ (ខេត្តកំពង់ស្ពឺ)។ តាំង ខែត បានខទេ្ទសនាមកម្លាំងដែលគាត់គ្រប់គ្រងឲ្យខ្ញុំស្គាល់មានពីរប្រភេទគឺកម្លាំងស្រប មានឈ្មោះ សែ គឺជាអតីតគណៈសន្តិសុខ, ឆែ គឺជាអនុសន្តិសុខតំបន់៣២, ថន គឺជាមេក្រុមស្នូលរបស់សន្តិសុខ, រឿន គឺជាយុទ្ធជនកងការពារមន្ទីរសន្តិសុខ៣២, វ៉ើត គឺជាយុទ្ធជនកងការពារមន្ទីរសន្តិសុខ៣២, រី គឺជាយុទ្ធជនកងការពារមន្ទីរសន្តិសុខ៣២ និង រិន គឺជាយុទ្ធជនកងការពារមន្ទីរសន្តិសុខ៣២ និងកម្លាំងថ្មីដែលទើបតែអប់រំ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំត្រូវអង្គការចាត់តាំងមកនៅមន្ទីរ៣២ ចំណែក គល់ ត្រូវគ្រប់គ្រងនៅមន្ទីរ៩៩។ តាំង ខែត បានមកលួចជួបខ្ញុំនៅមន្ទីរ៣២ចំនួនពីរលើក។ នៅមន្ទីរ៣២ ខ្ញុំទាក់ទងបាន ខេង គឺជាខ្មែរចាស់ពីមុន នៅខាងចិញ្ចឹមគោ ហើយ ខេង មានខ្សែខាងរលាក់កងជើង ពោធិ៍បិទ និង ឃុំប្រាំបីមុំ ស្រុកថ្ពង (ខេត្តកំពង់ស្ពឺ)។

នៅដើមឆ្នាំ១៩៧៧ អង្គការដក ខេង គឺជាប្រធានខាងចិញ្ចឹមគោរបស់តំបន់៣២, ជូ គឺជាប្រធានកងផលិតតំបន់៣២, តាសន និង អុន។ ពេលនោះមានប្រជុំនៅមន្ទីរ៩៩ ហើយអ្នកចូលរួមប្រជុំរួមមាន ខ្ញុំ, គល់, ឆែ, សែ, ថន និង រិន។ ខ្លឹមសារក្រោយការប្រជុំគឺយើងត្រូវពិនិត្យសភាពការណ៍នៅចំបក់ និងរកមូលដ្ឋានបង្អែកសម្រាប់រកទំនាក់ទំនងខាងក្រៅ ដោយឲ្យ សែ ចេញក្រៅចាំទាក់ទងជាមួយ ឆាំ។

ចុងក្រោយ ខ្ញុំត្រូវអង្គការចាប់មកដាក់នៅមន្ទីរ៩៩វិញ។ ឆែ ត្រូវអង្គការសម្រេចឲ្យដក។ មនុស្សដែលពាក់ព័ន្ធជាមួយសកម្មភាពរបស់ខ្ញុំរួមមាន៖ ទេព សាអ៊ុម គឺជាអាចារ្យបង្រៀនបាលី នៅវត្តសុខារាម, គីម សំអុន គឺជាព្រះចៅអធិការវត្តស្រះធុល, សឺន សាមិត្ត នៅកម្ពុជាក្រោម, នួន សំណាក រៀនបាលីនៅវត្តទេពប្រណម្យ, គល់ ណែម គឺជាអនុបញ្ជាការវរសេនាធំ តំបន់៣២, ចិន ឆេន គឺជាយុទ្ធជនកងវរសេនាតូច១៣៦, អឿម អឿ ហៅ បង់ត្រឡោក អតីតយុទ្ធជនវរសេនាតូច១៣៦, ចត់ស្លាប់នៅក្នុងឆ្នាំ១៩៧២ ពេលរត់ចូលដីខ្មាំង, ឆន គឺជាលេខាឃុំវិរស ស្រុក២៨ តំបន់៣២, មោក គឺជាជាងដែក, អៀម គឺជាប្រធានរណសិរ្សឃុំជើងរាស់, គក់ គឺជាពេទ្យទ័ពតំបន់៣២, គីន នៅមន្ទីរកសិដ្ឋាន, ឈន គឺជាសេដ្ឋកិច្ចកងតំបន់៣២, សុខ នៅសេដ្ឋកិច្ចកងតំបន់៣២, ខុន គឺជានីរសារវរសេនាធំ១៨៩,

*យ៉ាន នៅកន្លែងចិញ្ចឹមសត្វតំបន់៣២, ហេង គឺជាអតីតកងយុវជនតំបន់៣២, ចយ គឺជាពេទ្យវរសេនាធំ១៨៩, នារី យន គឺជាពេទ្យវរសេនាធំ១៨៩, នារី រឿន គឺជាពេទ្យវរសេនាធំ១៨៩, នារី វីន គឺជាពេទ្យវរសេនាធំ១៨៩, តាំង ខែត ហៅ ខាន់ គឺជាប្រធានមន្ទីរឈ្លើយសឹក អង្គការចាប់ឆ្នាំ១៩៧៦, ឈាង គឺជាលេខាឃុំមហាសាំង ស្រុក២៧, ផន គឺជាមេក្រុមស្ទូងរបស់សន្តិសុខ, គុល គឺជាអតីតគណៈសន្តិសុខ, វ៉ែន គឺជាគណសហករណ៍ឃុំសង្កែសាទប, នារី ឯម គឺជាគណសហករណ៍ឃុំសង្កែសាទប, នារី វ៉ាន គឺជាគណសហករណ៍ឃុំសង្កែសាទប ស្រុកឪរ៉ាល់, រ៉ាង ក្តាប់ក្រុមធ្វើទ្វារទឹករបស់កងចល័ត ឃុំសង្កែសាទប, ឌិប គឺជាប្រធានភូមិត្រពាំងកង ឃុំសង្កែសាទប, ប៉ាត គឺជាប្រធានភូមិតាម៉ិញ, ផុន គឺជាប្រធានភូមិស្រែវៀន, សៀង គឺជាគណកងចល័តឃុំ, ឆន យុទ្ធជន, ឡុង កងចល័ត, ឆាយ នៅភូមិយ៉ានពីស, ជឿន គឺជាអនុប្រធានភូមិតាម៉ិញ, នារី សួន គឺជាប្រធានចិញ្ចឹមជ្រូកសហករណ៍ឃុំសង្កែ, នារី មឿន គឺជាកងចល័តឃុំសង្កែសាទាប, តាសាន គឺជាអតីតប្រធានរោងជាងឈើ, ហៃ គឺជាអ្នកបើកឡានឲ្យរោងអាឈើរបស់ភូមិភាគបស្ចិម, ផុន គឺជាអ្នកបើកឡានឲ្យរោងអាឈើរបស់ភូមិភាគបស្ចិម, គូ គឺជាប្រធានភូមិព្រីងកោង ឃុំសង្កែសាទាប។ ក្រោយមកនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្ញុំមកសួរចម្លើយ។*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ000៥៥។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ចាប ណម ពិតបុយ៉ាងណានោះទេ?***



*កម្មាភិបាលខ្មែរក្រហម។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ឌឿន គឹមសាន ៖ អតីតប្រធានក្រុម នៅការដ្ឋានឆ្ល័ត្រ

**អេង វណ្ណីកា**



ឌឿន គឹមសាន អាយុ៦៣ឆ្នាំ បច្ចុប្បន្នជាប្រធានភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (លី ដេវីដ / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឌឿន គឹមសាន អាយុ៦៣ឆ្នាំ រស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងបច្ចុប្បន្នគឺជាប្រធានភូមិទីប្រាំបី។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ភួង ពៅ និងមានកូនចំនួនបួននាក់។ឪពុកខ្ញុំឈ្មោះ អៀ សុខាន់ និងម្តាយឈ្មោះ អែម គឹមអុល។ ខ្ញុំគឺជាកូនទី៧ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៧ នាក់។ កាលនៅពីក្មេង ខ្ញុំទៅរស់នៅជាមួយបងស្រីនៅ ទីរួមខេត្តកំពង់ចាម និងចូលរៀននៅសាលាបឋមសិក្សាដីដុះ។ បន្ទាប់មក ខ្ញុំប្តូរទៅរៀននៅសាលាបឋមសិក្សាទួលថ្មរហូតដល់ថ្នាក់ទី៩។

បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញបាតុកម្ម ផ្ទុះឡើង និងក្បួនបាតុករដង្ហែចូលមកដល់ទីរួមខេត្ត។ នៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ខ្ញុំបន្តរស់នៅជាមួយបងស្រីនៅ ទីរួមខេត្តកំពង់ចាមដដែល ប៉ុន្តែខ្ញុំឈប់រៀនពីព្រោះពេលនោះមានការប្រយុទ្ធគ្នារវាង ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះកាន់តែខ្លាំងឡើងៗ។ កងទ័ពរំដោះខ្មែរក្រហមបើកការវាយប្រហារ និងរំកិលចូលមកទីរួមខេត្តកំពង់ចាមបន្តិចម្តងៗ។ នៅឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមបើកការវាយប្រយុទ្ធជាទ្រង់ទ្រាយធំ និងរំដោះតំបន់ជាយ ទីរួមខេត្តកំពង់ចាម ដែលជាកន្លែងខ្ញុំស្នាក់នៅជាមួយបងស្រី។ ខ្ញុំនិងបងស្រីត្រូវបានជម្លៀសទៅនៅភូមិរការគយ ក្នុងស្រុកកងមាស។ យើងបានស្នាក់នៅភូមិនេះបានមួយរយៈ។

នៅពាក់កណ្តាលឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវឡោមព័ទ្ធដោយកងទ័ពរំដោះខ្មែរក្រហម គឺមានតែផ្លូវទឹកប៉ុណ្ណោះដែលជាផ្លូវអាចចូលក្នុងទីរួមខេត្តកំពង់ចាមបាន។ ទាហានម៉ារីន លន់ នល់ តែងតែបើកកប៉ាល់ចម្បាំង និងកប៉ាល់ដឹកស្បៀង ព្រមទាំងសម្ភារសឹកផ្សេងៗពីទីក្រុងភ្នំពេញទៅ ទីរួមខេត្តកំពង់ចាម ហើយជាញឹកញាប់បានទទួលរងការវាយប្រហារដោយកងទ័ពរំដោះខ្មែរក្រហមពីត្រើយម្ខាងនៃទន្លេមេគង្គ។ នៅឆ្នាំ១៩៧៣ ដដែល កងទ័ពរំដោះខ្មែរក្រហមវាយរំដោះបានពាក់កណ្តាល ទីរួមខេត្តកំពង់ចាម និងបន្តប្រយុទ្ធជាមួយ ទាហាន លន់ នល់ ដែលនៅសេសសល់ម្តុំសាលាខេត្ត។

នៅឆ្នាំ១៩៧៤ ខ្ញុំត្រឡប់មករស់នៅភូមិកំណើតជាមួយឪពុកម្តាយវិញ។ ចន្លោះពីឆ្នាំ១៩៧៤ និងដើម

ឆ្នាំ១៩៧៥ ខ្ញុំត្រូវកងទ័ពរំដោះខ្មែរក្រហមឲ្យចូលធ្វើការក្នុងកងប្រវាស់ដៃដើម្បីជួយប្រូតស្រូវ និងប្រមូលដំណាំផ្សេងៗ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមបង្កើតសហករណ៍ និងចាត់ឲ្យប្រជាជនធ្វើការនៅកងចល័តតាមការដ្ឋានផ្សេងៗ។ ខ្ញុំត្រូវបញ្ជូនឲ្យទៅធ្វើការនៅកងរយដែលមានទិសដៅធ្វើស្រែ និងលើកទំនប់នៅការដ្ឋានឆ្ន័ត្រ។ ខ្ញុំត្រូវក្រោកពីម៉ោង៤ និងត្រូវចូលរួមប្រជុំជួររយៈពេលមួយម៉ោង។ ខ្ញុំចាប់ផ្តើមធ្វើការពីម៉ោង៦ដល់ម៉ោង១១ព្រឹក។ បន្ទាប់ពីខ្ញុំហូបបបរនៅរោងបាយរួមរួច ខ្ញុំត្រូវបន្តធ្វើការចាប់ពីម៉ោង១ដល់ម៉ោង៥រសៀល។ ម៉ោង៦ដល់ម៉ោង៧ ល្ងាចគឺជាម៉ោងធ្វើការងារសង្គមនិយម គឺខ្ញុំនិងសមមិត្តផ្សេងទៀតត្រូវកាប់ដើមទន្ទ្រានខែត្រ និងស្រង់កំប្លោកដើម្បីយកមកធ្វើជី។ ខ្ញុំមិនបានដឹងថាម៉ោងសង្គមនិយមនេះយ៉ាងម៉េចទេ គឺគ្រាន់តែធ្វើតាមបទបញ្ជារបស់ប្រធានកងក្តាប់រួមប៉ុណ្ណោះ។

នៅឆ្នាំ១៩៧៧ អង្គការចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានកង «ក»។ នៅកងចល័តរយបុរសត្រូវបានបែងចែកជា៣កង៖ ទី១) គឺកង «ក» មានចំនួន១០កង ហើយក្នុងមួយកងៗមានសមមិត្តចំនួន១០នាក់។ ខ្ញុំគឺជាប្រធានកង «ក» ម្នាក់ក្នុងចំណោមប្រធានកង «ក» សរុបចំនួន១០នាក់។ ទី២) គឺកង «ខ» មានចំនួន៣កង ហើយក្នុងមួយកងមានសមមិត្តចំនួន៣០នាក់។ កង «ខ» គឺគ្រប់គ្រងលើកង «ក»។ ទី៣) គឺកង «គ» ដែលក្តាប់រួមកង «ខ» ។ ប្រធានឈ្មោះមិត្ត ឆាត និងអនុប្រធានឈ្មោះមិត្តប៊ិន។ នៅក្នុងការដ្ឋានឆ្ន័ត្រ ខ្ញុំនៅចងចាំអំពីព្រឹត្តិការណ៍សំខាន់ៗចំនួន៣ មុនការមកដល់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ដែលធ្វើការចាប់ខ្លួន និងសម្លាប់កម្មាភិបាលមូលដ្ឋាន។

**ព្រឹត្តិការណ៍ទី១)** គឺការទៅទទួលប្រធានតំបន់២២ ឈ្មោះមិត្ត ស៊ុម នៅឆ្នាំ១៩៧៦។ បន្ទាប់ពីទទួលប្រធានតំបន់២២រួចរាល់ ខ្ញុំត្រូវទៅធ្វើការវិញ។

**ព្រឹត្តិការណ៍ទី២)** គឺការទៅកាប់ដូងឲ្យមេការចិននៅរោងចក្រចម្ការកៅស៊ូពាមជាំង។ នៅព្រឹកមួយក្នុងឆ្នាំ១៩៧៦ កង «ក» របស់ខ្ញុំត្រូវបានបញ្ជាឲ្យបេះផ្លែដូងជាច្រើន និងដឹកមួយឡានធំចេញពីការដ្ឋានទៅរោងចក្រចម្ការកៅស៊ូពាមជាំង។ ពេលទៅដល់រោងចក្រ ខ្ញុំបានដឹកនាំសមមិត្តឲ្យកាប់ដូងដើម្បីយកឲ្យមេការចិនដែលកំពុងធ្វើការនៅរោងចក្រចម្ការកៅស៊ូ។ នៅពេលនោះ ខ្ញុំឃើញមានមេការចិនប្រុសស្រីប្រមាណ២០ទៅ៣០នាក់ ក្នុងសម្លៀកបំពាក់ខោខ្មៅអាវខ្មៅដូចខ្ញុំ បានដើរមកយកដូងដឹក។ ខ្ញុំក៏បានឲ្យដូងទៅមេការចិន។ មេការចិននោះបានងក់ក្បាលដើម្បីបង្ហាញការអរគុណ។ ខ្ញុំឮមេការចិននិយាយគ្នាថាចូលចិត្តហូបទឹកដូង ដោយមានអ្នកបកប្រែភាសាម្នាក់នៅទីនោះដែរ។ បន្ទាប់ពីមេការចិនដឹកទឹកដូងរួច ខ្ញុំនិងកង «ក» ត្រូវអង្គការដឹកមកការដ្ឋានវិញ។

**ព្រឹត្តិការណ៍ទី៣)** គឺការទៅលើកដីនៅស្ថានីយ៍ស្តុកទុកទឹកទួលទម្លាប់ស្ថិតនៅស្រុកអូររាំងឪ។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានទួលទម្លាប់ដើម្បីជីកស្រះ និងលើកដីទប់មាត់ស្រះប្រវែង១០០ម៉ែត្រ។ ក្នុងអំឡុងពេលនោះ ខ្ញុំក៏បានឃើញអ្នកជំនាញចិនមួយក្រុមទៀតដែលភាគច្រើនស្លៀកខោខ្លី និងពាក់ស្បែកជើងខ្ទប់ចូលមកពិនិត្យដំណើរការម៉ាស៊ីនបូមទឹកធំៗនៅក្នុងរោង។ អ្នកជំនាញការចិនក៏បានចុះមកមើលកន្លែងខ្ញុំកំពុងជីកដីដែរ។ នៅពេលរសៀលបន្តិចអ្នកជំនាញការចិនទាំងនោះត្រូវបានខ្មែរក្រហមដឹកត្រឡប់ទៅវិញ ព្រោះមិនមានកន្លែងស្នាក់នៅ គឺមានតែកងធារាសាស្ត្រយាមកន្លែងប៉ុណ្ណោះ។ អ្នកជំនាញចិនទាំងនេះមកពិនិត្យការដ្ឋានបានតែពីរថ្ងៃតែប៉ុណ្ណោះ ចំណែកការដ្ឋានស្ថានីយ៍ស្តុកទុកទឹកនេះបានបញ្ចប់ការសាងសង់ក្នុងរយៈពេលតែ៣ខែ។

បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនមកធ្វើការនៅការដ្ឋានឆ្ន័ត្រវិញ។ ខ្ញុំបន្តធ្វើការនៅការដ្ឋាននេះ រហូតដល់ពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមករំដោះប្រជាជនចេញពីខ្មែរក្រហម ទើបខ្ញុំវិលត្រឡប់មករស់នៅជួបជុំគ្រួសារវិញ។

# មួយទសវត្សរ៍ធ្វើទាហានបីរបប

ផេង ពង្សរ៉ាស៊ី



*គង់ ស៊ិង សព្វថ្ងៃរស់នៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ជាចាស់ទុំនៅក្នុងភូមិដែលមានសុខភាពល្អ មានមាឌមាំ រួមជាមួយការចងចាំ គង់ ស៊ិង បានរំឭកអំពីប្រវត្តិផ្ទាល់ខ្លួនបទពិសោធន៍ជីវិតឆ្លងកាត់សង្គ្រាមនៅក្នុងទឹកដីប្រទេសវៀតណាម និងកម្ពុជាកាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ថា នៅឆ្នាំ២០២២ នេះ ខ្ញុំមានអាយុ៧៨ឆ្នាំហើយ ហើយបច្ចុប្បន្ន ខ្ញុំរស់នៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។

ខ្ញុំមានស្រុកកំណើតនៅឃុំឃិនទង ស្រុកយ៉ាន់យ៉ាវ ខេត្តមាត់ជ្រូក កម្ពុជាក្រោម (បច្ចុប្បន្នប្រទេសវៀតណាម)។ ខ្ញុំនិងប្រពន្ធកូន ព្រមទាំងឪពុកម្ដាយបានមករស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៨ បន្ទាប់ពីកងកម្លាំងខ្មែរក្រហមបានវាយលុកលុយចូលដល់ទឹកដីដែលជាស្រុកកំណើតរបស់ខ្ញុំ និងបានកៀរប្រជាជនកម្ពុជាក្រោមស្ទើរតែទាំងអស់ឲ្យមកកាន់ប្រទេសកម្ពុជាដើម្បីចូលរួមធ្វើស្រែចម្ការ និងកសាងបដិវត្តន៍ជាមួយខ្មែរក្រហម។ ដោយសារខ្ញុំធ្លាប់មានបទពិសោធន៍បម្រើជាទាហានរបស់ធីវគីនៅវៀតណាម ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើកងទ័ពខ្មែរក្រហមប្រឆាំងនឹងវៀតណាម បន្ទាប់ពីបានមកស្នាក់នៅក្នុងប្រទេសកម្ពុជាត្រឹមតែរយៈពេលជាងពីរខែប៉ុណ្ណោះ។

ខ្ញុំបានវិលត្រឡប់ទៅកាន់ទឹកដីកម្ពុជាក្រោមវិញ ដើម្បីប្រយុទ្ធជាមួយកងកម្លាំងវៀតណាម តាមទិសដៅកំណត់របស់កងទ័ពខ្មែរក្រហមនៅលើភ្នំមួយចំនួនដែលស្ថិតនៅក្នុងប្រទេសវៀតណាម។ ក្រោយពីវិលត្រឡប់ពីសមរភូមិវិញ កងទ័ពវៀតណាមបានវាយចូលមកប្រទេសកម្ពុជាដើម្បីផ្ដួលរំលំរបបខ្មែរក្រហម។ ខ្ញុំបានដោះសម្លៀកបំពាក់យោធាខ្មែរក្រហមចោល និងបាននាំប្រពន្ធកូនមកកាន់ស្រុកគិរីវង់ ខេត្តតាកែវ ដែលខ្ញុំកំពុងរស់នៅនាពេលបច្ចុប្បន្ននេះ។ ដំបូង ខ្ញុំគិតថា ខ្ញុំស្នាក់នៅទីនេះតែត្រឹមរយៈពេលខ្លីប៉ុណ្ណោះ ព្រោះខ្ញុំនិងក្រុមគ្រួសារចង់វិលត្រឡប់ទៅកាន់ស្រុកកំណើតវិញ។ ប៉ុន្តែបន្ទាប់ពីរស់នៅអស់រយៈពេលប៉ុន្មានឆ្នាំក្រោយមក ខ្ញុំក៏សម្រេចចិត្តឈប់វិលត្រឡប់ទៅរស់នៅឯស្រុកកំណើតវិញ ហើយបន្តរស់នៅក្នុងភូមិព្រៃតាម៉ៅរហូតមកដល់បច្ចុប្បន្ន។ សព្វថ្ងៃ ខ្ញុំមិនប្រកបរបរអ្វីឡើយ ក្រៅពីដាក់ចិត្តដាក់កាយធ្វើបុណ្យថែរក្សាវត្តអារាម និងសុំសីលទាន។

ទាក់ទងនឹងប្រវត្តិចូលរួមធ្វើសង្គ្រាមរបស់ខ្ញុំគឺ ខ្ញុំធំដឹងក្ដីឡើងនៅក្នុងទឹកដីវៀតណាម (កម្ពុជាក្រោម)។ ខ្ញុំចេះនិយាយភាសាវៀតណាម និងភាសា

ខ្មែរច្បាស់លាស់។ ខ្ញុំចេះអាននិងសរសេរអក្សរខ្មែរ ដោយសារខ្ញុំបានចូលរៀនជាមួយព្រះសង្ឃនៅវត្តខ្មែរមួយក្នុងទឹកដីវៀតណាម។ ដោយសារកើតមានសង្គ្រាមជាហូរហែរនៅក្នុងប្រទេសវៀតណាមរវាងវៀតណាមខាងជើង និងវៀតណាមខាងត្បូង ធ្វើឲ្យការរស់នៅរបស់ខ្ញុំពិបាកខ្លាំងណាស់។ ក្មេងជំទង់ៗដូចខ្ញុំត្រូវកំណែនឲ្យធ្វើទាហានវៀតណាម ដើម្បីចូលរួមប្រយុទ្ធប្រឆាំងជាមួយកងទ័ពវៀតណាមខាងជើង (ហាណូយ)។ ខ្ញុំខ្លាចកំណែនទាហាននេះណាស់។ ខ្ញុំបានឈប់រៀន និងបានរត់មកកាន់ប្រទេសកម្ពុជា។

នៅកម្ពុជា ខ្ញុំបានមកស្នាក់នៅផ្ទះពូរបស់ខ្ញុំស្ថិតនៅក្នុងឃុំភ្នំដិនមួយរយៈពេលខ្លីប៉ុណ្ណោះ មុននឹងខ្ញុំត្រូវបានបញ្ចុះបញ្ចូលឲ្យចូលធ្វើជាទាហាន លន់ នល់។ ខ្ញុំមិនចាំឆ្នាំដែលខ្ញុំចូលទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថារបប លន់ នល់ បានកាន់កាប់ប្រទេសហើយ។ ខ្ញុំធ្វើទាហាន លន់ នល់ បានប្រហែលមួយឆ្នាំ ក៏សម្រេចចិត្តវិលត្រឡប់ទៅកាន់ស្រុកកំណើតនៅកម្ពុជាក្រោមវិញ ព្រោះខ្ញុំឮដំណឹងថា ស្ថានភាពនៅទីនោះប្រក្រតីឡើងវិញហើយ។

ទៅដល់ស្រុកកំណើតនៅកម្ពុជាក្រោម ខ្ញុំបានរៀបការប្រពន្ធ។ នៅពេលដែលខ្ញុំមានកូនពីរនាក់ទៅហើយ ស្ថានភាពស្រុកទេសហាក់ដូចជាវិលត្រឡប់ទៅរកស្ថានការណ៍ចលាចលដូចកាលពីប៉ុន្មានឆ្នាំមុនវិញ។ លើកនេះ ខ្ញុំមិនសម្រេចចិត្តរត់មកប្រទេសកម្ពុជាជាលើកទីពីរទេ ព្រោះខ្ញុំមានប្រពន្ធនឹងកូនហើយ។ ខ្ញុំទ្រាំរស់នៅទាំងភិតភ័យនៅស្រុកកំណើតឯកម្ពុជាក្រោម។ ដោយមិនអាចគេចផុតពីកំណែនទាហានបាន ខ្ញុំបានសម្រេចចិត្តចូលបម្រើជាកងទ័ពរបស់វៀតណាម។ ខ្ញុំត្រូវបានទាហានវៀតណាមឲ្យជ្រើសរើសកងពលដែលខ្ញុំពេញចិត្ត។ ខ្ញុំបានជ្រើសរើសកងពល «ស៊ីដង់បែ» មានភារកិច្ចវាយប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាមខាងជើង (ហាណូយ) នៅចម្ងាយប្រហែល ៣០ គីឡូម៉ែត្រពីស្រុកកំណើតខ្ញុំ។ ខ្ញុំស្ថិតនៅក្នុងកងកាំភ្លើងធំ និងនៅជានីរសារផ្ទាល់ជាមួយប្រធានកងពល។ ខ្ញុំស្លៀកសម្លៀកបំពាក់ត្រែអ៊ី មានស្លាកសញ្ញារូបឥន្ទ្រីយ៍ និងលេខ១៧។ ខ្ញុំបានចូលប្រយុទ្ធច្រើនសមរភូមិណាស់ មុននឹងខ្ញុំលួចរត់ត្រឡប់មកកាន់ស្រុកកំណើតជួបប្រពន្ធនិងកូនវិញ។ ខ្ញុំនៅបម្រើការនៅក្នុងកងពល ស៊ីដង់បែ អស់រយៈពេលជាងមួយឆ្នាំ។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានខ្មែរក្រហមកៀរឲ្យមកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមកសាងប្រទេស។ មុនដំបូង ខ្ញុំបានដឹងថាកងទ័ពវៀតណាមនៅតាមព្រំដែនដកថយចូលទៅក្នុងប្រទេសរបស់ខ្លួនវិញហើយ។ បន្ទាប់មក ខ្ញុំឃើញមានវត្តមានកងទ័ពខ្មែរក្រហមចូលលុកលុយពេញស្រុកកំណើតរបស់ខ្ញុំ ហើយប្រាប់ឲ្យប្រជាជនទាំងអស់ធ្វើដំណើរទៅកាន់ប្រទេសកម្ពុជាវិញ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងពីស្រុកកំណើតនៅកម្ពុជាក្រោម រហូតដល់ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំបានស្នាក់នៅវត្តប្រើសអស់រយៈពេលជាងពីរខែ។

ក្រោយមក ដោយសារ ខ្ញុំនិងប្រពន្ធកូនមិនមានអ៊ីហូបគ្រប់គ្រាន់ ទើបខ្ញុំសម្រេចចិត្តស្នើសុំចូលបម្រើជាកងទ័ពខ្មែរក្រហម។ បន្ទាប់ពីចូលកងទ័ពភ្លាម ខ្ញុំត្រូវចាត់តាំងឲ្យចេញទៅប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅក្នុងទឹកដីវៀតណាម។ ក្រុមខ្ញុំមានគ្នា៦៩ នាក់។ យើងបានទៅដល់គោលដៅដំបូងនៅលើភ្នំពពាយ រួចបន្តទៅកាន់ទីតាំងបន្ទាប់គឺស្ថិតនៅខាងលិចបាជុក និងភ្នំអកយំ ក្នុងស្រុកស្វាយទង ខេត្តមាត់ជ្រូក។ នៅទីនោះ ក្រុមខ្ញុំចំនួន៦០នាក់បានដាក់ពង្រាយគ្នានៅលើភ្នំនោះនិងនៅតាមចង្កេះភ្នំ ដើម្បីការពារទឹកដីដែលយើងយកបាន។ ខ្ញុំ និងទាហានសេសសល់ ៨ នាក់ទៀត បានចុះពីលើភ្នំអកយំ ធ្វើដំណើរឆ្ពោះមកកាន់មូលដ្ឋានទ័ពនៅក្នុងវត្តប្រើសវិញ ដើម្បីរាយការណ៍ពីលទ្ធផល និងស្នើសុំផែនការបន្ទាប់។ នៅពេលដែលពួកខ្ញុំមកដល់វត្តប្រើស ទើបដឹងថា កងកម្លាំងវៀតណាមបានវាយចូលមកដល់ទឹកដីខ្មែរ និងវាយបណ្តេញកងកម្លាំងខ្មែរក្រហមចេញអស់ហើយ។ ខ្ញុំបានដោះសម្លៀកបំពាក់កងទ័ពខ្មែរក្រហមចេញ រួចមកនាំប្រពន្ធកូនត្រឡប់មករស់នៅក្នុងភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ជាទីកន្លែងដែលខ្ញុំកំពុងរស់នៅសព្វថ្ងៃនេះ។

# ស្លេះ ហានីហ្វះ ៖ គ្រួសារខ្ញុំគឺជាអ្នកតម្បាញ

មីន សាណាស់




ស្លេះ ហានីហ្វះ រស់នៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីខែកក្កដា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស្លេះ ហានីហ្វះ ភេទស្រី អាយុ ៧៣ឆ្នាំ ខ្ញុំមានទីកន្លែងកំណើតនិងរស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ ខ្ញុំរៀបការជាប្តីឈ្មោះ ម៉ាត់ យូណោស មានមុខរបរគឺជាជាងសាងសង់ផ្ទះឈើ និងមានកូនចំនួន៤នាក់ គឺប្រុសចំនួន២នាក់ និង ស្រីចំនួន២នាក់។ ក្រោយរៀបការបានរយៈពេលបីថ្ងៃ ក៏មានការទម្លាក់គ្រាប់បែកចំផ្ទះរបស់ខ្ញុំរស់នៅ បណ្តាលឲ្យបាត់បង់ទ្រព្យសម្បត្តិអស់ ប៉ុន្តែមិនបណ្តាលឲ្យស្លាប់មនុស្សទេ។ គ្រួសាររបស់ខ្ញុំបានផ្អាកត្បាញតាំងពីពេលនោះមក។

គ្រួសារខ្ញុំគឺជាអ្នកត្បាញសំពត់សូត្រ ក្រមា និងសារុងសូត្រ នៅភូមិកំពង់ក្របី តាំងពីមុនសម័យបារាំងកាន់កាប់ស្រុកភូមិម្ល៉េះ។ ចំណែកម្តាយខ្ញុំគឺជាអ្នកជំនាញខាងពិនិត្យសំពត់សូត្រ ត្បាញ ចងគោមពណ៌ និងជាអ្នកទិញសំពត់សូត្រ សារុង ពីអ្នកភូមិកំពង់ក្របីយកទៅលក់នៅទីរួមខេត្តកំពង់ចាម។ ម្តាយខ្ញុំដឹងថាគោមសំពត់តូចៗគឺជាតម្រូវការរបស់បងប្អូនជនជាតិខ្មែរ ហើយគោមមានផ្កាធំៗ គោមរូបក្បាច់ឈរធំៗ សម្រាប់បងប្អូនជនជាតិចាម ជាហេតុនាំឲ្យគាត់មានភាពងាយស្រួលក្នុងការលក់នៅតាមទីផ្សារ។ ចំណែកអ្នកភូមិក៏មានការងារត្បាញច្រើន ព្រោះសំពត់លក់ដាច់ច្រើន។

អ្នកបង្កើតគោម ប្តូចងគឺសុទ្ធតែអ្នកឆ្លាតវៀសវៃ អត់ធ្មត់ ទើបអាចរចនាគោមសំពត់សូត្រយ៉ាងល្អប្រណិត ប្លែកៗ ថ្មីសម្រាប់អ្នកប្រើប្រាស់។ ប្រហែលនៅឆ្នាំ១៩៧២ វត្តមានកងទ័ពរំដោះខ្មែរក្រហមចូលមកគ្រប់គ្រងក្នុងភូមិរបស់ខ្ញុំ ហើយគ្រួសារខ្ញុំស្ថិតក្នុងបញ្ជីអ្នកមានធនធាន និងស្ថិតក្រោមការតាមដានរបស់កងទ័ពរំដោះ។ ក្រុមគ្រួសារខ្ញុំត្រៀមខ្លួនរត់ចេញពីភូមិដោយឃើញថា ជារៀងរាល់យប់កងទ័ពរំដោះខ្មែរក្រហមមកហៅមនុស្សប្រុសដែលមានចំណេះដឹងក្នុងភូមិឲ្យទៅជាមួយពួកគេ។ ប្រសិនជាមិនចុះពីលើផ្ទះ កងទ័ពរំដោះខ្មែរក្រហមយកកាំបិតផ្គាក់រុកពីក្រោមផ្ទះ។ នៅដើមឆ្នាំ១៩៧៤ គ្រួសារខ្ញុំរត់គេចទៅរស់នៅក្នុងខេត្តកំពង់ចាម បន្ទាប់មកទៅរស់នៅតាមភូមិ ដើម្បីលាក់ប្រវត្តិរូបឪពុករបស់ខ្ញុំដែលជាអតីតទាហាន លន់ នល់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមកាន់កាប់ប្រទេសបានទាំងស្រុង ដូច្នេះគ្រួសារ

ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅធ្វើការនៅ ខាងកំពង់ថ្ម ខេត្តកំពង់ធំ។

នៅឆ្នាំ១៩៧៩ ខ្ញុំនិងប្តីបាននាំកូនៗត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែផ្ទះ និងដីរបស់យើងមានអ្នកចូលមករស់នៅ និងកាន់កាប់អស់ទៅហើយ ហេតុនេះគ្រួសារខ្ញុំបានសុំដីណាដែលទំនេរពីរដ្ឋអំណាចដើម្បីសង់រោងតូចមួយសម្រាប់រស់នៅបណ្តោះអាសន្ន។ ពេលនោះប្តីរបស់ខ្ញុំមានជំនាញផ្នែកសាងសង់ស្រាប់ក៏ដើរសង់ផ្ទះអ្នកភូមិដោយប្តូរពីថ្លៃឈ្នួលជាប្រាក់មកយក ពោត អង្ករ បុសាច់ មកផ្គត់ផ្គង់គ្រួសារ។

នៅឆ្នាំ១៩៨២ ខ្ញុំចាប់ផ្តើមត្បាញក្រមាអំបោះសម្រាប់ប្រើប្រាស់ក្នុងផ្ទះ និងលក់យកប្រាក់ខ្លះ។ បន្ទាប់មកប្រហែលជាឆ្នាំ១៩៩២ ខ្ញុំចាប់ផ្តើមត្បាញសំពត់សូត្រឡើងវិញ។ ខ្ញុំបានបង្រៀនកូនស្រីខ្ញុំទាំងពីរនាក់ឲ្យចេះត្បាញ ជ្រលក់ពណ៌ ចងគោម ប៉ុន្តែកូនៗរបស់ខ្ញុំមិនចេះស្ទាត់ទេ។ ក្មេងៗជំនាន់ក្រោយចេះតែត្បាញមួយមុខប៉ុណ្ណោះ។ ចំពោះគោម ដែលខ្ញុំធ្លាប់ត្បាញ និងចងគោម មានដូចជា គោមសណ្តាន់, គោមក្ងោកមួយបុ ក្ងោកពីរ, គោមមាន់, គោមសំរោង, គោមខុងមិញ និងគោមជាច្រើនប្រភេទទៀត។ គោមទាំងនេះ គឺជាគោមដែលជនជាតិចាមចូលចិត្តធ្វើ ហើយវាសុទ្ធតែជាប្រភេទគោមធំៗ ប្រសិនបើជាគោមតូចៗ គឺខ្ញុំធ្វើសម្រាប់លក់ចេញឲ្យបងប្អូនខ្មែរ។

ចំណែកពណ៌គឺជំនាន់១៩៩០ គឺខ្ញុំនឹងអ្នកភូមិប្រើល័ក្តធម្មជាតិ ហើយល័ក្តខ្មែរមានពណ៌ដូចជា លឿង ក្រហម បៃតង ស្វាយ ខ្មៅ និង ខៀវ។



សំពត់សូត្រដែលជនជាតិចាមត្បាញនៅស្រុកកោះសូទិន ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឧបករណ៍រវៃអំបោះរបស់ជនជាតិចាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រស់ សៀត ៖ អតីតយុទ្ធនារីខ្មែរក្រហម

**ភា រស្មី**



រស់ សៀត នៅផ្ទះរបស់គាត់ស្ថិតនៅភូមិឫស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ រស់ សៀត ហៅ ហ៊ួយ ភេទស្រី អាយុ៧០ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅ ភូមិឫស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនសរុបចំនួន៩ នាក់ និងបានចូលបដិវត្តន៍ជាមួយខ្មែរក្រហមចំនួន៤នាក់ នៅក្នុងឆ្នាំ១៩៧០។ បងប្អូនរបស់ខ្ញុំចូលធ្វើបដិវត្តន៍តាមការឃោសនារបស់ តាចន្ថុម គឺជាអ្នកមកពីភូមិបឹង ឃុំអំពិលទោល ស្រុកមេសាង។ តាចន្ថុម ចូលមកធ្វើទំនាក់ទំនងជាមួយប្រធានសហករណ៍ភូមិឫស្សីសាញ់ឈ្មោះ ឥដ្ឋ និងសាន ដើម្បីស្វែងរកប្រជាជនឲ្យចូលធ្វើបដិវត្តន៍ជាមួយខ្មែរក្រហម។ កន្លែងដែល តាចន្ថុម មកឃោសនាគឺនៅផ្ទះមេភូមិ និងនៅវត្ត ហើយពេលខ្លះនៅតាមផ្ទះប្រជាជន។ ប្រជាជននៅក្នុងភូមិខ្ញុំជាច្រើននាក់រួម ទាំងបងប្អូនរបស់ខ្ញុំបានចូលរួមដែរ ប៉ុន្តែកាលនោះមិនទាន់ឃើញមានធ្វើសកម្មភាពអ្វីទេ។

នៅចុងឆ្នាំ១៩៧៤ មេឃុំជីផុច ឈ្មោះ មន ប្រាប់ទៅមេភូមិគ្រប់ភូមិប្រកាសស្នើសុំបាយដាក់ស្បោងពីប្រជាជនដោយក្នុងមួយគ្រួសារផ្តល់បាយមួយស្បោងក្នុងមួយថ្ងៃ។ ប្រជាជននៅក្នុងឃុំជីផុច ផ្លាស់វេនគ្នាផ្តល់អាហារឲ្យយោធាខ្មែរក្រហម ដោយធ្វើការផ្លាស់វេនក្នុងមួយថ្ងៃមួយភូមិ រហូតដល់គ្រប់ភូមិទាំងអស់នៅក្នុងឃុំ។ នៅពេលនោះប្អូនរបស់ខ្ញុំ ២ នាក់ស្លាប់នៅពេលដែលចូលធ្វើជាកងទ័ពខ្មែរក្រហម។ បន្ទាប់ពីទទួលបានជ័យជម្នះ នៅឆ្នាំ១៩៧៥ ប្រធានសហករណ៍បញ្ជូនក្រុមរបស់ខ្ញុំឲ្យទៅកាប់ខសយកមកដាក់ក្នុងសហករណ៍។ បន្ទាប់ពីកាប់ខសរួច ប្រធានកងចល័តប្រើក្រុមរបស់ខ្ញុំឲ្យទៅជីកប្រឡាយនៅក្បាលខែ្វកបន្តទៀត។ នៅក្បាលខ្វែក ខ្ញុំនិងមិត្តរបស់ខ្ញុំចំនួន៣នាក់នាំគ្នាលួចរត់មកលេងផ្ទះព្រោះក្រុមរបស់ខ្ញុំនឹកផ្ទះខ្លាំងពេក ប៉ុន្តែត្រូវប្រធានកងចល័តដឹង ហើយដើរតាមចាប់យើងទាំងយប់។ ក្រុមរបស់ខ្ញុំរត់មកដល់ផ្ទះ និងត្រូវក្រោកត្រឡប់ទៅវិញនៅម៉ោង១យប់ដើម្បីឲ្យទាន់ការងារពេលព្រឹក។ លុះម៉ោង១រសៀល ឈ្មោះ ថន គឺជាប្រធានយ ហៅក្រុមរបស់ខ្ញុំទាំង៤នាក់ទៅណែនាំដើម្បីកុំឲ្យខ្ញុំធ្វើបែបនេះទៀត។ ក្រោយពីបញ្ចប់ការងារនៅ ក្បាលខ្វែក អង្គការបញ្ជូនក្រុមកងចល័តនារីរបស់ខ្ញុំទាំងអស់ឲ្យទៅលើកប្រឡាយនៅ ខាងជើងពានភ្លើង (ស្រុកកំចាយមារ) បន្តរហូតដល់ដើមឆ្នាំ១៩៧៦ ទើប

ត្រឡប់មកសហករណ៍វិញ។

នៅឆ្នាំ១៩៧៦បន្ទាប់ពីខ្ញុំធ្វើការនៅក្នុងសហករណ៍ភូមិមិនបានប៉ុន្មាន អង្គការបញ្ជូនក្រុមរបស់ខ្ញុំឲ្យទៅធ្វើការនៅពោធិ៍រោង។ កងចល័តរបស់ខ្ញុំបញ្ចប់ការងារនៅពោធិ៍រោងហើយ ក៏ទៅធ្វើការស្រឡូងស្រឡី ហើយចេញពីស្រឡូងស្រឡីទៅលើកព្រែកនៅសំរោងរហូតដល់ខែសីហា ឆ្នាំ១៩៧៦ដដែល ទើបត្រឡប់មកភូមិឫស្សីសាញ់វិញ។ ពេលមកដល់ភូមិប្រធានសហករណ៍បញ្ជូនក្រុមកងចល័តឲ្យទៅជួយស្ទូងស្រូវនៅភូមិស្វាយអណ្ដូង រួចក៏បន្តទៅភូមិត្រពាំងស្គន់ទើបត្រឡប់មកធ្វើការទប់ទឹកនៅជិតភូមិវិញ។ នៅក្នុងភូមិឫស្សីសាញ់ អង្គការប្រើក្រុមខ្ញុំដែលមានសមាជិកចំនួន៨នាក់ ទៅស្ទូងស្រូវ១ហិកតាឲ្យរួចក្នុងមួយថ្ងៃ បើមិនទាន់រួចរាល់ គឺមិនបានអាហារហូបឡើយ។

នៅដើមឆ្នាំ១៩៧៧ អង្គការប្រើកងចល័តនារីទាំងអស់ ឲ្យទៅលើកប្រព័ន្ធភ្លឺស្រែមួយថ្ងៃឲ្យបាន២០ម៉ែត្រ គឺពេលព្រឹក១០ម៉ែត្រ និងពេលរសៀល១០ម៉ែត្រ។ ក្រុមរបស់ខ្ញុំខិតខំធ្វើការដើម្បីឲ្យគ្រប់ផែនការ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ប្រធានសហករណ៍ជ្រើសរើសឈ្មោះរបស់ខ្ញុំឲ្យទៅធ្វើជាទាហាន និងទៅបើកសម្លៀកបំពាក់នៅវត្តចំបក់។ ចេញពីវត្តចំបក់ខ្ញុំនិងមិត្តនារីផ្សេងទៀតបានទៅហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធានៅក្នុងវត្តស្មាវចំនួន៣ខែទៀត។ បន្ទាប់ពីបញ្ចប់ការហ្វឹកហាត់អង្គការបញ្ជូនក្រុមខ្ញុំឲ្យទៅត្រៀមនៅកោះទៃដងត្នោត ហើយក្រោយមកបញ្ជូនទៅវត្តព្រៃមូល។ ចេញពីវត្តព្រៃមូល អង្គការបញ្ជូនខ្ញុំឲ្យទៅត្រៀមនៅតំបន់២០។ នៅក្នុងតំបន់២០ មានឈ្មោះតា ឆាំ បានបង្វឹកក្រុមរបស់ខ្ញុំឲ្យចេះគប់គ្រាប់បែក និងគេចខ្លួនពីគ្រាប់បែក រហូតដល់ចេះសព្វគ្រប់ទើបបញ្ជូនទៅខាងត្បូងត្រពាំងផ្លុងក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ខ្ញុំនៅក្នុងកងពលលេខ១៦ ដែលមានទីតាំងឈរជើងនៅទួលសង្កែក្បាលដំរី ជិតច្រកព្រំដែន រំដេង ព្រំប្រទល់កម្ពុជា-វៀតណាម។ តួនាទីរបស់ខ្ញុំនៅព្រំដែន គឺចាំសែងយោធាខ្មែរក្រហមដែលរងរបួសនៅពេលវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម។ ខ្ញុំនៅធ្វើការក្នុងកងពលលេខ១៦រហូតដល់ខែមិថុនា ឆ្នាំ១៩៧៨ ទើបមានឈ្មោះ អៀង នឹងឈ្មោះលៃ នាំខ្ញុំរត់ត្រឡប់មកវិញ។ នៅតាមផ្លូវត្រឡប់មកវិញ ខ្ញុំត្រូវដើរកាត់ព្រៃ កាត់ភ្នំពីកន្លែងមួយទៅកន្លែងមួយដោយសម្ងាត់បំផុត និងមានយោធាខ្មែរក្រហមនៅខាងស្រុកពញាក្រែក ទៅទទួលទៀតផង។ បន្ទាប់មកទៀតខ្ញុំធ្វើដំណើរមកស្រុកមេសាងវិញ។ នៅទីនោះ ប្រធានសហករណ៍បញ្ជូនខ្ញុំឲ្យទៅនៅខាងស្រុកបាភ្នំវិញ ព្រោះប្រជាជននៅក្នុងភូមិឫស្សីសាញ់មិនពេញចិត្តខ្ញុំនិងតាមសម្លាប់ខ្ញុំចោល។ អ្នកដែលបញ្ជូនខ្ញុំទៅបាភ្នំមានឈ្មោះថា ហ៊ាន, ញ៉ និងឈ្មោះ សេង ហើយអ្នកទាំងនោះត្រូវបានប្រជាជនតាមសម្លាប់បាននៅឃុំបឹងព្រះ ស្រុកបាភ្នំ នៅពេលដែលអ្នកទាំងនោះទៅដល់ឃុំបឹងព្រះបានប្រមាណ៤ថ្ងៃ។ នៅពេលខ្ញុំរស់នៅបាភ្នំក្នុងតំបន់ ២៤ មេទ័ពតំបន់ឈ្មោះ ខិន និង ខិតបានឲ្យខ្ញុំបន្លំខ្លួនធ្វើជាប្រជាជន និងជួយស្ទូងដកអ្នកភូមិក្នុងតំបន់នោះសិនរហូតដល់ស្ថានភាពនៅក្នុងភូមិឫស្សីសាញ់ធម្មតាវិញ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំត្រឡប់ទៅរស់នៅក្នុងភូមិឫស្សីសាញ់វិញ ប៉ុន្តែនៅពេលទៅដល់ផ្ទះ ឈ្មោះ ជន គឺជាប្រធានតំបន់២០ថ្មីហៅខ្ញុំទៅសាកសួរ អំពីមូលហេតុដែលខ្ញុំត្រឡប់មកវិញ រួចហើយបញ្ជូនខ្ញុំឲ្យទៅនៅមន្ទីរពោធិ៍តាមុំ។ នៅមន្ទីរពោធិ៍តាមុំ ខ្ញុំធ្វើការដូចអ្នកទោស ហើយអ្នកគ្រប់គ្រងនៅទីនោះ មានឈ្មោះថា ប៊ិច។ ខ្ញុំធ្វើការនៅពោធិ៍តាមុំមិនបានប៉ុន្មានផង ក៏កងទ័ពវៀតណាមវាយចូលមករំដោះប្រជាជន។ នៅពេលមានភាពចលាចល ខ្ញុំលួចរត់ចេញពីមន្ទីរមកផ្ទះវិញ ហើយនាំគ្រួសារភៀសខ្លួនចេញទៅនៅជិតៗភូមិ រហូតដល់ស្ថានភាពធម្មតាទើបនាំគ្នាចូលមកក្នុងភូមិវិញ។ នៅដើមឆ្នាំ១៩៧៩ បន្ទាប់ពីខ្មែរក្រហមដួលរលំ បងប្អូនរបស់ខ្ញុំប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ សព្វថ្ងៃនេះខ្ញុំរស់នៅជាមួយបងស្រីរបស់ខ្ញុំ ព្រោះខ្ញុំទាំងពីរនាក់មិនមានគ្រួសារដូចគ្នា។ ខ្ញុំប្រកបរបរធ្វើស្រែ ដាំដំណាំ និងចិញ្ចឹមសត្វ ប៉ុន្តែទោះបីយ៉ាងណាជីវភាពគ្រួសាររបស់ខ្ញុំក៏មិនសូវជាធូរធារប៉ុន្មានដែរ។

# សេង សឿ ៖ បង្រៀននយោបាយដល់ប្រជាជនក្នុងភូមិ

គាត ស្រីឡែន



សេង សឿ ភេទស្រី អាយុ៧៧ឆ្នាំ រស់នៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សេង សឿ ភេទស្រី អាយុ៧៧ឆ្នាំ កើតនៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម ។ ខ្ញុំមានឪពុកឈ្មោះ សេង ម្តាយឈ្មោះ សួក និងមានបងប្អូនបង្កើតចំនួន២នាក់ ហើយខ្ញុំគឺជាកូនពៅ។ ខ្ញុំមានប្តីឈ្មោះ អេក អាន និងមានកូនចំនួន១០នាក់ ប៉ុន្តែកូនខ្ញុំស្លាប់អស់ចំនួន៣នាក់។ កាលពីអាយុ៧ឆ្នាំ ខ្ញុំចូលរៀននៅសាលាវត្តរំចេកដែលស្ថិតនៅមុខផ្ទះរបស់ខ្ញុំ។ ក្មេងៗក្នុងភូមិជាច្រើននាក់ទៀតក៏បានចូលរៀននៅសាលានេះដែរ ដោយមានព្រះសង្ឃពីរអង្គគឺជាអ្នកបង្រៀន។ ខ្ញុំរៀនជាមួយព្រះសង្ឃ ពេលចូលខែពិសាខ ដល់ខែចេញពិសាខព្រះសង្ឃមិនគង់នៅវត្តទេ។

ក្រោយមក ខ្ញុំឈប់រៀននិងរៀបការជាមួយប្តីរបស់ខ្ញុំគឺជាអ្នកភូមិជាមួយគ្នា។ ឪពុកម្តាយខ្ញុំធ្វើស្រែចម្ការ និងរកជ័រ ហើយដឹកតាមរទេះក្របីយកទៅលក់នៅឆ្លូង។ នៅតាមផ្លូវមានចោរច្រើនណាស់។ ឪពុករបស់ខ្ញុំត្រូវចោរប្លន់ និងកាប់គាត់បែកក្បាល ដើម្បីប្លន់យកក្របី។ ប្រជាជនមានការខ្លាចរអាចោរប្លន់ទាំងនោះណាស់។

នៅឆ្នាំ១៩៧០ ខ្ញុំមានកូន២នាក់ ពេលនោះខ្ញុំឮឪពុករបស់ខ្ញុំនិយាយថា មានបាតុកម្ម។ ខណៈនោះនៅក្នុងភូមិរំចេកក៏មានវៀតកុង ឬយួនខាងជើងចូលមកដែលនាំមានការទម្លាក់គ្រាប់បែក។ ខ្ញុំនិងគ្រួសាររត់ចូលរណ្តៅត្រង់សេ ព្រោះខ្លាចគ្រាប់ធ្លាក់ចំ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមជម្លៀសប្រជាជនថ្មីជាច្រើនឲ្យមករស់នៅភូមិរបស់ខ្ញុំ។ ខ្មែរក្រហមបង្កើតជាសហករណ៍ដាក់ស្រូវ អង្ករ ជាទ្រព្យសម្បត្តិរួម។ ប្រជាជនដែលទើបជម្លៀសមក ខ្មែរក្រហមបានឲ្យរស់នៅតាមផ្ទះប្រជាជនមូលដ្ឋានដោយក្នុងមួយផ្ទះមានប្រជាជនថ្មីចំនួន២ទៅ៣នាក់ ឬ៥នាក់។ ក្រោយមកខ្មែរក្រហមបានប្រមូលប្រជាជនថ្មីទាំងអស់ឲ្យទៅរស់នៅដាច់ដោយឡែកនៅចុងភូមិ។ ប្រជាជនថ្មីជាច្រើននាក់បានស្លាប់ដោយសារជំងឺ ចំណែកអ្នកចេះដឹង, គ្រូបង្រៀន, នាយទាហាន គឺខ្មែរក្រហមហៅយកទៅរៀនសូត្រ ហើយមិនឃើញត្រឡប់មកវិញទេ។

នៅពេលនោះ ខ្មែរក្រហមយកសាលារៀន

នៅក្នុងភូមិធ្វើជាពេទ្យបាយរួមៗ យុវជនយុវនារីត្រូវបានខ្មែរក្រហមបំបែកចេញពីឪពុកម្ដាយ ហើយខ្ញុំត្រូវខ្មែរក្រហមចាត់តាំងឲ្យបង្រៀនពីនយោបាយ ពីរបៀបធ្វើការងារស្រែចម្ការ និងដាំដុះស្រូវដល់ប្រជាជនក្នុងភូមិៗ បន្ទាប់មកខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការងារផ្សេងៗ ដូចជា ដាំបាយ ចងចន្លុះ ទុកដុតបំភ្លឺ កាប់រំពេកធ្វើកន្ទេល និងដកស្ទូងស្រូវៗ ខ្ញុំទទួលបានរបបអង្ករមួយកំប៉ុងក្នុងមួយថ្ងៃ ព្រោះកាលនោះខ្ញុំមានកូនខ្ចីៗ ចំណែកប្ដីរបស់ខ្ញុំធ្វើជាប្រធានកងតូច និងជាមេសហករណ៍ដែលទទួលការងារអ្នកផ្គត់ផ្គង់របបអាហារដល់ប្រជាជននៅក្នុងភូមិៗ

នៅឆ្នាំ១៩៧៨ កម្មាភិបាល និងយោធាភូមិភាគនិរតីចូលមកចាប់កម្មាភិបាលនៅខាងបូព៌ា ប៉ុន្តែសំណាងល្អប្ដីរបស់ខ្ញុំរួចខ្លួនដោយសារប្រជាជនជួយលាក់ប្រវត្តិរូបព្រោះប្ដីរបស់ខ្ញុំចិត្តល្អ ហើយប្រជាជនស្រឡាញ់រាប់អានគាត់ៗ ពេលនោះខ្ញុំបានរត់ទៅនៅខាងខ្នងក្រពើអស់រយៈពេល១ខែ ទើបកងទ័ពវៀតណាមយកឡានមកទទួលខ្ញុំនិងអ្នកភូមិផ្សេងទៀតទៅរស់នៅភ្នំជើងអណ្ដែងៗ វៀតណាមបើកអង្ករ និង ពោតសំឡីឲ្យខ្ញុំហូបៗ បន្ទាប់មក ខ្ញុំនាំកូនត្រឡប់មកស្រុកវិញ ប៉ុន្តែវៀតណាមិនទាន់ឲ្យមកទេ ដូច្នេះខ្ញុំក៏លួចរត់ចេញមកៗ ខ្ញុំមករស់នៅមេមត់បានរយៈពេល១ខែ ព្រោះមេភូមិប្រាប់មិនឲ្យត្រឡប់មករស់នៅក្នុងភូមិភ្លាមទេ ព្រោះខ្លាចជាន់មីនដែលដោះមិនទាន់អស់ៗ មួយរយៈក្រោយមក ខ្ញុំក៏ត្រឡប់មកដល់ភូមិរំចេកវិញ ប៉ុន្តែផ្ទះរបស់ខ្ញុំមិនមានសម្ភារឆ្នាំង ចាន នៅសេសសល់ឡើយ គឺនៅតែសម្បកផ្ទះ ចំណែកប្រជាជនក៏មិនរស់នៅក្នុងភូមិច្រើនដែរ ក្រោយមកទើបមានប្រជាជនមករស់នៅ និងប្រកបរបររកស៊ីៗ



រណ្ដៅសាកសពរួមដែលកងទ័ពមជ្ឈិមរបស់ខ្មែរក្រហមសម្លាប់អតីតកម្មាភិបាលថ្នាក់ភូមិ និងឃុំ ក្នុងឃុំរំចេក ស្រុកមេមត់ តំបន់២១ ភូមិភាគបូព៌ាចំនួន៧៥នាក់នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផន ភឿន ៖ កងចល័តជីកប្រឡាយ និងខាយថ្ម

***សូ ហាន់***



ផន ភឿន រស់នៅភូមិឫស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ផន ភឿន ភេទប្រុស អាយុ៧៨ឆ្នាំ រស់នៅភូមិឫស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ នុត ផន និងម្តាយឈ្មោះ នួន នឹម។ នៅអាយុ១២ឆ្នាំ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាវត្តសំរោង។ ក្រោយពីបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា ខ្ញុំមិនបានបន្តការសិក្សានៅសាលាទៀតទេ។ ខ្ញុំចូលរៀនខាងធម៌វិន័យព្រះពុទ្ធសាសនាជាមួយលោកគ្រូ សំ, គ្រូអោក និងគ្រូចែម។ ក្រោយមកខ្ញុំទៅបួសរៀននៅវត្តសំរោង វត្តបានរយ:ពេល១ឆ្នាំ ក៏លាចាកសិក្ខាបទវិញ។ ក្រោយពីលាចាកសិក្ខាបទ ខ្ញុំមករស់នៅជាមួយឪពុកម្តាយនៅក្នុងភូមិឫស្សីសាញ់។ ក្រោយមកឪពុកម្តាយខ្ញុំបានរៀបការឲ្យខ្ញុំជាមួយឈ្មោះ កៅ នាថ។ បន្ទាប់ពីរៀបការរួច យើងមានកូនចំនួន៩នាក់ ក្នុងនោះស្រីចំនួន៥នាក់។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ។ ខ្ញុំឃើញប្រជាជនជាច្រើននាំគ្នាធ្វើបាតុកម្មទាមទារអំណាចថ្វាយសម្តេចព្រះ នរោត្តម សីហនុ និងយាងសម្តេចមកដឹកនាំប្រទេសវិញ។ មិនយូរប៉ុន្មាន ខ្ញុំឃើញមានការទម្លាក់គ្រាប់បែកបណ្តាលឲ្យការរស់នៅរបស់ខ្ញុំជួបការលំបាកយ៉ាងខ្លាំង ព្រោះត្រូវរត់គេចពីការទម្លាក់គ្រាប់បែក ហើយចូលពួននៅក្នុងត្រង់សេ (លេណដ្ឋាន) ជាញឹកញាប់។ ជាមួយគ្នានោះ ខ្ញុំឃើញវត្តមានពួកវៀតកុង (ទាហានវៀតណាមខាងត្បូង) ចូលមករស់នៅក្នុងភូមិឫស្សីសាញ់ ធ្វើឲ្យប្រជាជនមានការភ័យខ្លាចយ៉ាងខ្លាំង។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ ខ្ញុំឃើញប្រជាជនថ្មីជាច្រើនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញឲ្យមករស់នៅតាមទីជនបទ។ ពេលនោះខ្ញុំមិនសូវបានរស់នៅក្នុងភូមិទេ ព្រោះអង្គការបាត់តាំងខ្ញុំឲ្យទៅជីកប្រឡាយ នៅស្រម៉រ។ ពេលការងារនៅស្រម៉រត្រូវបានបញ្ចប់ អង្គការបាន

ចាត់ខ្ញុំឲ្យទៅធ្វើការនៅព្រៃកូនបុស្សី និងនៅដំណាក់ក្រសាំងទៀត។ នៅពេលខ្ញុំធ្វើការងារនៅដំណាក់ក្រសាំងហើយរួចរាល់ ទើបខ្ញុំអាចត្រឡប់មករស់នៅជាមួយគ្រួសារបានរយៈពេលកន្លះខែ។ បន្ទាប់មក អង្គការបានចាត់ខ្ញុំឲ្យទៅដឹកប្រឡាយ និងវាយថ្មនៅថ្មពេជ្រ ក្នុងខេត្តកំពង់ចាម។ នៅពេលខ្ញុំធ្វើការនៅថ្មពេជ្រ ខ្ញុំបានហូបបាយស្រួយ មិនខ្វះខាតដូចរស់នៅក្នុងភូមិបុស្សីសាញ់ទេ ដែលកាលនោះប្រធានកងឲ្យហូបតែបបរប៉ុណ្ណោះ។ នៅថ្ងៃខ្លះ អង្គការបានរៀបចំឲ្យមានកម្មវិធីសម្តែងសិល្បៈដើម្បីឲ្យប្រជាជនមើលកម្សាន្ត។

នៅពេលបញ្ចប់ការងារវាយថ្មនៅកំពង់ចាម ខ្ញុំបានមករស់នៅក្នុងភូមិបុស្សីសាញ់វិញ។ នៅពេលនោះ អង្គការចាត់តាំងខ្ញុំឲ្យទៅធ្វើស្រែចម្ការដូចប្រជាជនដទៃទៀតនៅក្នុងភូមិដែរ។ ជារឿយៗ អង្គការបានយកមនុស្សទៅសម្លាប់នៅលើទួលពោធិ៍អង្អែរ ធ្វើឲ្យខ្ញុំកាន់តែខិតខំធ្វើការងារទៅតាមផែនការ ព្រោះខ្លាចអង្គការបញ្ជូនទៅរៀនសូត្រ។

នៅចុងឆ្នាំ១៩៧៨ ប្រជាជននៅក្នុងភូមិបុស្សីសាញ់ជាច្រើនគ្រួសារ ត្រូវបានអង្គការជម្លៀសឲ្យទៅរស់នៅខេត្តពោធិ៍សាត់។ កាលនោះខ្ញុំបានបររទេះជូនក្រុមគ្រួសារជម្លៀសទាំងនោះទៅអ្នកលឿង។ ក្រោយពីជូនក្រុមគ្រួសារជម្លៀសទាំងនោះទៅដល់អ្នកលឿងហើយ ខ្ញុំក៏បររទេះគោត្រឡប់មកភូមិបុស្សីសាញ់វិញ។ ពេលមកដល់ភូមិ ខ្ញុំឃើញវត្តមានកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (កងទ័ពរំដោះ) ចូលមកក្នុងភូមិ ចំណែកប្រជាជនមួយចំនួនត្រូវបានអង្គការជម្លៀសចេញពីភូមិបុស្សីសាញ់ទៅទិសខាងលិចវិញ។

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំក៏ជួបជុំជាមួយគ្រួសារឡើងវិញ។ ចាប់តាំងពីឆ្នាំ១៩៨០មក ខ្ញុំរកស៊ីដឹកជ្រូកយកទៅលក់នៅតាមព្រំដែនវៀតណាម និងនៅខេត្តបាត់ដំបងទើបធ្វើឲ្យជីវភាពរស់នៅរបស់គ្រួសារខ្ញុំបានប្រសើរឡើង និងមានហូបចុកគ្រប់គ្រាន់។ ដោយសារការខិតខំប្រឹងប្រែងក្នុងការរកស៊ីទើបធ្វើឲ្យខ្ញុំនិងគ្រួសារមានជីវភាពសមរម្យមិនលំបាកដូចកាលមុនទៀត។




ផន ភឿន កំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាស ផាត ៖ កម្មករស្រែអំបិលកែប និងកំពត

*រឹម ស្រីស្រស់*



មាស ផាត អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មាស ផាត អាយុ៦៧ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការ មានស្រុកកំណើតនៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំនេះដដែល។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ វីង និងម្តាយឈ្មោះ តន់ សុន និងមានបងប្អូន៨នាក់ (ស្រី៥នាក់) ហើយខ្ញុំគឺជាកូនទី៣ក្នុងគ្រួសារ។ បងប្អូនរបស់ខ្ញុំស្លាប់អស់៣នាក់។

ខ្ញុំរៀនត្រឹមថ្នាក់ទី១០ ពីសង្គមចាស់នៅសាលាភូមិដើមបេង រួចក៏ឈប់រៀន ដើម្បីមកជួយធ្វើស្រែឪពុកម្តាយ និងជួយមើលថែប្អូនៗ។ ឪពុកខ្ញុំគឺជាអ្នកឡើងត្នោត ហើយម្តាយរបស់ខ្ញុំធ្វើស្រែចម្ការ។ ក្រោយមកឪពុករបស់ខ្ញុំបានធ្លាក់ពីលើដើមត្នោត បណ្តាលឲ្យគាត់ពិការធ្វើការងារ មិនកើតឡើយ។ ម្តាយរបស់ខ្ញុំបានខិតខំរកស៊ីចិញ្ចឹមកូនទាំងអស់នាពេលនោះ។

នៅឆ្នាំ១៩៧០ មានព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកនៅតាមជួរភ្នំក្បែរផ្ទះរបស់ខ្ញុំ។ ខ្ញុំ និងអ្នកភូមិដទៃទៀតរស់នៅមិនសូវសុខឡើយ។ គ្រួសារខ្លះបានរត់គេចពីការទម្លាក់គ្រាប់បែកនេះ និងមិនដែលឃើញវិលត្រឡប់មកស្រុកកំណើតវិញឡើយ។ ប្រជាជនខ្លះទៀតនៅសម្ងំលាក់ខ្លួននៅក្នុងត្រង់សេក្បែរផ្ទះនៅពេលមានការទម្លាក់គ្រាប់បែកម្តងៗ។ ខ្ញុំមិនរត់គេចទៅណាទេ គឺ ស៊ូទ្រាំរស់នៅក្នុងស្រុកកំណើតរហូតដល់ឆ្នាំ១៩៧៥។

នៅពេលរបបខ្មែរក្រហមឡើងកាន់កាប់អំណាច ខ្ញុំព្រមទាំងគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅភូមិភ្នំត្នោត ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត។ នៅទីនោះ ខ្មែរក្រហមប្រើខ្ញុំឲ្យជីកប្រឡាយ កាប់ព្រៃដាំដំឡូង និងដាំពោត។ បន្ទាប់មកទៀត ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យមកនៅភូមិខ្វាវ ឃុំតាអូរ ស្រុកគិរីវង់វិញ និងចាត់តាំងខ្ញុំឲ្យធ្វើស្រែជាមួយសហករណ៍នៅទីនោះ។ ខ្ញុំត្រូវមកហូបរួមនៅរោងបាយ ប៉ុន្តែហូបមិនបានគ្រប់គ្រាន់ទេ។ ខ្ញុំមិនមានអំបិលហូបទេ ពេលខ្លះខ្ញុំយកដីដំបូកមកស្ងោររម្ងាស់ ហើយយកទឹកដែលបានពីការស្ងោររម្ងាស់នេះទៅស្លហូប ព្រោះដីដំបូកមានជាតិប្រៃតិចៗ។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវខ្មែរក្រហមជម្លៀសម្តង

ទៀតឲ្យទៅនៅអង្គភាពស្រែអំបិល។ លើកនេះ ខ្ញុំទៅតែម្នាក់ឯង ចោលម្ដាយរបស់ខ្ញុំនៅភូមិ។ អង្គភាពនេះ មានមនុស្សបីពាន់នាក់សុទ្ធតែស្រីទាំងអស់។ នៅរដូវប្រាំង ខ្ញុំនិងអ្នកឯទៀតនៅក្នុងអង្គភាពធ្វើស្រែអំបិល។ ដល់រដូវវស្សា ខ្ញុំប្ដូរទៅធ្វើចម្ការ គឺ ដាំពោតនិងដាំដំឡូង។ ខ្ញុំធ្វើជាកម្មករស្រែអំបិលនៅកែបបានរយៈពេល១ឆ្នាំ ក៏ប្ដូរទៅធ្វើនៅអង្គភាពស្រែអំបិលខេត្តកំពតវិញ។ នៅឆ្នាំ១៩៧៩ ខ្ញុំនិងអ្នកធ្វើការនៅក្នុងអង្គភាពបានរត់ភៀសខ្លួនទៅកាន់ព្រំដែនថៃកាត់តាមភ្នំឱរ៉ាល់ លាច និងកន្លែងជាច្រើនទៀតដែលខ្ញុំមិនស្គាល់។

នៅតាមផ្លូវ ខ្ញុំឃើញមនុស្សស្លាប់ច្រើននិងអាណោចអាធ័មបំផុត។ ខ្ញុំមិនមានបាយហូបទេ ដូច្នេះខ្ញុំនិងអ្នករួមដំណើរនាំគ្នាដើរជីកដំឡូងហាលទុកសម្រាប់ធ្វើស្បៀងពេលធ្វើដំណើរតាមផ្លូវ។ បន្ទាប់មកខ្ញុំជួបយោធាខ្មែរក្រហម ហើយយោធាទាំងនោះបាននាំខ្ញុំទៅកាន់ព្រំដែនថៃតាមផ្លូវសំឡូត។ ទៅដល់ព្រំដែន អង្គភាពរបស់ខ្ញុំនៅសល់មនុស្សតែពីរនាក់ប៉ុណ្ណោះ គឺខ្ញុំ និងមិត្តនារីម្នាក់ទៀត។ ចំណែកអ្នកដទៃទៀតបានស្លាប់តាមផ្លូវអស់ហើយ។ នៅព្រំដែន ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ពេលអ៊ុនតាក់ចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៩៣ ទើបខ្ញុំបានវិលត្រឡប់មកស្រុកកំណើតវិញ។ មកដល់ស្រុកកំណើត មេឃុំបានចែកដីឲ្យខ្ញុំធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ ប៉ុន្តែខ្ញុំសោកស្ដាយណាស់ដែលខ្ញុំមិនបានជួបមុខឪពុកម្ដាយខ្ញុំ ព្រោះអ្នកទាំងពីរបានស្លាប់នៅឆ្នាំ១៩៧៩ ដោយសារជំងឺ។



ក្រុមអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ សម្ភាសន៍មាស ផាត អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រស់ ទូច ៖ អតីតប្រធានក្រសួងវប្បធម៌

## ភូមិភាគបូព៌ាដែលបានចូលរួមប្រជុំជាមួយ សោ ភឹម

ថុន ស្រីពេជ្រ



រស់ ទូច ភេទប្រុស កើតនៅឆ្នាំ១៩៤១ សព្វថ្ងៃរស់នៅភូមិឫស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ថិតនៅក្រោមផ្ទះដែលមានដំបូលប្រក់ក្បឿងតូចល្មម ក្នុងសម្លៀកបំពាក់អាវដៃខ្លីពណ៌ស និងខោសាច់ក្រណាត់ពណ៌ក្រម៉ៅ រស់ ទូច ភេទប្រុស កើតនៅឆ្នាំ១៩៨១ រស់នៅភូមិឫស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង បានផ្តល់បទសម្ភាសន៍មកកាន់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាថា នៅឆ្នាំ១៩៧៦ មុនពេលអង្គការ (ខ្មែរក្រហម) ចាប់ផ្តើមបង្កើតសហករណ៍កម្រិតខ្ពស់ អង្គការស្នើខ្ញុំឲ្យទៅរៀនអំពីសហករណ៍កម្រិតខ្ពស់អស់រយៈពេល៣ខែ មុននឹងផែនការទាំងនោះត្រូវបានដាក់ចេញមកអនុវត្តនៅតាមភូមិស្រុកៗ ក្រោយរៀនចប់ អង្គការឃើញថា ខ្ញុំគឺជាមនុស្សដែលមានចំណេះដឹង និងអាចទុកចិត្តបានក៏ចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានក្រសួងវប្បធម៌នៅឆ្នាំ១៩៧៦។

នៅឆ្នាំ១៩៧៨ ខ្ញុំនិងកម្មាភិបាលគ្រប់ជាន់ថ្នាក់ព្រមទាំងគណៈស្រុកជាច្រើនមកពីតំបន់និងភូមិភាគបូព៌ាទាំងមូល បានទៅចូលរួមការប្រជុំដ៏ធំមួយតាមការកោះហៅរបស់ សោ ភឹម លេខាភូមិភាគបូព៌ា ដែលមានទីតាំងស្ថិតនៅភូមិស្វាយរមាស ក្រុងព្រៃវែង ជាមួយនឹងសម្លៀកបំពាក់ថ្មី និងក្រមាបង់កថ្មី ដែលអង្គការបានចែកឲ្យខ្ញុំ និងគាត់ ដែលជាចៅហ្វាយស្រុកមេសាង។ ខ្ញុំបានធ្វើដំណើរមកប្រជុំដោយជិះរទេះសេះ រីឯ សោ ភឹម បានជិះឡានអាកាត់សង់ត្រេដើម្បីមកប្រជុំ។ ឡានរបស់ សោ ភឹម បានបញ្ឆេះចោលរហូត ព្រោះគាត់ដឹងថាការមកប្រជុំនេះនឹងមានសភាពការណ៍មិនល្អឡើយ។ ប៉ុន្តែទោះយ៉ាងណា ការប្រជុំនេះគឺបានធ្វើឡើងដោយបើកចំហព្រមទាំងនិយាយវាយប្រហារដល់របបដឹកនាំរបស់ ប៉ុល ពត ថែមទៀត។

នៅក្នុងអង្គប្រជុំ សោ ភឹម បានលើកឡើងថា ការអនុវត្តនូវរបបសព្វថ្ងៃនេះ គឺពុំត្រឹមត្រូវនិងពុំដូចអ្វីដែលគាត់ចង់បានឡើយ។ ប្រជាជនទទួលបានរបបអាហារមិនគ្រប់គ្រាន់ ធ្វើការច្រើន ប៉ុន្តែបានហូបតិច ពេលឈឺមិនមានថ្នាំសង្កូវដើម្បីព្យាបាល រីឯសម្លៀកបំពាក់ក៏មិនមានគ្រប់គ្រាន់។ ដូច្នេះរបបនេះមិនល្អទេ ហើយមានប្រជាជនច្រើនណាស់ដែលបានស្លាប់។ យើងម្នាក់ៗ ត្រូវមានវិចារណញ្ញាណ គិតឲ្យបានវែងឆ្ងាយ។ បន្ទាប់មក សោ ភឹម ក៏បានស្រែកនូវសុភាសិតដៀមដាមទៅកាន់របបដឹកនាំរបស់ ប៉ុល ពត នូវសុភាសិតមួយឃ្លាថា «ជ័យយោ មហារុងរឿង រុះផ្ទះ

ក្បឿង ធ្វើផ្ទះស្លឹក ជ័យយោម ហាសន្ទឹក រុះផ្ទះស្លឹកធ្វើទ្រុងជ្រូក ជ័យយោម ហាទុក្ខសោក រុះទ្រុងជ្រូកធ្វើឈ្នាងនង្គ័ល ជ័យយោម ហាដោះទាល់ យកឈ្នាងនង្គ័លទៅដុតនឹងចង្ក្រាន»។ សុភាសិត ត្រូវបានស្រែកដំណាលគ្នាពេញទាំងសាលប្រជុំ។ ការប្រជុំនេះអាចថាជាការប្រជុំលើកចុងក្រោយរបស់ សោ ភឹម។ មុននឹងមកប្រជុំនេះ សោ ភឹម បានត្រៀមកម្លាំងទុករួចជាស្រេច ប្រសិនបើកើតសភាពការណ៍មិនស្រួល។

ពេលចប់ប្រជុំ សោ ភឹម ក៏បានចាប់ដៃចៅហ្វាយស្រុកនានា ហើយនិយាយពាក្យផ្តាំផ្ញើបន្តិចបន្តួច រួចគាត់ក៏ត្រឡប់ទៅវិញ។ ខ្ញុំគិតថាសភាពការណ៍ដូចជាមិនសូវស្រួល ចំពោះការប្រជុំដោយបើកចំហរបែបនេះ ហើយ ៣ថ្ងៃ ក្រោយមក អង្គការបានតាមចាប់ខ្លួន សោ ភឹម ដែលធ្វើឲ្យស្ថានការណ៍កាន់តែយ៉ាប់យ៉ឺន។

អ្នកដែលមានវត្តមាននៅក្នុងកម្មវិធីប្រជុំទាំងប៉ុន្មាន ភាគច្រើនត្រូវអង្គការហៅទៅរៀនសូត្រជាបន្តបន្ទាប់ ហើយមិនដែលឃើញត្រឡប់មកវិញទេ។ អ្នកដែលខ្ញុំស្គាល់មាន តា ហ៊ាន, តាម៉ន គឺជាមេឃុំ, តាជ្រង គឺជាគណៈឃុំ ត្រូវអង្គការយកទៅសម្លាប់ទាំងអស់ នៅរស់តែ សឿន ដែលកាន់ខាងក្រសួងកសិកម្ម។ បន្ទាប់ពីប្រធានតំបន់ត្រូវចាប់ខ្លួន សួរចម្លើយ និងសម្លាប់ និងការស្លាប់របស់ សោ ភឹម នៅក្នុងភូមិឃុំស្រុកខេត្តព្រៃវែងទាំងមូលត្រូវផ្លាស់មេដឹកនាំថ្មី ហើយជំនួសដោយកម្មាភិបាល និងយោធាមកពីភូមិភាគនិរតី។ កម្មាភិបាលនិងយោធាមកពីភូមិភាគនិរតីបានគំរាមឲ្យអ្នកដែលនៅក្រោមបង្គាប់ សោ ភឹម ទាំងអស់ទម្លាក់អាវុធចុះហើយព្រមប្រគល់ខ្លួនឲ្យអង្គការ ដោយមិនមានសិទ្ធិតវ៉ា ឬបញ្ចេញមតិទាំងអស់។ ចំណែកខ្ញុំ ត្រូវបានខ្មែរក្រហមចោទប្រកាន់ថា គឺជា កា.សេ.បេ ក្បត់នឹងអង្គការ។ ជាសំណាងរបស់ខ្ញុំពេលនោះ ខ្ញុំមិនត្រូវខ្មែរក្រហមយកទៅសម្លាប់ ហើយអាចរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ។

ខ្ញុំមិនពេញចិត្តរបបប៉ុល ពត ដែលបានប្រព្រឹត្តមកលើប្រជាជនទេ។ របបនេះមិនឲ្យប្រជាជនហូបឆ្អែត មិនមានសម្លៀកបំពាក់ បិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ រឿងរ៉ាវទាំងអស់នេះក្មេងជំនាន់ក្រោយគួរចងចាំឲ្យច្បាស់ និងគិតពិចារណាទៅលើរបបនេះ តើសង្គមមួយណាល្អ និងសង្គមមួយណាមិនល្អ ជាពិសេសសូមកុំយកគំរូតាមរបបដឹកនាំខ្មែរក្រហម។ ខ្ញុំមិនចង់ឲ្យរបបនេះ វិលត្រឡប់មកវិញទេ។



រស់ ទូច ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ដេង ពងរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហ៊ុន សាន ៖ ឪពុកខ្ញុំកាន់សីល៨ ប្រធានកងប្រើគាត់ឱ្យធ្វើទ្រូងដាក់ត្រី

*សៀង កញ្ញា*




*ហ៊ុន សាន អាយុ៧២ឆ្នាំ រស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ហ៊ុន សាន អាយុ៧២ឆ្នាំ មានទីលំនៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ហ៊ុន ហ៊ុំ និងម្ដាយឈ្មោះ ម៉ី សុខ ព្រមទាំងមានបងប្អូនបង្កើតចំនួន៧ នាក់ ក្នុងនោះមានស្រី២នាក់ ហើយខ្ញុំគឺជាកូនទី២ក្នុងគ្រួសារ។

កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រជ្រៅជ្រះទេ ដោយសារមានប្អូនច្រើន ដូច្នេះខ្ញុំត្រូវឈប់រៀនដើម្បីរៀបចំបាយ ទឹកឲ្យប្អូនហូបបន្ទាប់ពីត្រឡប់មកពីសាលារៀន។ ប្អូនៗរបស់ខ្ញុំរៀនបានច្រើនជាងខ្ញុំ។ ខ្ញុំបានរៀបការនៅសម័យសង្គមរាស្ត្រនិយម។ ក្រោយមកខ្ញុំក៏មានផ្ទៃពោះ និងកើតបានកូនស្រីម្នាក់ ចំណែកប្ដីរបស់ខ្ញុំក៏ចាកចេញពីផ្ទះទៅមានប្រពន្ធថ្មីទុកឲ្យខ្ញុំចិញ្ចឹមកូនម្នាក់ឯង។

ចូលមកដល់របប លន់ នល់ ខ្ញុំបានបាត់បង់បងស្រីម្នាក់។ បងស្រីរបស់ខ្ញុំស្លាប់នៅពេលកំពុងមានការវាយប្រយុទ្ធគ្នា និងផ្លោងគ្រាប់ដាក់គ្នាទៅវិញទៅមក ហើយនៅពេលគាត់ចេញពីត្រង់សេ (លេណដ្ឋាន) មកខាងក្រៅ យន្តហោះបានទម្លាក់គ្រាប់បែកត្រូវចំគាត់បណ្ដាលឲ្យដាច់កស្លាប់ភ្លាមៗជាមួយកូនរបស់គាត់ដែលកំពុងឱបជាប់នឹងទ្រូង។ ខ្ញុំយំនិងស្ដាយបងស្រីខ្ញុំជាពន់ពេក។ ក្រោយមកខ្ញុំនិងគ្រួសារព្រមទាំងអ្នកភូមិមួយចំនួនបានភៀសខ្លួនចេញពីផ្ទះ អ្នកភូមិ

ខ្លះទៅនៅភ្នំពេញ អ្នកភូមិខ្លះទៀតទៅនៅស្រុកផ្សេងដែលខ្លួនគិតថាមានសុវត្ថិភាព។ ចំណែកគ្រួសារខ្ញុំបានភៀសខ្លួនទៅនៅពាមបួនក្នុងខេត្តឃ្លាំងប្រទេសវៀតណាម។ នៅទីនោះ វៀតណាម បានរាក់ទាក់ជាមួយជនភៀសខ្លួនខ្មែរ ហើយបានផ្តល់នូវអំណោយដូចជា អង្ករ ទឹកត្រី អំបិល និងម្ហូបអាហារផ្សេងទៀតដល់យើង។ វៀតណាមបានឲ្យយើងដាំសណ្តែកដីធ្វើចម្ការដើម្បីទុកជាស្បៀងសម្រាប់ហូបខ្លួនឯង។

នៅពេលដែលយោធាខ្មែរក្រហមវាយបែកភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមឃោសនាឲ្យត្រឡប់មករស់នៅស្រុកកំណើតវិញ។ នៅពេលនោះខ្មែរក្រហមបាននិយាយថា «បងប្អូនអើយមកនៅស្រុកកំណើតយើងវិញ នៅទីនេះសម្បូរហូប ហើយមិនបាច់យកអ្វីច្រើនមកតាមខ្លួនទេ»។ ខ្ញុំនិងគ្រួសារបានវិលត្រឡប់មកស្រុកកំណើតយើងវិញ ប៉ុន្តែបានខុសពីការរំពឹងទុករបស់យើង។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យនៅកងនារីច្រូតស្រូវ។ ពេលនោះ ខ្មែរក្រហមកំណត់ ដោយអ្នកណាច្រូតស្រូវលឿន ខ្មែរក្រហមឲ្យហូបបាយឆ្ងាញ់ ចំណែកឯអ្នកដែលច្រូតយឺតខ្មែរក្រហមឲ្យហូបបបររាវ។ សំណាងដែរ ខ្ញុំពូកែច្រូតស្រូវ ហើយខ្ញុំច្រូតលឿនណាស់ គឺបានលេខ១ រហូត។ ខ្ញុំបានបាយហូបគ្រប់គ្រាន់ ហើយនៅសល់ខ្លះខ្ញុំលួចលាក់យកមកឲ្យកូន និងម្តាយ។

កាលនោះខ្មែរក្រហមបែងចែកឲ្យម្តាយរបស់ខ្ញុំនៅកងផ្សេងពីខ្ញុំ។ ប្រធានកងបានប្រើម្តាយខ្ញុំឲ្យដកសណ្តែកដី ដាំល្ពៅ និងបន្លែផ្សេងៗទៀត។ កន្លែងដែលម្តាយខ្ញុំរស់នៅមិនមានអាហារហូបចុកគ្រប់គ្រាន់ទេ។ ចំណែកកូនរបស់ខ្ញុំរស់នៅ និងធ្វើការនៅក្នុងកងកុមារ។ ប្រធានកងប្រើកូនរបស់ខ្ញុំឲ្យរើសអាចម៍គោក្នុងមួយថ្ងៃឲ្យបាន ១០គីឡូ បើរើសមិនបានទេ ប្រធានកងមិនឲ្យហូបបាយទេ។ ខ្ញុំអាណិតកូនស្រីខ្ញុំណាស់។ រីឯឪពុកខ្ញុំនៅក្នុងកងតាតា ដូច្នេះប្រធានកងបានប្រើគាត់ឲ្យធ្វើឈ្នាង និងធ្វើទ្រូ សម្រាប់ដាក់ត្រី។ ខ្ញុំពិតជាអាណិតឪពុករបស់ខ្ញុំខ្លាំងណាស់ព្រោះគាត់បានកាន់សីល៨ ដល់មករបបខ្មែរក្រហម ប្រធានកងប្រើគាត់ឲ្យធ្វើការបែបហ្នឹង ប៉ុន្តែប្រសិនបើឪពុកខ្ញុំមិនធ្វើខ្មែរក្រហមនឹងសម្លាប់គាត់ចោល។ ចំណែកបងប្អូនខ្ញុំផ្សេងទៀតក៏មិនបាននៅជុំគ្នាជាមួយខ្ញុំដែរ គឺបែកទៅធ្វើការតាមកងរៀងខ្លួន។ ក្រោយមកខ្ញុំទទួលដំណឹងថាប្អូនប្រុសរបស់ខ្ញុំម្នាក់បានស្លាប់ដោយសារគេបំពុលថ្នាំ ហើយខ្ញុំក៏មិនបានដឹងថាហេតុអ្វីបានជាគេបំពុលប្អូនខ្ញុំដែរ។

មួយរយៈក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំ និងប្រជាជនទៅនៅភ្នំឪរ៉ាល់ ដោយបានប្រាប់ថានឹងឲ្យខ្ញុំហូបនំបញ្ចុកនៅទីនោះ ប៉ុន្តែតាមពិតជាកលល្បិចរបស់ខ្មែរក្រហម ដែលបានត្រៀមដាក់ថ្នាំសម្លាប់ខ្ញុំ និងប្រជាជន។ នៅពេលដែលខ្ញុំនិងប្រជាជនដើរទៅដល់ចង្កេះភ្នំឪរ៉ាល់ កងទ័ពវៀតណាមបានវាយចូលមករំដោះប្រជាជន ហើយប្រាប់ប្រជាជនឲ្យត្រឡប់មកស្រុកកំណើតវិញ។ ចំណែកយោធាខ្មែរក្រហមបានរត់គេចខ្លួនចូលទៅក្នុងព្រៃបាត់អស់។ ខ្ញុំនិងគ្រួសារនាំគ្នាមករស់នៅភូមិកំណើតវិញ។ ក្រោយពីរបបខ្មែរក្រហមដួលរលំម្តាយរបស់ខ្ញុំបានស្លាប់ ហើយរយៈពេល ១ខែបន្ទាប់មកឪពុករបស់ខ្ញុំក៏បានស្លាប់បន្តទៀត។ ខ្ញុំកំព្រាឪពុកម្តាយតាំងពីពេលនោះមក។ បន្ទាប់មក ខ្ញុំប្រកបរបរលក់តាប៉ែ និងបានយកក្មេងដែលកំព្រាឪពុកម្តាយចំនួន៥នាក់មកចិញ្ចឹម រហូតដល់កូនចិញ្ចឹមរបស់ខ្ញុំធំ និងមានប្តីប្រពន្ធរៀងៗខ្លួន។



ហ៊ុន សាន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ នៅអំឡុងពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ុក ឡាន ៖ កូនខ្ញុំធ្លាក់ទឹកប្រឡាយ ដោយសារខ្ញុំងងឹតមាន់

*រឹម ស្រីស្រស់*



អ៊ុក ឡាន អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ុក ឡាន អាយុ៧២ឆ្នាំ ប្រកបរបរកសិករធ្វើស្រែចម្ការ។ សព្វថ្ងៃខ្ញុំរស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ ជាមួយប្អូនរបស់ខ្ញុំ។ ខ្ញុំមានកូនប្រុស២នាក់ ប៉ុន្តែបានស្លាប់ម្នាក់កាលពីឆ្នាំ១៩៧២ ពេលអាយុបាន១ឆ្នាំ។

កាលពីវ័យកុមារភាពខ្ញុំបានរៀនដល់ត្រឹមថ្នាក់ទី៩ចាស់ ប៉ុន្តែដោយសារតែគ្រួសារមានជីវភាពក្រីក្រខ្វះខាត ទើបខ្ញុំឈប់រៀនប្រហែលជាអាយុ១២ឆ្នាំ ហើយរស់នៅជាមួយឪពុកម្តាយវិញ។ គ្រួសារខ្ញុំបានទៅចាប់ដីថ្មីនៅស្រុកកំពង់សិលា ហើយបានប្រកបរបរធ្វើស្រែចម្ការនៅទីនោះ។

បន្ទាប់មកនៅឆ្នាំ១៩៧០ ខ្ញុំបានរៀបការនៅអាយុប្រហែលជា២០ឆ្នាំជាមួយប្តីរបស់ខ្ញុំដែលគាត់ធ្វើទាហាន លន់ នល់ នៅកំពង់សិលា។ រយៈពេលប្រហែលជា១ឆ្នាំក្រោយមកក៏មានការវាយប្រយុទ្ធគ្នានៅបន្ទាយទាហាន ហើយខ្មែរក្រហមបានឡោមព័ទ្ធជុំវិញបន្ទាយនោះរយៈពេលកន្លះឆ្នាំ ធ្វើឲ្យការហូបចុកមានការលំបាកខ្លាំង ប៉ុន្តែក្រោយមកក៏មានយន្តហោះដឹកជំនួយមកទម្លាក់ស្បៀងឲ្យ។

នៅដើមឆ្នាំ១៩៧៥ អង្គភាពទ័ពបានបញ្ជូនប្តីរបស់ខ្ញុំឲ្យមកវាយតទល់ជាមួយខ្មែរក្រហមនៅកប់ស្រូវ ចំណែកខ្ញុំបានផ្លាស់មកនៅកំពង់សោម។ ខ្ញុំ

រស់នៅកំពង់សោមបានរយៈពេល២១ថ្ងៃ យោធាខ្មែរក្រហមក៏វាយបែកក្រុងកំពង់សោមៗ នៅពេលនោះ ខ្ញុំក៏ចាកចេញពីកំពង់សោម ហើយបានជួបប្តីនៅស្ពានត្រពាំងរពៅ។ បន្ទាប់មក យើងក៏នាំគ្នាត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែត្រូវបានយោធាខ្មែរក្រហមឃាត់ទុកនៅភូមិត្រយឹង ឃុំរាមអណ្តើក ស្រុកគិរីវង់ ខេត្តតាកែវ។ ដោយសារខ្ញុំគឺជាប្រជាជន១៧ មេសា ខ្មែរក្រហមចាត់តាំងប្តីខ្ញុំឲ្យភ្ជួរស្រែ ចំណែកខ្ញុំដកស្ទូង ដោយទុកកូនៗឲ្យយាយៗមើលថែនៅពេលថ្ងៃ ហើយពេលយប់ទើបខ្ញុំមកយកកូនទៅវិញ ចំណែកប្អូនៗរបស់ខ្ញុំនៅកងកុមារ។ ការហូបចុកមានការលំបាក ហើយមិនដែលបានហូបបាយទេ គឺហូបតែបបរប៉ុណ្ណោះ។ ពេលខែប្រាំង ប្រធានកងប្រើខ្ញុំឲ្យជីកប្រឡាយ និងរែកដីដំបូក។

នៅខែកក្កដា ឆ្នាំ១៩៧៧ ឈ្លបខ្មែរក្រហមបានយកប្តីខ្ញុំទៅវាយចោល ដោយស៊ើបដឹងថាប្តីរបស់ខ្ញុំធ្លាប់បានធ្វើទាហាន លន់ នល់។ កាលនោះប្រធានកងបញ្ជូនគាត់មកធ្វើស្រែនៅវត្តអង្គ ហើយគាត់ឈឺហើមដៃជើង។ បន្ទាប់មកប្រធានកងបញ្ជូនគាត់មកដេកពេទ្យ ហើយខ្មែរក្រហមក៏យកគាត់ទៅសម្លាប់ចោលនៅពេលនោះទៅ។ ចំណែកខ្ញុំមានការលំបាកយ៉ាងខ្លាំង ព្រោះកូនខ្ញុំឈឺ និងនៅរស់តែពីរនាក់កូននៅផ្ទះ។ ខ្ញុំមិនហ៊ាននិយាយអ្វីឡើយ ព្រោះខ្លាចឈ្លបខ្មែរក្រហមឮ ហើយយកទៅសម្លាប់ចោល។

នៅចុងឆ្នាំ១៩៧៧ ប្រធានកងបានបញ្ជូនខ្ញុំទៅភូមិទួលត្បែង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ដោយប្រើខ្ញុំឲ្យជីកប្រឡាយ រែកដីដំបូកដូចកាលពីខ្ញុំធ្វើការនៅឃុំរាមអណ្តើកដែរ។ ថ្ងៃមួយពេលដែលខ្ញុំជីកប្រឡាយកន្លែងនោះរួចហើយ ប្រធានបានរើកងរបស់ខ្ញុំទៅកន្លែងផ្សេងទាំងយប់ ដែលធ្វើឲ្យខ្ញុំមានការលំបាកយ៉ាងខ្លាំងដោយសារខ្ញុំមានជំងឺខ្វាក់មាន់មើលអ្វីមិនឃើញឡើយ។ ខ្ញុំបានដើរតាមស្នូរជើងរបស់សមាជិកកងផ្សេងទៀត ដោយរែកកូនផងនិងអីវ៉ាន់ផង ប៉ុន្តែទៅដល់កន្លែងមួយក៏ដាច់ខ្សែអំរែកធ្លាក់កូនចូលទៅក្នុងប្រឡាយ ទម្រាំខ្ញុំរាវរកកូនឃើញ។ នៅពេលនោះ មិនដែលបានហូបឆ្អែតទេ ទោះបីខ្ញុំខិតខំធ្វើការធ្ងន់យ៉ាងណាក៏ដោយ។ នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក ប្រធានកងមកបបួលខ្ញុំរត់ឡើងទៅភ្នំវល្លិ និងភ្នំស្រួច ប៉ុន្តែខ្ញុំឈឺជើងមិនបានទៅជាមួយប្រធានកងនោះបានឡើយ ក៏ខ្ញុំត្រឡប់មកក្រោយវិញ។ នៅតាមផ្លូវខ្ញុំឃើញសាកសពជាច្រើន បន្ទាប់មកក៏មកដល់ស្រុកកំណើតនិងជួបជុំបងប្អូនវិញ។



អ៊ុក ឡាន អាយុ៧២ឆ្នាំ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ក្រុមអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




អ៊ុក ឡាន ទទួលប្រអប់អនុស្សាវរីយ៍ពីក្រុមអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រជាជនភូមិសំរោងវត្តហូបចុកគ្រប់គ្រាន់ ដោយសារប្រធានសហករណ៍ចិត្តល្អ

ភា ស្រី



នី ធុច រស់នៅភូមិសំរោងវត្ត ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នី ធុច កើតនៅឆ្នាំ១៩៥០ នៅក្នុងភូមិសំរោងវត្ត ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ នី អឹម និងម្តាយឈ្មោះ កែវ ទួន។ ខ្ញុំមានបងប្អូនសរុបទាំងអស់៧ នាក់ ក្នុងនោះមានស្រី៣នាក់ ហើយបច្ចុប្បន្ននៅរស់តែ៤នាក់ប៉ុណ្ណោះ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ឪពុកម្តាយរបស់ខ្ញុំប្រកបរបរធ្វើស្រែ និងធ្វើនំលក់ដើម្បីផ្គត់ផ្គង់ជីវភាព។

នៅអាយុ១២ឆ្នាំ ខ្ញុំចូលរៀននៅសាលាក្នុងវត្តសំរោងវត្ត ជាមួយលោកគ្រូឈ្មោះ អោក ដែលជាព្រះសង្ឃ។ ក្រោយមកទៀត ខ្ញុំបន្តការសិក្សានៅអនុវិទ្យាល័យវត្តថ្មី ស្ថិតនៅម្តុំផ្សារស្មេហ៍ រហូតដល់ប្រឡងជាប់ចូលរៀននៅវិទ្យាល័យ។ ក្រោយមកដោយសារតែឪពុកម្តាយក្រីក្រគ្មានលទ្ធភាពបង់ថ្លៃសាលា ខ្ញុំបានឈប់រៀនរួចហើយត្រឡប់មកផ្ទះជួយរកស៊ីឪពុកម្តាយវិញ។ នៅក្នុងភូមិសំរោងវត្តខ្ញុំជួយបង្រៀនអនក្ខរកម្មចាស់ៗនៅក្នុងភូមិដែលមិនចេះអក្សរ និងធ្វើស្រែ។ នៅសម័យ លន់ នល់ នៅក្នុងភូមិសំរោងវត្តមានការទម្លាក់គ្រាប់បែកចំនួនពីរលើកគឺ លើកទី១) ទម្លាក់នៅផ្ទះរបស់លោកគ្រូ អោក អំឡុងពេលដែលចាស់ៗកំពុងរៀនអក្សរបណ្តាលឲ្យមនុស្សស្លាប់ចំនួន២នាក់ និងខូចខាតទ្រព្យសម្បត្តិរបស់ប្រជាជនជាច្រើន។ លើកទី២) ទម្លាក់នៅទួលប្រាសាទជិតភូមិសំរោងវត្ត ប៉ុន្តែមិនមានមនុស្សស្លាប់ទេ។

នៅដើមឆ្នាំ១៩៧៥ ខ្ញុំបានរៀបការជាមួយនារីម្នាក់នៅក្នុងភូមិដែលមានឈ្មោះថា មុជ ហេង។ ការរៀបការរបស់យើងគឺធ្វើឡើងតាមប្រពៃណីជាធម្មតា ព្រោះកាលនោះនៅមានប្រពៃណីនិងសាសនាសម្រាប់គោរពប្រតិបត្តិ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះ ខ្មែរក្រហមបានបញ្ជូនកងចល័តនារី និងកងចល័តបុរស រួមទាំងរូបខ្ញុំឲ្យទៅលើកប្រព័ន្ធភ្លឺស្រែចាប់ពីស្រុកកំចាយមារ រហូតមកដល់ស្រុកមេសាង ខេត្តព្រៃវែង។ ក្រោយបញ្ចប់ការលើកប្រព័ន្ធភ្លឺស្រែ ខ្ញុំបានត្រឡប់មករស់នៅជាមួយក្រុមគ្រួសារវិញ ហើយចាប់ផ្តើមចូលធ្វើការក្នុងក្រុមដាំងឈើ និងឡើងត្នោត។ នៅចុងឆ្នាំ១៩៧៥ អង្គការបានចាត់តាំងឲ្យក្រុម

របស់ខ្ញុំអាឈើធ្វើតុ ធ្វើកៅអី និងសង់រោងបាយសម្រាប់ហូបអាហាររួមគ្នា។

ចាប់តាំងពីចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ការងាររបស់ខ្ញុំគឺឡើងត្នោត ដាងឈើ និងធ្វើស្រែបន្តិចបន្តួចប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៦ ប្រជាជននៅក្នុងភូមិសំរោងវត្តចាប់ផ្តើមហូបបាយរួមគ្នា ដោយខ្មែរក្រហមបានបែងចែកប្រជាជនឲ្យទៅហូបអាហារតាមរោងបាយចំនួន ៤។ នៅក្នុងភូមិសំរោងវត្តមិនសូវលំបាកក្នុងការហូបចុកប៉ុន្មានទេ ព្រោះប្រធានសហករណ៍ឈ្មោះ រស់ មី តែងតែឲ្យប្រជាជនហូបបាយមួយឆ្អែត។ នៅក្រោមការគ្រប់គ្រងរបស់ មី គឺមិនបានធ្វើបាបប្រជាជនទេ ហើយប្រជាជននៅក្នុងភូមិជាច្រើននាក់គោរពស្រឡាញ់គាត់។ នៅអំឡុងពេលមានព្រឹត្តិការណ៍តាមចាប់ សោ ភឹម ប្រធានសហករណ៍នៅតាមភូមិផ្សេងៗមានការផ្លាស់ប្តូរ លើកលែងតែនៅភូមិសំរោងវត្តគឺនៅដដែល។ ចំណែកឯការបញ្ជូនប្រជាជនទៅខេត្តពោធិ៍សាត់ ដែលជាតំបន់ដីខ្លាញ់ គឺមានតែ៣គ្រួសារប៉ុណ្ណោះដែលត្រូវបានខ្មែរក្រហមជម្លៀសពីភូមិសំរោងវត្តទៅរស់នៅទីនោះ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមវាយចូលមក គ្រួសាររបស់ខ្ញុំរួមជាមួយប្រជាជននៅក្នុងភូមិសំរោងវត្តបានធ្វើដំណើររហូតដល់ភូមិព្រៃឃ្មុំស។ គ្រួសាររបស់ខ្ញុំបានស្នាក់នៅភូមិព្រៃឃ្មុំសរយៈពេល៣ថ្ងៃ ទើបត្រឡប់មកផ្ទះវិញ ព្រោះខ្ញុំឮដំណឹងថាមានការផ្ទុះអាវុធនៅអ្នកលឿង ហើយប្រទេសក៏ត្រូវបានរំដោះដែរ។ ក្រោយរបបខ្មែរក្រហមដួលរលំភ្លាម គ្រួសាររបស់ខ្ញុំចាប់ផ្តើមធ្វើស្រែ។ បន្ទាប់មក ខ្ញុំយកប្រាក់ដែលសន្សំបានទៅទិញម៉ូតូដើម្បីរត់ឌុប និងដឹកអីវ៉ាន់ពីផ្សារអ្នកលឿងយកមកលក់នៅក្នុងភូមិ។ សព្វថ្ងៃនេះ ខ្ញុំមានកូនសរុបទាំងអស់៦នាក់ ស្លាប់ម្នាក់ ហើយប្រពន្ធរបស់ខ្ញុំក៏ស្លាប់ចោលខ្ញុំដែរ។



សិស្សថ្នាក់បឋមសិក្សានៅក្នុងស្រុកមេសាងចេញពីរៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នួន អាត ៖ កាន់ម៉ាស៊ីនបូមទឹកដាក់ស្រូវប្រាំង ក្នុងរបបខ្មែរក្រហម

ភួង សុខថា



អ្នួន អាត អាយុ៦៦ឆ្នាំ គឺជាមេភូមិសំរោងវត្ត ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ្នួន អាត ភេទប្រុស អាយុ៦៦ឆ្នាំ។ សព្វថ្ងៃខ្ញុំមានតួនាទីជាមេភូមិ នៅភូមិសំរោងវត្ត ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ នៅក្នុងឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ធ្វើឲ្យមានសង្គ្រាមកើតឡើងយ៉ាងខ្លាំងនៅក្នុងភូមិសំរោងវត្ត។ នៅក្នុងឆ្នាំ១៩៧២ ខ្ញុំបួសជាព្រះសង្ឃនៅវត្តសំរោងវត្ត។ នៅឆ្នាំ១៩៧៤ ឈ្មោះ ឈឹម ផ្លៅន គឺជាមេកងចល័តបាននាំកូនទាហានចូលមកវាយរូបព្រះពុទ្ធបដិមាធ្វើពីស៊ីម៉ងត៍នៅក្នុងវត្តសំរោងវត្ត។

នៅឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចទាំងស្រុង ខ្ញុំនិងព្រះសង្ឃនៅវត្តសំរោងវត្តទាំងអស់ត្រូវបានផ្សឹកដោយបង្ខំ។ ក្រោយពីផ្សឹករួច កម្មាភិបាលខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យចូលក្នុងកងចល័ត ជីកប្រឡាយ និងធ្វើស្រែអស់រយៈពេល ៣ខែនៅស្រុកពញាក្រែក ទើបឲ្យខ្ញុំត្រឡប់មកស្រុកកំណើតនៅភូមិសំរោងវត្តវិញ។ ពេលមកដល់ស្រុកកំណើត ខ្ញុំឃើញប្រជាជននាំគ្នាទៅបោះឆ្នោតឲ្យសំ ហាន ឡើងធ្វើជាចៅហ្វាយស្រុក។ ការបោះឆ្នោតនេះរៀបចំធ្វើនៅភូមិទទឹង និងមានប្រជាជនប្រហែល

១០០នាក់ចូលរួមបោះឆ្នោត។ សំហាន បានធ្វើជាចៅហ្វាយស្រុករហូតដល់ឆ្នាំ១៩៧៨។

នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំរៀបការជាមួយប្រពន្ធរបស់ខ្ញុំសព្វថ្ងៃ ដែលត្រូវអង្គការរៀបចំឲ្យចំនួន៧០គូ ក្នុងពេលតែមួយ។ បន្ទាប់ពី ខ្ញុំបានរៀបការរួច កម្មាភិបាលខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិឲ្យទៅនៅម្តុំក្រុង ព្រៃវែង។ នៅពេលដែលខ្ញុំបានទៅដល់ក្រុងព្រៃវែង អង្គការចាត់តាំងឲ្យខ្ញុំកាន់ម៉ាស៊ីនបូមទឹកដាក់ស្រូវប្រាំង។

ខ្ញុំបូមទឹកដាក់ស្រូវប្រាំងរហូតដល់ដើមខែមករា ឆ្នាំ១៩៧៩ ខណៈដែលខ្មែរក្រហមកំពុងតែបញ្ជូនប្រជាជនទៅខេត្តភាគខាងលិច។ ខ្ញុំបានលួចរត់ត្រឡប់មកស្រុកកំណើតវិញ។ នៅពេលខ្ញុំត្រឡប់មកដល់ពាក់កណ្តាលផ្លូវ ចូលបន់ស្រន់នៅវត្តបារាយណ៍អណ្តែត សូមឲ្យវត្ថុស័ក្តិសិទ្ធិជួយខ្ញុំបានសុខសប្បាយ។ នៅតាមផ្លូវខ្ញុំរើសបានត្រាក់ដែលមានឈ្មោះ ចាន់ ស៊ី នៅក្នុងនោះដែរ ហើយខ្ញុំបានរើសយកមកអាន។ នៅក្នុងត្រាក់នោះបានសរសេរថា សូមឲ្យបងប្អូនទាំងអស់គ្នាត្រឡប់មកផ្ទះវិញ ប្រទេសយើងមានសន្តិភាពហើយ។ បងប្អូនអាចមករស់នៅផ្ទះសម្បែងរបស់ខ្លួនវិញបាន។ នៅពេលខ្ញុំត្រឡប់មកដល់ភូមិកំណើត ខ្ញុំឃើញអ្នកភូមិនាំគ្នាចូលរួមអបអរជ័យជម្នះលើរបបខ្មែរក្រហម និងមានការរាំច្រៀងយ៉ាងសប្បាយ។



អ្នូន អាត កំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# តក់ តុប ៖ ពិការជើងដោយសារជាន់មីន

***យន់ ឃីម***



*តក់ តុប រស់នៅភូមិទ័ពស្វាយ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប និង យន់ ឃីម អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តសៀមរាប។*
*( យន់ ឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា )*

ខ្ញុំឈ្មោះ តក់ តុប អាយុ៦១ឆ្នាំ គឺជាទាហានចូលនិវត្តន៍ មានស្រុកកំណើតនៅភូមិព្រៃក្រឡាញ់ ឃុំសែនសុខ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ បច្ចុប្បន្នខ្ញុំរស់នៅភូមិទ័ពស្វាយ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានឪពុកឈ្មោះ កុង តក់ និងម្ដាយឈ្មោះ ហ៊ាង តុម ប្រកបរបរធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ខ្ញុំមានប្រពន្ធឈ្មោះ ហាយ រុំ ប៉ុន្តែប្រពន្ធខ្ញុំបានស្លាប់កាលពីឆ្នាំ២០១៩ ដោយសារជំងឺ។ សព្វថ្ងៃ ខ្ញុំមានកូនចំនួន៤នាក់។

នៅរវាងពីឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៧៥ គ្រួសាររបស់ខ្ញុំនៅធ្វើស្រែចម្ការនៅក្នុងភូមិព្រៃក្រឡាញ់ ទោះពេលនោះមានភាពច្របូកច្របល់ពេញផ្ទៃប្រទេសក៏ដោយ។ ទន្ទឹមនឹងនោះ ក៏មានការទម្លាក់គ្រាប់បែកលើកងទ័ពវៀតណាមខាងជើង និងខ្មែរក្រហម ដែលបានចូលកាន់កាប់តាមភូមិឃុំដែលស្ថិតនៅក្បែរព្រៃភ្នំក្នុងប្រទេសកម្ពុជា។ ក្រៅពីការទម្លាក់គ្រាប់បែក ក៏មានការវាយប្រយុទ្ធគ្នារវាងទាហានលន់ នល់ និងកងទ័ពខ្មែរក្រហម ដែលបណ្ដាលឲ្យមានមនុស្សស្លាប់ និងរបួសជាច្រើន។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកក្នុងភូមិរបស់ខ្ញុំ ប៉ុន្តែមិនទាន់មានការបែងចែកប្រជាជនឲ្យចេញទៅធ្វើការតាមសហករណ៍ទេ គឺគ្រាន់តែចូលមកកាន់កាប់ និងបណ្ដេញទាហាន លន់ នល់ ចេញពីភូមិប៉ុណ្ណោះ។ ក្រោយពីខ្មែរក្រហមចូលកាន់កាប់ភូមិ

បានរយៈពេលមួយខែ ខ្មែរក្រហមចាប់ផ្ដើមចល័តអ្នកភូមិឲ្យទៅធ្វើការតាមសហករណ៍ផ្សេងៗ។ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅឃុំស្នួល ក្នុងស្រុកក្រឡាញ់ ដើម្បីធ្វើការងាររែកដី។ បន្ទាប់មក ខ្មែរក្រហមបញ្ជាខ្ញុំឲ្យដើរប្រមូលអាចម៍គោ លាមកមនុស្ស កាប់ដីដំបូក កាប់ដើមទន្ទ្រានខែត្រមកចិញ្ច្រាំឲ្យហ្មត់ហើយដាំទឹកវាឲ្យចូលគ្នា រួចហើយយកវាទៅហាលថ្ងៃឲ្យស្ងួត ទើបដឹកជញ្ជូនវាមកទុកក្នុងជម្រុក ដើម្បីទុកយកទៅធ្វើជីដាក់ស្រែ។

ខ្ញុំធ្វើការនៅឃុំស្នួលបានរយៈពេល៣ខែ ទើបខ្មែរក្រហមបញ្ជូនខ្ញុំត្រឡប់មកភូមិព្រៃក្រឡាញ់វិញ។ មួយរយៈក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំនិងគ្រួសារទៅកាន់ឃុំកំពង់ថ្កុវ ស្ថិតនៅស្រុកក្រឡាញ់ដដែល។ គ្រួសាររបស់ខ្ញុំបានដឹកចានឆ្នាំងតាមរទេះទៅឃុំកំពង់ថ្កុវ ព្រោះផ្ទះរបស់ខ្ញុំនៅក្នុងភូមិព្រៃក្រឡាញ់ ខ្មែរក្រហមទុកសម្រាប់ប្រជាជនដែលជម្លៀសមកថ្មី។ នៅពេលនោះស្ថិតនៅក្នុងរដូវវស្សា ដូច្នេះផ្លូវដែលខ្ញុំធ្វើដំណើរគឺសុទ្ធសឹងតែទឹកដែលមានជម្រៅត្រឹមចង្កេះរបស់ខ្ញុំ។ ឪពុករបស់ខ្ញុំគឺជាអ្នកបររទេះ ហើយខ្ញុំនិងបងប្អូននាំគ្នារុញរទេះពីក្រោយ។ រទេះដែលខ្ញុំនិងប្រជាជនបរទៅកាន់ឃុំកំពង់ថ្កុវមានប្រមាណ៤០រទេះគោ។ នៅក្នុងឃុំកំពង់ថ្កុវ មានផ្ទះធំៗជាច្រើនខ្នងដែលខ្មែរក្រហមត្រៀមទុកសម្រាប់ប្រជាជនដែលជម្លៀសទៅដល់ថ្មីស្នាក់នៅបណ្ដោះអាសន្ន។ គ្រួសារខ្ញុំបររទេះទៅដល់ភូមិថ្កុវនៅពេលយប់ទៅហើយ ដូច្នេះខ្មែរក្រហមបានឲ្យគ្រួសារខ្ញុំ និងគ្រួសារពីរទៀត ទៅស្នាក់នៅក្នុងផ្ទះមួយខ្នងដែលមានភាពស្ងាត់ជ្រងំ ដូចជាទីរហោឋាន។

នៅថ្ងៃបន្ទាប់ ខ្ញុំ និងគ្រួសារត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការនៅតាមកងផ្សេងៗគ្នា។ នៅពេលនោះខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យដើររើសស្រូវ និងគួរស្រូវដែលជ្រុះនៅតាមវាលស្រែយកមកទុក ដោយកំណត់១០ហិកតា មានគ្នា៤០នាក់ដើររើសគួរស្រូវឲ្យអស់ពីស្រែ បើរើសមិនអស់ត្រូវយកទៅកសាងបុយកទៅរៀនសូត្រ។ ចំពោះអ្នកដែលត្រូវខ្មែរក្រហមយកទៅកសាងបុរៀនសូត្រហើយមិនដែលឃើញត្រឡប់មកវិញទេ។ ដូច្នេះខ្ញុំខិតខំធ្វើការឲ្យហើយរួចរាល់តាមផែនការដែលខ្មែរក្រហមកំណត់។ នៅពេលខ្ញុំឈឺក្ដាត់ម្ដងៗ មិនមានថ្នាំសង្កូវសម្រាប់លេបទេ គឺមានតែសមាជិកក្នុងកងជួយរក្សានិងមើលថែគ្នា ដូចជា ជួយជប់ បុកោស ខ្យល់ឲ្យគ្នាទៅវិញទៅមក។ ខ្ញុំធ្វើការនៅឃុំកំពង់ថ្កុវរហូតដល់របបខ្មែរក្រហមដួលរលំនៅដើមខែមករា ឆ្នាំ១៩៧៩។ ពេលនោះគ្រួសារខ្ញុំនិងគ្រួសារមួយចំនួនទៀតមិនបានត្រឡប់មករស់នៅភូមិព្រៃក្រឡាញ់វិញទេ គឺបន្តស្នាក់នៅកំពង់ថ្កុវដដែល ដោយយើងប្រកបរបរធ្វើស្រែចម្ការ។

រហូតដល់ឆ្នាំ១៩៨២ ខ្ញុំចូលបម្រើកងទ័ពនៅខេត្តបន្ទាយមានជ័យ ហើយក្រោយមកត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅស្រុកចុងកាល់ ខេត្តឧត្ដរមានជ័យ។ ខ្ញុំចូលបម្រើកងទ័ពបានរយៈពេលបីឆ្នាំក៏ជាន់មីនផ្ទុះដាច់ជើងស្ដាំ នៅឆ្នាំ១៩៨៥។ ទោះបីខ្ញុំពិការជើង ក៏ខ្ញុំនៅបន្តធ្វើកងទ័ពរហូតដល់ឆ្នាំ២០០៨ ទើបខ្ញុំចូលនិវត្តន៍។ ក្រោយពេលចូលនិវត្តន៍ ទើបខ្ញុំរៀបការហើយមករស់នៅភូមិទ័ពស្វាយ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប រហូតមកដល់ពេលបច្ចុប្បន្ន។



ផ្ទះរបស់ តក់ តុប ស្ថិតនៅភូមិទ័ពស្វាយ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។
(យ៉ន់ ឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស៊ុន ហឿង ៖ អតីតកងចល័តនៅស្រុកវ៉ារិន

***យន់ ឃីម***



ស៊ុន ហឿង និងចៅ សព្វថ្ងៃរស់នៅភូមិពងទឹក ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។ (យន់ ឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស៊ុន ហឿង អាយុ ៦០ឆ្នាំ គឺជាកសិករ សព្វថ្ងៃរស់នៅភូមិពងទឹក ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ ហើយខ្ញុំគឺជាកូនទីមួយក្នុងចំណោមបងប្អូនប្រុសស្រី។ កាលពីដើមឪពុកម្តាយរបស់ខ្ញុំគឺជាកសិកររស់នៅភូមិពងទឹកចាស់ឃុំពាក់ស្នែង ស្រុកវ៉ារិនព្រោះកាលនោះមិនទាន់មានស្រុកអង្គរធំដូចសព្វថ្ងៃទេ។ ឪពុកម្តាយរបស់ខ្ញុំធ្វើស្រែចម្ការសម្រាប់ទុកហូបប្រចាំថ្ងៃ។

នៅអំឡុងឆ្នាំ១៩៧០គ្រួសាររបស់ខ្ញុំនៅតែធ្វើស្រែចម្ការដដែល ទោះបីមានការទម្លាក់គ្រាប់បែកពីសំណាក់កងទ័ពអាមេរិក និងទាហានលន់នល់ទៅលើខ្មែរក្រហម និងកងទ័ពវៀតណាមខាងជើងដែលបានលាក់ខ្លួនក្នុងព្រៃក៏ដោយ។ នៅពេលកំពុងធ្វើស្រែចម្ការហើយឮសំឡេងយន្តហោះនៅក្បែរភូមិ អ្នកភូមិចាប់ផ្តើមរត់បែកគ្នាទៅរកកន្លែងដែលមានសុវត្ថិភាពរៀងៗខ្លួន អ្នកភូមិខ្លះរត់ចូលគុម្ពព្រៃ ខ្លះរត់ចូលត្រង់សេ (លេណដ្ឋាន) ខ្លះក្រាបផ្ទាល់នឹងដីកុំឲ្យអំបែងគ្រាប់ខ្ទាតត្រូវ។ នៅពេលយន្តហោះមកទម្លាក់គ្រាប់បែកម្តងៗ ទាល់តែស៊ើបដំណឹងច្បាស់ថា វៀតណាមខាងជើង និងខ្មែរក្រហមស្នាក់នៅទីណាទើបយន្តហោះទៅទម្លាក់គ្រាប់បែកនៅតំបន់នោះ។ ពេលខ្លះអ្នកស៊ើបការណ៍ផ្តល់ដំណឹងទៅអ្នកបើកយន្តហោះខុស ព្រោះពេលអ្នកភូមិធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀត ក៏អ្នកស៊ើបការណ៍បានរាយការណ៍ថា ជា

វៀតណាមដែរ។ ដូច្នេះយន្តហោះខាង លន់ នល់ ក៏មកទម្លាក់គ្រាប់បែក។ ពេលខ្លះការទម្លាក់គ្រាប់នេះក៏បណ្តាលឲ្យកងទ័ពវៀតណាមខាងជើងស្លាប់ ចំណែកប្រជាជនស្លូតត្រង់ និងកងទ័ពខ្មែរក្រហមស្លាប់ច្រើនជាងគេ ទន្ទឹមនឹងនោះ គោ-ក្របី ជាច្រើនរបស់ប្រជាជនក៏ងាប់ដែរ។ ការទម្លាក់គ្រាប់បែកនេះបណ្តាលឲ្យប្រជាជនក្នុងភូមិមានការភ័យខ្លាច និងភៀសខ្លួនទៅរស់នៅភូមិឃុំផ្សេងៗ។

មកដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមចល័តខ្ញុំទៅ វ៉ារិន ដើម្បីធ្វើផ្លូវ រែកដី និងជីកប្រឡាយ ដើម្បីនាំទឹកទៅកាន់តំបន់នានាឲ្យមានទឹកប្រើប្រាស់គ្រប់គ្រាន់ និងអាចដាំដំណាំបានល្អ។ ខ្ញុំជីកប្រឡាយនៅវ៉ារិនរយៈពេល៨ខែ ខ្មែរក្រហមក៏បញ្ជូនខ្ញុំទៅកាន់ភូមិគោកស្រុក ដើម្បីលើកអាងស្តុកទឹកសម្រាប់ប្រើប្រាស់នៅរដូវប្រាំង។ ក្រោយពីលើកទំនប់ ខ្មែរក្រហមប្រើខ្ញុំឲ្យទៅធ្វើស្រែ ស្ទូងស្រូវ ច្រូតស្រូវ និងបោកស្រូវ។ នៅធ្វើស្រែអស់រយៈពេល២ឆ្នាំ វេងការលំបាកជាច្រើន ព្រោះពេលខ្លះខ្ញុំស្ទូងយឺត និងមិនត្រង់ជួរ ត្រូវបានប្រធានកងវាយបង្ខំខ្ញុំឲ្យស្ទូងឲ្យបានលឿន និងត្រង់ជួរ។ ថ្ងៃខ្លះខ្ញុំមិនទទួលបានអាហារហូបទេ ដោយសារខ្ញុំធ្វើខុស និងធ្វើមិនបានតាមតម្រូវការរបស់ខ្មែរក្រហម។

ក្រោយពីធ្វើការងារនៅស្រុកវ៉ារិនចប់ នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមបានបញ្ជូនខ្ញុំមកធ្វើការនៅភ្នំបាយដុះវិញ។ ស្រាប់តែពេលនោះ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមក ដូច្នេះខ្មែរក្រហមប្រាប់ខ្ញុំឲ្យរត់ទៅព្រំដែនខ្មែរ-ថៃ។ នៅពេលរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់មករស់នៅក្នុងភូមិរបស់ខ្ញុំវិញ។ មួយរយៈក្រោយមក ខ្ញុំបានរៀបការ ហើយរស់នៅជុំជាមួយឪពុកម្តាយ។ ចំណែកបងប្អូនរបស់ខ្ញុំ បានទៅរស់នៅជាមួយអុំរបស់ខ្ញុំ។

ថ្វីត្បិតខ្មែរក្រហមដួលរលំក៏ពិតមែន ប៉ុន្តែនៅក្នុងតំបន់របស់ខ្ញុំមិនទាន់បានសុខទេ ព្រោះពេលខ្លះកងទ័ពខ្មែរក្រហមលបចូលក្នុងភូមិដើម្បីចាប់គោ-ក្របី របស់ប្រជាជនយកទៅអស់។ ពេលខ្លះកងទ័ពខ្មែរក្រហមជួបកងទ័ពរដ្ឋកម្ពុជា ក៏វាយប្រយុទ្ធគ្នាបណ្តាលឲ្យស្លាប់ និងរបួសកងទ័ពជាច្រើន។ ជារឿយៗ កងទ័ពខ្មែរក្រហម បានផ្លោងគ្រាប់ចូលក្នុងភូមិស្រុក ដូច្នេះកងទ័ពរដ្ឋកម្ពុជាក៏បានជម្លៀសអ្នកភូមិរបស់ខ្ញុំមករស់នៅភូមិពងទឹកនេះរហូតមកដល់សព្វថ្ងៃ ដោយពេលនោះកងទ័ពរដ្ឋកម្ពុជាបានចែកដីឲ្យអ្នកភូមិគ្រប់គ្នាដើម្បីធ្វើស្រែចម្ការ។ ខ្ញុំ និងប្តីបានធ្វើស្រែចម្ការដែលរបបរដ្ឋកម្ពុជាចែកឲ្យរហូតដល់ប្តីរបស់ខ្ញុំស្លាប់ ហើយខ្ញុំនៅតែបន្តធ្វើស្រែដល់ពេលបច្ចុប្បន្ន។



ផ្ទះរបស់ ស៊ិន ហឿង ស្ថិតនៅក្នុងភូមិពងទឹក ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។ (យ៉ន់ ឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្មាំងរបស់អង្គការ

ស្ងួត វិចិត្រ



សោម ថា និង ស្ងួត វិចិត្រ ថតរូបជុំគ្នាបន្ទាប់ពីវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅស្រុកអន្លង់វែង កាលពីខែកញ្ញា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សោម ថា អាយុ៥៦ឆ្នាំ មានទីកន្លែងកំណើតនៅភូមិសារី ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ នៅពេលខ្ញុំមានអាយុ ៨ឆ្នាំ ខ្មែរក្រហមស្នើឲ្យម្តាយរបស់ខ្ញុំទៅវែកដី និងលើកទំនប់នៅការដ្ឋានមួយកន្លែងមានឈ្មោះថា «ទំនប់ ៣០ កញ្ញា» ដែលមានចម្ងាយប្រមាណ ១០ គីឡូម៉ែត្រពីភូមិរបស់ខ្ញុំ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំទៅជាមួយម្តាយទេ ដោយសារខ្ញុំត្រូវមើលថែប្អូនៗរបស់ខ្ញុំពីរនាក់នៅផ្ទះ ។

ក្នុងនាមខ្ញុំជាបងស្រីម្នាក់ ខ្ញុំពិតជាមានការលំបាកក្នុងការថែរក្សាប្អូនជាពិសេសនៅពេលប្អូនៗរបស់ខ្ញុំឃ្លានអាហារម្តងៗ។ ខ្ញុំតែងតែរង់ចាំស្នូរជួងដែលអង្គការអនុញ្ញាតឲ្យខ្ញុំនិងប្អូនៗទៅយករបបអាហារនៅរោងចុងភៅដែលមានចម្ងាយប្រមាណ២០០ម៉ែត្រពីផ្ទះរបស់ខ្ញុំ។ ចុងភៅតែងតែវាយក្បាលយើងនឹងវែកជាញឹកញាប់ ដោយសារតែប្អូនៗរបស់ខ្ញុំតែងអើតមើលឆ្នាំងបបរព្រោះឃ្លានខ្លាំង។ យាយ លឹម និង យាយ ណេង គឺជាចុងភៅដែលត្រូវបានស្គាល់ថាមានសម្តីកោងកាច និងទឹកចិត្តមិនល្អនៅទីនោះ ហើយតែងតែមានភាពរឹតត្បិតរបបអាហាររបស់យើង។

ថ្ងៃមួយ ដោយសារប្អូនៗរបស់ខ្ញុំឃ្លានខ្លាំងពេក ខ្ញុំក៏សម្រេចចិត្តលួចគាស់ដំឡូងមីចំនួនពីរគុម្ព នៅក្បែរផ្ទះមកស្ងោរឲ្យប្អូនៗហូប។ ចៃដន្យកង ឈ្លបរបស់

ខ្មែរក្រហមពីរនាក់មកដល់កំឡុងពេលដំឡូងឆ្អិន។ កងឈ្លបយកទឹកចាក់ពន្លត់ភ្លើងស្ងោរដំឡូង ហើយចោទប្រកាន់ខ្ញុំថាគឺជា «ខ្មាំងរបស់អង្គការ» ដែលហ៊ានលាក់ទុកឆ្នាំង និងលួចកាស់ដំឡូងស្ងោរហូប។ កងឈ្លបថែមទាំងបានគំរាមសម្លាប់ខ្ញុំទៀតផង។ បន្ទាប់មក កងឈ្លបយកឆ្នាំងខ្ញុំទៅបាត់ ចំណែកខ្ញុំបានត្រឹមឈរយំអាណិតប្អូនៗនៅក្បែរចង្ក្រាន។

ក្រោយមកខ្ញុំឃើញប្រជាជនប្រហែល ៦០គ្រួសារ ដែលត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ មកកាន់ភូមិរបស់ខ្ញុំ។ ជារៀងរាល់ថ្ងៃខ្ញុំតែងតែរត់លេងជាមួយក្មេងៗដែលទើបជម្លៀសមកទាំងអស់នោះ រហូតដល់អង្គការផ្លាស់ក្រុមគ្រួសារប្រជាជនថ្មីទាំងអស់នោះទៅកាន់ភូមិថ្មី។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនមានឱកាសបានប្រលែងលេងជាមួយក្មេងៗទាំងអស់នោះទៀតទេ។

មិនយូរប៉ុន្មាន ម្តាយរបស់ខ្ញុំត្រូវបានប្រធានសហករណ៍ផ្លាស់ឲ្យមកធ្វើការនៅរោងម៉ាស៊ីនកិនស្រូវនៅក្នុងភូមិកំណើតវិញ។ គាត់សប្បាយចិត្តជាងព្រោះបានជួបជាមួយកូនៗវិញ។ ជារៀងរាល់ថ្ងៃ ម្តាយខ្ញុំលួចអង្ករមួយឬពីរកំប៉ុងទុកដាំបាយឲ្យកូនៗហូប។ យើងក្រោកនៅវេលាម៉ោង៤ទៀបភ្លឺ ដើម្បីហូបបាយដែលម្តាយខ្ញុំដាំ។

មួយរយៈក្រោយមកអង្គការខ្មែរក្រហមផ្លាស់ម្តាយខ្ញុំឲ្យទៅធ្វើជាចុងភៅវិញ។ ប្រជាជននៅក្នុងសហករណ៍គោរពស្រឡាញ់ម្តាយរបស់ខ្ញុំដោយសារតែសណ្តានចិត្តល្អរបស់គាត់ និងភាពមិនរឹតត្បិតទៅលើរបបអាហារប្រចាំថ្ងៃ។ ម្តាយរបស់ខ្ញុំថែមទាំងលួចរបបអាហារឲ្យប្រជាជនដែលស្រេកឃ្លានខ្លាំងជាពិសេសនៅពេលគាត់ទៅបើកស្បៀងអាហាររបស់សហករណ៍ម្តងៗ។ ប្រជាជននៅក្នុងសហករណ៍ហាក់មានភាពប្រសើរឡើងតិចតួចទៅលើការហូបចុកប្រចាំថ្ងៃចាប់តាំងពីម្តាយរបស់ខ្ញុំធ្វើជាចុងភៅ។

រហូតដល់ដើមឆ្នាំ១៩៧៩ របបខ្មែរក្រហមបានដួលរលំ ដូច្នេះសហករណ៍ត្រូវបានរំសាយចោលទាំងអស់។ ពេលនោះ ម្តាយខ្ញុំបានចាប់ផ្តើមប្រកបរបរធ្វើស្រែចម្ការនៅក្នុងភូមិ ចំណែកខ្ញុំឃ្វាលគោ។ ក្រោយមក កងទ័ពខ្មែរក្រហមបានចូលទៅដល់ភូមិរបស់ខ្ញុំម្តងទៀត ហើយបានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រជាជននៅក្នុងភូមិឡើងវិញ។

រហូតដល់ឆ្នាំ១៩៨៥ ខ្ញុំសម្រេចចិត្តចាកចេញពីផ្ទះសម្បែង ហើយធ្វើដំណើរជាមួយកងទ័ពខ្មែរក្រហមទៅកាន់ភ្នំដងរែក។ កងទ័ពទាំងនោះបាននិយាយថា ខ្លួននឹងនាំយើងទៅកាន់ប្រទេសថៃដែលជាទីកន្លែងសុវត្ថិភាព និងមានភាពសម្បូរសប្បាយ។ ខ្ញុំធ្វើដំណើរជាច្រើនយប់ច្រើនថ្ងៃ ទើបទៅដល់ព្រៃស្អាក ស្ថិតនៅក្នុងខេត្តសៀមរាប-ឧត្តរមានជ័យ ដែលជាទីកន្លែងចំណតមុនពេលខ្ញុំត្រូវបន្តដំណើរទៅកាន់ប្រទេសថៃ។ ខ្ញុំបានរស់នៅទីនោះអស់រយៈពេលជិតមួយសប្តាហ៍បន្ទាប់មកខ្ញុំធ្វើដំណើរបន្តទៅកាន់ភូមិអូរត្រាវ (ជំរំអូរត្រាវ) ប្រទេសថៃ ដោយត្រូវឆ្លងកាត់ភ្នំដងរែក។

នៅជំរំខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅធ្វើការជាកងដឹកជញ្ជូនគ្រាប់ទៅកាន់តំបន់សមរភូមិតាមបណ្តោយជើងភ្នំដងរែកដើម្បីវាយជាមួយកងទ័ពវៀតណាមដែលឈរជើងនៅភូមិឫស្សី និងភូមិផ្អាវ និងតំបន់ត្រពាំងប្រាសាទទាំងមូល។

រហូតដល់ឆ្នាំ១៩៨៦ ខ្ញុំរៀបការជាមួយប្តីឈ្មោះ គង់ លឹម គឺជាអតីតកងទ័ពខ្មែរក្រហម។ ប្រធានអង្គភាពទ័ពបានរៀបចំពិធីសែនព្រេន និងទំនុកបម្រុងស្បៀងអាហារមួយចំនួនដល់យើង។ ខ្ញុំបានរស់នៅលើភ្នំដងរែករហូតដល់កងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៨៩ ទើបខ្ញុំនិងប្រជាជនដទៃទៀតបានចុះមករស់នៅភូមិឫស្សី ស្រុកត្រពាំងប្រាសាទ ដែលជាអតីតទីតាំងកាំភ្លើងធំរបស់កងទ័ពវៀតណាម។ យើងបានផ្លាស់ទីកន្លែងជាច្រើនលើកច្រើនសារ ទម្រាំមានការបញ្ចប់សង្គ្រាមនៅតំបន់អន្លង់វែង។

# កុយ សុខ ៖ កងនេសាទត្រី

***រមេក ទិន***



*កុយ សុខ និងក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង អំឡុងពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅស្រុកអន្លង់វែងចន្លោះថ្ងៃទី១១ដល់ទី១៤ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ កុយ សុខ អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅខេត្តសៀមរាប។ សព្វថ្ងៃខ្ញុំរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ កាលពីកុមារភាពខ្ញុំរស់នៅក្នុងគ្រួសារមួយមានជីវភាពមធ្យម។ ខ្ញុំមានបងប្អូនបង្កើតចំនួន៩ នាក់ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។

នៅក្នុងឆ្នាំ១៩៧២ ខ្ញុំស្ម័គ្រចិត្តចូលធ្វើកងទ័ពរំដោះ។ ដំណាន់នោះប្រសិនបើមានកម្លោះៗណាមិនចូលធ្វើទាហានស្រីៗនៅក្នុងភូមិមិនទទួលយកធ្វើជាប្តីនោះទេ។ ហេតុនេះហើយទើបប្រុសៗក្នុងភូមិខ្ញុំសម្រេចចិត្តចូលធ្វើទាហានគ្រប់ៗគ្នា។ បុរសៗចូលធ្វើទាហានទោះរងគ្រោះថ្នាក់ពិការដៃ ជើង ខ្វាក់ភ្នែកយ៉ាងណាក៏នារីៗព្រមទទួលយកធ្វើជាប្តីដែរ។ ខ្ញុំចូលធ្វើជាកងទ័ពដំបូងនៅ ខាងកងនេសាទត្រី។ កាលនោះខ្ញុំគឺជាអ្នកដឹកត្រីងៀតចេញពីកំពង់ឃ្លាំង និងកំពង់ភ្លុក ទៅដាក់នៅផ្សារចាស់សៀមរាប។ កងនេសាទជំនាន់នោះមួយកងមានឡានចំនួន ៣ ទៅ ៤ គ្រឿង សម្រាប់ដឹកត្រី។ មេកងដឹកត្រីរបស់ខ្ញុំឈ្មោះ តាអឿម និងតាសុខ។ ការហូបចុកខ្ញុំមិនមានការខ្វះខាតអ្វីទេ ខ្ញុំហូបឆ្អែតៗ។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវមេសហករណ៍រៀបចំឲ្យមានគ្រួសារ។ ប្រពន្ធរបស់ខ្ញុំគាត់មានតួនាទីជា

ពេទ្យៗ ក្រោយមកកងពលខ្ញុំដកឲ្យមកនៅកងចល័ត ធ្វើជាអ្នកមើលការខុសត្រូវក្រុមនីមួយៗឲ្យលើកទំនប់ៗ កាលនោះក្នុងម្នាក់ខ្ញុំកំណត់ឲ្យលើកចំនួន ១៥ម៉ែត្រ និងកម្ពស់១ម៉ែត្រ ហើយក្នុងរយៈពេលមួយថ្ងៃៗ ការធ្វើស្រែស្រូវជំនាន់នោះយើងប្រើគោភ្លួរ ប៉ុន្តែស្រូវទទួលបានផលច្រើនណាស់ព្រោះដីល្អៗ ខ្ញុំរស់នៅក្នុងកងចល័តរហូតដល់ឆ្នាំ១៩៧៩ ហើយពេលកងទ័ពវៀតណាមវាយចូលមកខ្ញុំរត់ចូលព្រៃៗ កងកម្លាំងទ័ពខ្ញុំចុះទៅវាយនៅផ្លូវជាតិលេខ៦ ម្តុំភូមិអូរ និងកំពង់ក្តីៗ ក្នុងឆ្នាំ១៩៧៩ ខ្ញុំសម្រេចចិត្តចូលធ្វើជាកងទ័ពខ្មែរក្រហមៗ បន្ទាប់ពីខ្ញុំចូលធ្វើជាកងទ័ពខ្ញុំបន្តដើរតាមកងទ័ពនៅក្នុងព្រៃ ដើម្បីរង់ចាំកងទ័ពតាម៉ុក មកយកទៅលើភ្នំដងរែកៗ រហូតដល់ឆ្នាំ ១៩៨១ ខ្ញុំធ្វើដំណើរឆ្ពោះទៅលើភ្នំដងរែកតាមច្រកភ្នំ១០០៣ៗ ការធ្វើដំណើរពេលនោះ ខ្ញុំរួមទាំងកងទ័ពរួមដំណើរជាច្រើននាក់ បានជួបឧបសគ្គជាច្រើន ជួនកាលដើរជួបកងទ័ពវៀតណាមបាញ់រត់ពេញព្រៃ ពេលខ្លះក៏ដាច់ស្បៀងនិងទឹកៗ ខ្ញុំធ្វើដំណើររយៈពេលមួយសប្តាហ៍ទើបទៅដល់ភ្នំ១០០៣ គ្រប់គ្រងដោយ តាម៉ុកៗ ការរស់នៅលើភ្នំគឺខ្ញុំរស់នៅជាកងទ័ពរួមៗ កំ ឡុងឆ្នាំ១៩៨៥ ខ្ញុំត្រូវបញ្ជូនឲ្យចុះទៅវាយនៅភ្នំពេញៗ កាលនោះទិសដៅដែលខ្ញុំវាយដំបូងគឺនៅម្តុំបារាយណ៍ វាយជាមួយកងទ័ពវៀតណាមៗ កម្លាំងកងទ័ពចុះទៅវាយដំបូងចំនួន ៩០០នាក់ ទៅចំនួន១០០០នាក់ ហើយគ្រាប់រំសេវកងទ័ពខ្ញុំកប់លាក់ទុករួចជាស្រេចៗ



កុយ សុខ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គីម ចយ ៖ យោធាក្នុងភូមិភាគពិសេស

**ស្លូត ទិចិត្រ**



គីម ចយ អំឡុងពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ចន្លោះថ្ងៃទី១១ ដល់ទី១៨ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គីម ចយ អាយុ៩៧ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិព្រែកតាអោម ឃុំពាមតាឯក ស្រុកល្វាឯម ខេត្តកណ្ដាល។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ កាលពីកុមារភាព ខ្ញុំបួសរៀននៅវត្តពាមតាឯករយៈពេល២វស្សា។ ខ្ញុំរៀនអក្សរខ្មែរ និងសង្កេតមើលពីរបៀបទ័ពនៅមុនជំនាន់ឥស្សរៈ។ បុគ្គលដែលល្បីក្នុងស្រុកភូមិរបស់ខ្ញុំ គឺអាចារ្យយី គឺមានសកម្មភាពយ៉ាងផុសផុលក្នុងការទាមទារឯករាជ្យពីបារាំង។ ជំនាន់នោះប្រជាជននៅក្នុងភូមិ ក៏ត្រូវបារាំងកេណ្ឌឲ្យទៅធ្វើកងទ័ពដើម្បីបង្ក្រាបក្រុមបះបោរនៅឯប្រទេសវៀតណាម កំឡុងពេលស្ថិតក្រោមអាណានិគមបារាំង។ ក្រោយមក សម្ដេច ព្រះនរោត្តម សីហនុ បង្កើតកងជីវពលនារីក្លាហាន ដើម្បីទាមទារឯករាជ្យពីបារាំង កាលនោះខ្ញុំត្រូវបាត់ឲ្យចូលធ្វើគ្រូបង្វឹកពីរបៀបសម្រាកប្រុងនិងយុទ្ធសាស្ត្រទ័ពក្នុងចំណោមមនុស្សប្រមាណចំនួន៣៥០នាក់។ យើងប្រើប្រាស់បំពង់ឫស្សី និងថ្មស្ពុយ ដើម្បីធ្វើជាអាវុធក្នុងការហ្វឹកហាត់អស់រយៈពេលប្រមាណជាបីខែបន្ទាប់មក យើងបានប្រមូលផ្តុំកម្លាំងប្រជាជនកាន់តែច្រើននៅក្នុងចលនាទាមទារមួយនេះ។ រហូតដល់ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំង។ ខ្ញុំមិនទាន់លាឈប់ពីកងជីវពលនោះទេ។ ប្រធានសង្កាត់បាត់តាំងឲ្យខ្ញុំធ្វើជាកងសន្តិសុខនៅឃុំពាមតាឯក ដើម្បីបង្ក្រាបការលេងល្បែង និងការស៊ីផឹកពាលា ភាគច្រើនប្រព្រឹត្តដោយជនជាតិចិន។ ក្រោយមក ខ្ញុំក៏ឈប់ធ្វើជាកងជីវពល ហើយទៅស៊ីឈ្នួលនេសាទត្រីឲ្យជនជាតិអ៊ីស្លាមនៅអរិយក្សត្រ។ ខ្ញុំយល់ដឹងពីរបៀបរបស់ជនជាតិអ៊ីស្លាម ប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់យ៉ាងខ្ជាប់ខ្ជួនជាពិសេសគឺស្ត្រីៗដោយមានការតំណមពាក្យសម្ដីឬភាពតឹងរឹងនៅក្នុងពិធីសាសនាណាមួយ។ ប៉ុន្តែភាគច្រើន ខ្ញុំតែងតែប្រាស្រ័យទាក់ទងជាមួយជនជាតិអ៊ីស្លាមទាំងនោះ។ នៅក្នុងមុខរបរស៊ីឈ្នួលនេសាទ ខ្ញុំទទួលបានប្រាក់ចំនួន៣០០រៀលក្នុងមួយខែ គឺជាចំនួនសមរម្យកាលជំនាន់នោះ។ ក្រោយមក ខ្ញុំរៀបការនៅអាយុ១៩ឆ្នាំ នៅក្នុងខេត្តកណ្ដាល។

ខ្ញុំបម្រើក្រុមគ្រួសារខាងប្រពន្ធរបស់ខ្ញុំអស់រយៈពេល ១ឆ្នាំ ដើម្បីឈានទៅដល់ការរៀបការ។ ជំនាន់នោះ នៅឆ្នាំ១៩៧០ នៅពេល លន់ នល់ ធ្វើរដ្ឋប្រហារ ខ្ញុំចូលចលនាខាងខ្មែរក្រហមតាមការអំពាវនាវរបស់សម្ដេច ព្រះនរោត្ដម សីហនុ ឲ្យចូលព្រៃម៉ាគី។ ខ្ញុំត្រូវបញ្ជូនទៅកាន់ព្រលានយន្តហោះខេត្តសៀមរាប ហើយខ្ញុំការពារនៅតំបន់អង្គរ។ ខ្ញុំមើលឃើញកម្មករខ្មែរជាច្រើននាក់ កំពុងជួសជុលប្រាង្គប្រាសាទក្រោមការដឹកនាំដោយស្ថាបត្យករជំនាន់របស់ជនជាតិបារាំង។ ក្រោយមក កងកម្លាំងរបស់ខ្ញុំត្រូវបញ្ជូនទៅកាន់តំបន់ត្រពាំងព្រាយ ខេត្តកំពង់ស្ពឺ ដើម្បីប្រយុទ្ធជាមួយទាហាន លន់ នល់។ នៅពេលនោះ ខ្ញុំនាំផ្លូវ និងចុះជាប់ជាមួយ ហ៊ូ នឹម ដើម្បីវាយតាមសមរភូមិ។ កងកម្លាំងរបស់យើងវាយសម្រុកនៅភ្នំបាសិត និងទទួលបានជ័យជម្នះ ស្របពេលទីក្រុងភ្នំពេញត្រូវកាន់កាប់ដោយយោធាខ្មែរក្រហមក្នុងឆ្នាំ១៩៧៥។ ក្រោយមកខ្ញុំត្រូវចាត់តាំងឲ្យឈរជើងនៅជិតស្ពានអូរឡាំពិក ទីក្រុងភ្នំពេញ ហើយមួយរយៈពេលខ្លីយើងក៏ត្រូវបានដកគ្រឿងសព្វាវុធ និងបញ្ជូនឲ្យទៅលើកទំនប់និងធ្វើស្រែនៅតំបន់កប់ស្រូវ។ ក្រោយមកទៀត ថ្នាក់លើខ្មែរក្រហមចាត់ខ្ញុំចូលកងទ័ពក្នុងភូមិភាគពិសេស។ នៅពេលមួយ ខ្ញុំបានត្រឡប់ទៅលេងផ្ទះនៅឯភូមិកំណើត។ ខ្ញុំបានជួបជាមួយកូនប្រុសរបស់ខ្ញុំពីរនាក់កំពុងឃ្វាលគោនៅវាលស្រែ។ កូនខ្ញុំទាំងពីរនាក់មិនស្គាល់ខ្ញុំថា ជាឪពុកនោះទេ ចំណែកខ្ញុំវិញក៏ដូចគ្នាដែរ។ ខ្ញុំសួរឈ្មោះគាត់ និងប្រាប់គាត់ថា ខ្ញុំគឺជាឪពុករបស់គាត់។ ភ្លាមៗនោះយើងក៏បានស្គាល់គ្នា។បន្ទាប់មកទៀត ខ្ញុំក៏បានទៅលេងផ្ទះ និងជួបប្រពន្ធរបស់ខ្ញុំជាមួយនឹងគ្រួសារថ្មីរបស់គាត់។ ទោះជាយ៉ាងនេះក្ដី ខ្ញុំមិនបានខឹងនឹងគាត់នោះទេ ដោយសារតែខ្ញុំបានបំពេញកាតព្វកិច្ចជាប្ដី និងមើលថែកូនៗ។ ខ្ញុំបានរាប់អានគាត់ដូចបងប្អូនបង្កើតក្រោយមកយើងលែងទទួលបានដំណឹងអ្វីពីគ្នា។ ខ្ញុំបានហូបបាយជួបជុំគ្នាជាមួយនឹងគ្រួសារថ្មីរបស់គាត់ រហូតដល់ខ្ញុំវិលត្រឡប់ទៅកាន់ព្រំដែនវៀតណាមវិញ។ យើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សូ សារឿន (តា០៥) នៅតំបន់ជនជាតិភាគតិច។ ពេលមួយ ខ្ញុំបានទទួលសំបុត្រ (ដែលមានអក្សរមិនច្បាស់ដូចទៅនឹងជើងក្អាម) ទៅដាក់នៅមន្ទីរស្រុក។ ភ្លាមៗនោះ ខ្ញុំត្រូវបានមន្ទីរស្រុកចាប់ដាក់គុក និងសួរចម្លើយស៊ើបរកខ្សែក្បត់។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនត្រូវបានឆ្កាំគុកទាំងនោះវាយដំ ឬធ្វើទារុណកម្មឡើយ។ ខ្ញុំទទួលបានរបបអាហារហូបគ្រប់គ្រាន់មិនដូចទៅនឹងអ្នកទោសឯទៀតដែលនៅទីនោះទេ នេះអាចនឹងមកពីខ្ញុំធ្លាប់មានប្រវត្តិជាទ័ពនៅក្នុងភូមិភាគពិសេស។ ក្រោយមកខ្ញុំក៏ត្រូវបានដោះលែងមកវិញ ហើយចូលទៅក្នុងកងពលលេខ៨០០ គ្រប់គ្រងដោយ មិត្តធិន។ ខ្ញុំត្រឡប់រស់នៅតំបន់អង្គរអស់រយៈពេលប្រមាណជា៥ឆ្នាំ ដើម្បីមើលការខុសត្រូវផ្នែកសន្តិសុខសណ្ដាប់ធ្នាប់ និងទប់ទល់មុខតម្កាលជាមួយកងទ័ពវៀតណាមដែលនៅឈរជើងនៅបរិវេណអង្គរ ជាពិសេសទីតាំងទ្វារខ្មោច។ រហូតដល់បរាជ័យជាមួយកងទ័ពវៀតណាម កងកម្លាំងរបស់យើងក៏បានធ្វើដំណើរកាត់ព្រៃឆ្ពោះទៅកាន់តំបន់ ១០០១ ខេត្តព្រះវិហារ ដើម្បីរៀបចំកម្លាំងឡើងវិញ។



ទេសភាពស្រូវវស្សានៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ចន្លោះថ្ងៃទី១១ដល់ទី១៨ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គុយ អឹម ៖ កងទ័ពនារី

**រមេក ខិន**



គុយ អឹម អំឡុងពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ចន្លោះថ្ងៃទី១១ ដល់ទី១៤ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គុយ អឹម អាយុ៧០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិអង្គខ្នាយ ឃុំដានគោង ស្រុកអង្គរជ័យ ខេត្តកំពត។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ កាលពីក្មេងខ្ញុំរៀនត្រឹមថ្នាក់ទី១០។ ខ្ញុំឈប់រៀនដោយសារតែស្រុកភូមិរបស់ខ្ញុំកើតមានសង្គ្រាម។ ខ្ញុំបន្តរស់នៅជាមួយឪពុកម្តាយជួយធ្វើស្រែចម្ការ រហូតដល់ខ្មែរក្រហមចូលមកគ្រប់គ្រងភូមិ។ នៅក្នុងឆ្នាំ១៩៧២ ខ្ញុំត្រូវថ្នាក់ដឹកនាំឃុំបង្ខំឲ្យចូលធ្វើជាកងទ័ពនារី។ កាលនោះនៅក្នុងភូមិខ្ញុំ ប្រមូលនារីៗបានចំនួន៣នាក់។ បន្ទាប់ពីប្រមូលបានហើយថ្នាក់ដឹកនាំភូមិ-ឃុំ បញ្ជូនខ្ញុំទាំង៣នាក់ទៅព្រំដែនវៀតណាម។ ពេលនោះខ្ញុំមានអាយុ១៦ឆ្នាំ។ កងទ័ពនារីមានគ្នាចំនួន ២០០នាក់ ឈរជើងការពារព្រំដែនខ្មែរ-វៀតណាម។ ក្រៅពីការពារព្រំដែន ខ្ញុំ និងកងទ័ពនារីទាំងអស់ត្រូវទៅធ្វើស្រែប្រមូលផល ទុកដើម្បីផ្គត់ផ្គង់ជីវភាពកងទ័ពខ្លួនឯង។ ដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបញ្ជូនទៅទីក្រុងភ្នំពេញដើម្បីរៀបចំផ្ទះសម្បែងរបស់ប្រជាជនដែលទុកចោល។ ក្រៅពីរៀបចំផ្ទះសម្បែង ខ្ញុំចូលទៅខាងដាំបាយផ្គត់ផ្គង់ឲ្យមេៗ ដែលមករៀនពីនយោបាយនៅស្តាតអូឡាំពិក។ អ្នកមកចូលរួមរៀនមានគ្នាពីចំនួន ២០០នាក់ទៅចំនួន៣០០នាក់។ រាល់ការបង្រៀនម្តងៗមានរយៈពេលមួយសប្តាហ៍ទើបចប់។ ការហូបចុកខ្ញុំទទួលរបបអាហារគ្រប់គ្រាន់ ដោយសារតែខ្ញុំគឺជាអ្នកដាំបាយ ធ្វើម្ហូប។ នៅឆ្នាំ១៩៧៦ ខ្ញុំផ្លាស់ទៅខេត្តរតនគិរី វិញម្តង។ កាលនោះខ្ញុំធ្វើដំណើរតាមកាណូតរបស់ថ្នាក់លើបញ្ជូនឲ្យមកទទួលកម្លាំងកងទ័ព និងក្រុមគ្រូពេទ្យចំនួន ៤កាណូត ដោយបានដឹកកម្លាំងនារីៗចំនួន ២កាណូត និងកម្លាំងប្រុសៗចំនួន ២កាណូត។ ការធ្វើដំណើរអស់រយៈពេល១ថ្ងៃ១យប់ក៏បានទៅដល់ខេត្តក្រចេះ។ ខ្ញុំរួមទាំងកងកម្លាំងទាំងអស់បានឈប់សម្រាកនៅក្នុងខេត្តក្រចេះ ជួយប្រមូលស្រូវប្រជាជនអស់រយៈពេលកន្លះខែ ទើបបន្តដំណើរទៅស្រុកបានលុង ក្នុងខេត្តរតនគិរី។ នៅពេលទៅដល់ បានលុង ថ្នាក់លើបញ្ជូនឲ្យខិតខំបង្កបង្កើនផលស្រូវ។ ដល់ឆ្នាំ១៩៧៨ ខ្ញុំត្រូវអង្គការរៀបចំឲ្យមានគ្រួសារ។ ខ្ញុំរៀបការចំនួន១៥គូក្នុងពេលដំណាលគ្នា

ហើយ សុទ្ធតែអង្គការចាប់គូឲ្យមិនមានគូមួយណាពេញចិត្តស្រឡាញ់គ្នាចិត្តដោយចិត្តទេ។ ខ្ញុំមិនបានស្រឡាញ់គ្នាជាមួយប្តីខ្ញុំទេប៉ុន្តែដោយសារខ្ញុំមិនហ៊ានប្រកែកទើបខ្ញុំសុខចិត្តរស់នៅជាមួយគ្នា។ គូណាដែលរស់នៅមិនចុះសម្រុងនឹងគ្នាអង្គការនឹងហៅទៅប្រជុំដើម្បីនិយាយទិតៀន។ ក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមកដល់ខេត្តមណ្ឌលគិរី ខ្ញុំរួមទាំងប្រជាជនជាច្រើននាក់ ដែលរស់នៅក្នុងខេត្តមណ្ឌលគិរី រត់ចូលទៅនៅក្នុងព្រៃដើម្បីលាក់ខ្លួនពីកងទ័ពវៀតណាម។ ការរស់នៅក្នុងព្រៃមានការលំបាកច្រើនណាស់ ខ្ញុំមិនដែរបានបាយហូបទេ។ ក្នុងកំឡុងពេលរស់នៅក្នុងព្រៃ ខ្ញុំបានជីកដំឡូង មើមក្តួច និងទំពាំងយកមកហូបជំនួសបាយ។ ឯកន្លែងសម្រាកក៏ពិបាក កាលណោះយើងដេកតែលើដី បើមានភ្លៀងធ្លាក់យើងនាំគ្នាកាប់ឬស្សីធ្វើខ្ទមតូចល្មមដើម្បីចូលជ្រក។ ខ្ញុំរស់នៅក្នុងព្រៃរហូតដល់ឆ្នាំ១៩៨៦ ទើបមានកងកម្លាំងខ្មែរក្រហមចុះពីលើភ្នំដងរែកមកទទួលយកទៅព្រំដែនថៃ។ បន្ទាប់មក យើងទាំងអស់គ្នាសម្រេចចិត្តធ្វើដំណើរចាកចេញពីព្រៃក្នុងខេត្តមណ្ឌលគិរីឆ្ពោះទៅភ្នំដងរែក។ ការធ្វើដំណើរអស់រយៈពេលកន្លះខែទើបទៅដល់តំបន់ភ្នំ១០០១។ បន្ទាប់ពីបានមកដល់ភ្នំ១០០១ ហើយការរស់នៅរបស់យើងមានភាពប្រសើរជាងមុនដោយទទួលបានការហូបចុកគ្រប់គ្រាន់។



ទេសភាពដំណាំអំពៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ញៀន រីន ៖ កងចល័តស្រុក

**ហ៊ាន ពិសី**



ញៀន រីន កំពុងផ្តល់បទសម្ភាសន៍ទៅកាន់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង អំឡុងពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីចន្លោះថ្ងៃទី១១ដល់ទី១៤ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ញៀន រីន អាយុ៦៥ឆ្នាំ មានទីកន្លែងកំណើតនៅ ឃុំគោកធ្លោកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ កាលពីក្មេងខ្ញុំទៅរស់នៅជាមួយជីដូនរបស់ខ្ញុំនៅក្នុងភូមិក្របីរាល បន្ទាប់ពីម្តាយរបស់ខ្ញុំស្លាប់។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៣ ក្រោយមកខ្ញុំឈប់រៀនដោយសារសាលារៀននៅឆ្ងាយពីភូមិ។ ឆ្នាំ១៩៧៥ ខ្មែរក្រហមវាយដាច់ទីក្រុងភ្នំពេញ ខ្ញុំត្រូវជ្រើសរើសឲ្យធ្វើជាកងចល័តស្រុក។ ពេលនោះខ្មែរក្រហមបែងចែកប្រជាជនជាពីរគឺប្រជាជនចាស់ និងប្រជាជនថ្មី។ ភូមិក្របីរាល ត្រូវខ្មែរក្រហមចាត់ទុកថាជាភូមិប្រជាជនថ្មី។ ហេតុនេះការរស់នៅរបស់យើងមានការលំបាកជាងប្រជាជនចាស់ឆ្ងាយណាស់។ ប្រសិនបើមានកំហុសអ្វីមួយ មិនថាធ្ងន់ឬស្រាល ប្រជាជនថ្មីពុំត្រូវបានខ្មែរក្រហមលើកលែងទោសឲ្យឡើយ។ ជារឿយៗនៅពេលខ្មែរក្រហមប្រាប់ថាបញ្ជូនទៅរៀនសូត្រច្បាស់ណាស់ប្រជាជននោះនឹងត្រូវយកទៅសម្លាប់ព្រោះខ្ញុំមិនដែលឃើញអ្នកភូមិអង្គការហៅទៅបានត្រឡប់មកវិញទេ។ ការហូបចុកយើងទទួលបានតែបបររាវប៉ុណ្ណោះសម្រាប់អាហារបីពេល។ ក្រោយមកឪពុកខ្ញុំទទួលដំណឹងថាខ្ញុំរស់នៅភូមិក្របីរៀលលំបាក គាត់ក៏ស្នើទៅប្រធានកងឲ្យខ្ញុំទៅរស់នៅជាមួយគាត់ក្នុងភូមិថ្នល់បាសិត។ ទោះបីខ្ញុំផ្លាស់ប្តូរទៅទីនោះហើយក៏ដោយ ខ្ញុំនៅតែបន្តធ្វើការនៅក្នុងកងចល័តស្រុកដដែល។ ខ្ញុំធ្វើការងារជាច្រើនកន្លែងនៅជុំវិញស្រុកជីក្រែង ដូចជា លើកទំនប់ ដកស្ទូងស្រូវធ្វើស្រូវប្រាំងនិងស្រូវវស្សា។ ជារៀងរាល់ល្ងាចយើងតែងចូលរួមប្រជុំអប់រំដើម្បីបូកសរុបលទ្ធផលការងារដែលយើងបានធ្វើហើយគ្មាននរណាម្នាក់ហ៊ានខ្ជិលច្រអូសឡើយ។

ដល់ឆ្នាំ១៩៧៧ ខ្ញុំរៀបការក្រោមការរៀបចំរបស់អង្គការខ្មែរក្រហមចំនួន៧គូ។ ក្រោយមក ខ្មែរក្រហមផ្លាស់ខ្ញុំពីកងចល័តមកធ្វើការវែកដីនៅក្នុងសហករណ៍វិញ។ ខ្ញុំនៅធ្វើការនៅទីកន្លែងនោះរហូតទាល់តែខ្ញុំសម្រាលបានកូនម្នាក់។ រយៈពេល១ខែកន្លះក្រោយមកខ្ញុំត្រូវផ្លាស់ឲ្យទៅធ្វើការនៅរោងកិនស្រូវ។ ជំនាន់នោះយើងប្រើប្រាស់ត្បាល់កិនដើម្បីកិនយកអង្ករសម្រាប់ផ្គត់ផ្គង់នៅក្នុងសហករណ៍។ រហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលក្នុងប្រទេសកម្ពុជា។ ខ្ញុំនិងគ្រួសារបានរត់ចូលក្នុងព្រៃដើម្បីគេចខ្លួនរហូតដល់មានការប្រកាសពីសំណាក់កងទ័ពវៀតណាមឲ្យយើងវិលត្រឡប់ទៅលំនៅស្ថានរបស់ខ្លួនវិញ។

# រឿង ផែន ៖ យោធា

***ហ៊ាន ពិសី***



*រឿង ផែន អំឡុងពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែកញ្ញា ឆ្នាំ២០២២។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ខ្ញុំឈ្មោះ រឿង ផែន អាយុ៦៧ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកសូទ្រនិគម ខេត្តសៀមរាប។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ នៅក្នុងជំនាន់ខ្មែរក្រហម ខ្ញុំមិនបានរៀនសូត្រនោះទេ ដោយសារត្រូវជួយការងារឪពុកម្ដាយ។ នៅពេលនោះ ខ្ញុំ និងក្មេងៗក្នុងភូមិបានឮអំពីពាក្យថាបដិវត្តន៍ខ្មែរក្រហម ហើយយើងបាននាំគ្នាស្រែកលេងថា «បដិវត្តន៍ បដិ-វ៉ៃ ស៊ីបាយអ្នកស្រែ ចោលអ្នកស្រុក»។ ឮដូចនេះ ម្ដាយរបស់ខ្ញុំក៏បានស្ដីបន្ទោសខ្ញុំខ្លាំងៗ ហើយហាមមិនឲ្យនិយាយពាក្យនេះតទៅទៀតទេ ពីព្រោះខ្លាចគេយកទៅសម្លាប់ចោល។ លុះដល់ឆ្នាំ១៩៧៣ ខ្ញុំបានសម្រេចចិត្តចូលបម្រើជាកងទ័ពខ្មែរក្រហម។ ក្រោយមកខ្ញុំត្រូវបញ្ជូនទៅសមរភូមិមុខ ដើម្បីធ្វើសង្គ្រាមជាមួយទាហាន លន់ នល់ រហូតដល់ទទួលបានជ័យជម្នះក្នុងឆ្នាំ១៩៧៥។ រយៈពេលបីថ្ងៃក្រោយមក ខ្មែរក្រហមបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថ្មីតាមផ្នែកនីមួយៗ បន្ទាប់ពីជម្លៀសប្រជាជនអស់ទាំងស្រុងពីទីក្រុងភ្នំពេញ។ ថ្នាក់លើបានជ្រើសតាំងខ្ញុំឲ្យឡើងជាប្រធានកងវរសេនាធំលេខ៥៩ កងពលលេខ៥១៥ដឹកនាំដោយ តាអឿន។ លុះនៅចុងឆ្នាំ១៩៧៥ អង្គភាពទ័ពរបស់ខ្ញុំត្រូវប្រមូលអាវុធទាំងអស់ទុកនៅក្នុងឃ្លាំង និងទៅធ្វើស្រែនៅស្រុកតាំងគោក ខេត្តកំពង់ធំរយៈពេលមួយវស្សា។ បន្ទាប់មក យើងបានបន្តទៅធ្វើការងារលើកទំនប់នៅ អន្លង់ក្ងាន។ នៅពេលនោះ តាអឿន គឺជាប្រធានកងពលលេខ៥១៥ ត្រូវរងការចោទប្រកាន់ថាជាជនក្បត់ និងត្រូវចាប់ខ្លួន។ ខ្ញុំផ្ទាល់បានរត់គេចខ្លួនទៅកាន់ស្រុកបាកាន ខេត្តពោធិ៍សាត់ ជាមួយនឹងកងកម្លាំង និងប្រជាជនជាច្រើននាក់ផ្សេងទៀត។ នៅទីនោះ មានស្រះទឹកធំមួយ ហើយស្រះនោះមិនត្រូវបានខ្មែរក្រហមអនុញ្ញាតឲ្យប្រើប្រាស់ឡើយ។ ដោយសារមិនដឹងការហាមឃាត់នេះ ប្រជាជនក៏បានចុះផ្ងូតទឹកស្រះ ហើយក៏ត្រូវបានខ្មែរក្រហមបាញ់សម្លាប់តែម្ដង។ ក្រោយមក នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅឈរជើងនៅខេត្តកំពង់សោម*

ជាមួយនឹងកងកម្លាំង៣០នាក់ ការពារទីតាំងប្រេងកាត។ លុះដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានបញ្ជូនរថក្រោះ និងកាំភ្លើងធំដាក់តាមបណ្ដោយដងស្ទឹងហាវ ក្បែររោងចក្រប្រេងកាតដែលយើងឈរជើង។ ពេលនោះ ទើបយើងដឹងខ្លួនថា កម្លាំងទ័ពវៀតណាមបានចូលមកដល់ប្រទេសកម្ពុជា។ ភ្លាមៗនោះ យើងនាំគ្នារត់គៀសខ្លួនតាមបណ្ដោយផ្លូវរថភ្លើងរហូតដល់ផ្លូវជាតិលេខ៤។ ក្រោយមក យើងជួបនឹងកងកម្លាំងរបស់យើងដែលឈរជើងនៅទីនោះ ហើយបានចង្អុលប្រាប់ទិសដៅដល់យើងឲ្យធ្វើដំណើរទៅកាន់ស្រុកស្រែអំបិល។ យើងបន្តដំណើររហូតទៅដល់ស្រុកអមលាំង ខេត្តកំពង់ស្ពឺ។ បន្ទាប់មក យើងធ្វើដំណើរទៅដល់ព្រែកជីក និងបន្តរហូតទៅដល់ស្រុកសំឡូត ខេត្តបាត់ដំបង។ ពេលនោះ កងកម្លាំងរបស់ខ្ញុំដែលសេសសល់បានចូលទៅក្នុងកងពលទីមួយរបស់ តាអង និងបន្តដំណើរទៅកាន់ភ្នំដងរែក ដើម្បីគេចខ្លួនពីការវាយប្រហាររបស់កងទ័ពវៀតណាម។ ជីវិតជាយោធារបស់យើងបានបន្តរហូតដល់ឆ្នាំ១៩៩៨ គឺនៅពេលកងកម្លាំងរបស់ខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល។



ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងធ្វើបទសម្ភាសន៍ជាមួយ រឿង ផែន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សំ មឿន ៖ អ្នកធ្វើក្បឿង

**ស្លួត វិចិត្រ**




សំ មឿន ពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នាខែកញ្ញា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សំ មឿន អាយុ៦២ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិដំណាក់ត្រយឹង ឃុំជីរះពេន ស្រុកសំរោង ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ កាលពីជំនាន់សង្គមរាស្ត្រនិយម ខ្ញុំរៀនបានត្រឹមថ្នាក់ទី៨។ ខ្ញុំចូលរៀនពីម៉ោង៦ព្រឹក និងចេញនៅម៉ោង៧ព្រឹកដែលមានរយៈពេលត្រឹមតែមួយម៉ោងប៉ុណ្ណោះ។ ពេលខ្លះយើងមិនបានរៀននោះទេ ដោយសារមានការទម្លាក់គ្រាប់បែកអំឡុងពេល លន់ នល់ ធ្វើរដ្ឋប្រហារ។ ក្រោយមកខ្មែរក្រហមចាត់ឲ្យខ្ញុំទៅធ្វើស្រែនិងកាត់ស្មៅ នៅកោះស្លាយ ស្ថិតនៅខាងជើងខេត្តតាកែវ។ ខ្ញុំធ្លាប់ត្រូវកងឈ្លបខ្មែរក្រហមធ្វើបាប ដោយសារខ្ញុំលួចដំណាំ និងផ្លែឈើហូប។ ថ្ងៃមួយខ្ញុំកុហកប្រធានសហករណ៍ថាទៅបន្ទោរបង់ ប៉ុន្តែផ្ទុយទៅវិញខ្ញុំបានទៅរើសត្នោតទុំហូប។ កងឈ្លបខ្មែរក្រហមទាត់ខ្ញុំចំនួន៥ដើង ពេលទៅទាន់ខ្ញុំនៅក្រោមដើមត្នោត។ អ្នកទាំងនោះចោទខ្ញុំថា ខ្ញុំជាមនុស្សក្បត់បដិវត្តន៍ មានគំនិតសក្តិភូមិ និងមិនលះបង់ចោលគំនិតមូលធននិយម។ រឿងមួយទៀតគឺខ្ញុំបានលួចរើសខ្យងមកដុតហូបដោយសារឃ្លានខ្លាំងពេក។ ចៃដន្យកងឈ្លបខ្មែរក្រហម បានមកដល់ម្តងទៀត ហើយយកខ្ញុំទៅចងត្រាំភក់ និងហាលមូសមួយយប់។ កងឈ្លបទាំងនោះចោទខ្ញុំទៀតថា ជាមនុស្សក្បត់នឹងបដិវត្តន៍។ ក្រោយមក ខ្ញុំត្រូវដោះលែងមកវិញ។ រហូតដល់ឆ្នាំ១៩៧៦ ឪពុករបស់ខ្ញុំបានស្លាប់ដោយសារភាពអត់ឃ្លាន។ ខ្មែរក្រហមមិនបានផ្តល់របបអាហារដល់គាត់នោះទេរយៈពេលបីថ្ងៃចុងក្រោយ។ ខ្ញុំបានលួចទៅលេងឪពុករបស់ខ្ញុំ ពេលឮដំណឹងថាគាត់ធ្លាក់ខ្លួនឈឺធ្ងន់។ គាត់ ការព្រួយបារម្ភចំពោះខ្ញុំបន្ទាប់ពីខ្ញុំបានលួចរត់ពីសហករណ៍មកលេងគាត់។ គាត់បានឲ្យខ្ញុំឆាប់ចូលដេក និងឆាប់រួតរះក្រោកពីព្រលឹមដើម្បីទៅធ្វើការនៅក្នុងសហករណ៍ឲ្យទាន់ពេលវេលា។ ខ្ញុំពិតជាសោកស្តាយណាស់ចំពោះការបាត់បង់គាត់។ ខ្ញុំឃើញថា ការធ្វើបាប និងសម្លាប់ប្រជាជនគឺស្ថិតនៅត្រឹមឃុំ ឬជំទប់ឃុំ។ មិត្តសី ដែលជាជំទប់ឃុំ និងទទួលបន្ទុកផ្នែកកងចល័តធ្លាប់មានប្រវត្តិស៊ីថ្លើមមនុស្ស។ ខ្ញុំឃើញប្រមាត់មនុស្សព្យួរនឹងជញ្ជាំងផ្ទះរបស់គាត់។ ក្រោយមក មិត្តសី ត្រូវប្រធានឃុំចាប់ខ្លួន និងសម្លាប់ដោយទាក់កនឹងខ្សែពួរ ហើយអូសតាមសត្វសេះ បន្ទាប់ពីជំទប់ឃុំរូបនេះបាន

ប្រព្រឹត្តទង្វើខុសសីលធម៌ជាមួយនារីពីរនាក់នៅក្នុងភូមិ។ រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបញ្ជូនខ្ញុំទៅធ្វើការនៅកន្លែងផលិតក្បឿងស្រកាលិញមួយកន្លែងស្ថិតនៅក្នុងភូមិក្រាំងខ្នុរ ស្រុកបរសែត ខេត្តកំពង់ស្ពឺ។ ខ្មែរក្រហមបែងចែកក្រុមផលិតក្បឿងជាពីរផ្សេងៗពីគ្នា គឺក្រុមពិសេស និងក្រុមមធ្យម។ ក្រុមមធ្យម គឺផលិតក្បឿងមួយថ្ងៃចំនួន៥០០សន្លឹក ចំណែកឯក្រុមពិសេសវិញ គឺធ្វើយ៉ាងណាផលិតក្បឿងមួយថ្ងៃឲ្យបានខ្ទង់១ពាន់សន្លឹក។ ថ្ងៃមួយ នៅពេលខ្ញុំកំពុងជាន់ដីធ្វើក្បឿង កងឈ្លបខ្មែរក្រហមបានមកដល់ ហើយស្តីបន្ទោសដល់យើងថាធ្វើការយឺតយ៉ាវ និងចាញ់ទាំងកងកុមារីទៅទៀត។ ដោយសារអត់ទ្រាំមិនបាន ខ្ញុំក៏បានតបទៅនឹងកងឈ្លបទាំងនោះវិញថា «បើកងកុមារីខ្លាំងជាងកងកុមារា ហេតុអ្វីមិនយកកងកុមារីមកធ្វើការជំនួសកងកុមារាទៅ?» ភ្លាមៗនោះ កងឈ្លបឃុំក៏បម្រុងនឹងបញ្ជូនខ្ញុំទៅកាន់មន្ទីរតាហែ ដែលស្ថិតនៅភ្នំតូច ដើម្បីសម្លាប់ចោល។ ខ្ញុំគិតថាប្រសិនបើបញ្ជូនទៅកាន់មន្ទីរតាហែពិតជាមិនរួចខ្លួននោះទេ។ ប្រជាជនច្រើនណាស់ត្រូវបានយកទៅសម្លាប់ ហើយខ្មែរក្រហមតែងតែដាំដើមល្ហុង ឬប្ញស្សីនៅត្រង់កន្លែងកប់សាកសពនោះ។ នារដូវច្រូតកាត់ស្រូវក្នុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមចូលក្នុងប្រទេសកម្ពុជា។ ពេលនោះ កងកុមារ និងសហករណ៍ត្រូវខ្មែរក្រហមបង្វែរផ្លូវឲ្យធ្វើដំណើរទៅកាន់វត្តអង្គខ្វាវ ខេត្តកំពង់ស្ពឺ។ មិត្តវែង ដែលជាអនុប្រធានកងរបស់ខ្ញុំប្រកាសប្រាប់ប្រជាជនសាថ្មីឲ្យនាំគ្នាត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ។



សំមឿន កំពុងផ្តល់បទសម្ភាសន៍ អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដល់ក្រុមការងាររមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ភារបស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បឹងកេងកង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!



























# ក្រុមការងារថតខ្សែភាពយន្តឯកសារ
## នៃក្រសួងព័ត៌មានទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកោះថ្ម

*ឈុំ រ៉ា*




បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មធ្វើបទបង្ហាញទៅកាន់ក្រុមការងារថតខ្សែភាពយន្តឯកសារក្រសួងព័ត៌មាន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃអាទិត្យ ទី០២ ខែតុលា ឆ្នាំ២០២២ ក្រុមការងារថតខ្សែភាពយន្តឯកសារនៃក្រសួងព័ត៌មាន ដឹកនាំដោយ ឯកឧត្តម ជា ច័ន្ទបរិបូរណ៍ រដ្ឋលេខាធិការ ក្រសួងព័ត៌មាន រួមជាមួយ អាជ្ញាធររដ្ឋបាលស្រុកមេមត់ចំនួន ១៥នាក់ រួមមាន៖ ១) ឯកឧត្តម ជា ច័ន្ទបរិបូរណ៍ ២) ជា ច័ន្ទដល្លា ៣) មាស ប៊ុន សាន ៤) អ៊ុំ និមួន ៥) ផល ចន្ទភិរក្ស ៦) ជា សុធន់ ៧) គង់ សុវណ្ណបញ្ញា ៨) ខាន់ វឌ្ឍនា ៩) ធីន ស៊ីថាប ១០) ទូច សុរី ១១) ញឹក នៅ ១២) ទី លីហ្វាន់ ១៣) ប៊ីង ប៊ុនថន ១៤) សុទ្ធ កុសល ១៥) វ៉ែន វ៉ាន បានអញ្ជើញមកទស្សនកិច្ច និងថតភាពយន្តឯកសារក្រោមចំណងជើងថា «កម្ពុជាមុននឹងមានថ្ងៃនេះ» នៅមជ្ឈមណ្ឌលឯកសារកោះថ្មចាប់ពីម៉ោង៨:០០ ដល់ម៉ោង១០:៣០នាទីព្រឹក។

លោក ញឹក នៅ គឺជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាស្រុកមេមត់ និងជាអភិបាលរងនៃគណៈអភិបាលស្រុកមេមត់មានប្រសាសន៍ថា នៅភូមិកោះថ្មឃុំទន្លូងនេះ គឺជាទីតាំងដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន រួមជាមួយយុទ្ធមិត្តប្អូនរូប

ទៀតធ្វើដំណើរទៅកាន់ប្រទេសវៀតណាម ដើម្បីស្នើសុំជំនួយវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត។ មជ្ឈមណ្ឌលឯកសារកោះថ្ម គឺជាកន្លែងមួយសម្រាប់យុវជន និងសិស្សានុសិស្សចូលមកសិស្សាពីប្រវត្តិសាស្ត្រ ជាពិសេសគឺប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

ចំណែក កញ្ញា ទី លីហ៊ាន់ អភិបាលរងនៃគណៈអភិបាលស្រុកមេមត់ មានប្រសាសន៍ថា ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយ នៅពេលដែលបានមកដល់មជ្ឈមណ្ឌលឯកសារកោះថ្ម និងបានជួបប្អូនៗដែលធ្វើការងារនៅទីនេះ។ នៅពេលចូលដល់ខាងក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម នាងខ្ញុំកាន់តែចាប់អារម្មណ៍ទៅលើការតាំងពិព័រណ៍រូបភាព ផ្ទាំងគំនូរ ផ្ទាំងផែនទី ដែលគួរឲ្យអារម្មណ៍ទាក់ទងនឹងប្រវត្តិសាស្ត្រតំបន់កោះថ្ម ជាពិសេសរូបគំនូរដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូបទៀត ធ្វើដំណើរឆ្ពោះទៅកសាងកងកម្លាំងប្រដាប់អាវុធ ដើម្បីវាយផ្តួលរំលំរបបខ្មែរក្រហម។ រូបគំនូរនេះបានឆ្លុះបញ្ចាំងអំពីការលះបង់អាយុជីវិតរបស់មេដឹកនាំ ដើម្បីសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍ប៉ុល ពត។

អ្នកផលិតខ្សែភាពយន្ត និង ពិធីការិនី បានមានប្រសាសន៍ថា ពេលខ្ញុំមកដល់តំបន់នេះ ខ្ញុំមានការចាប់អារម្មណ៍។ តំបន់នេះ គឺជាតំបន់មួយដែលបង្ហាញពីទីតាំងប្រវត្តិសាស្ត្រ ហើយក៏ជាទឹកដីប្រវត្តិ-សាស្ត្រដំបូងដែលនាំមកនូវសន្តិភាព។ ចុងក្រោយខ្ញុំចង់ឲ្យយុវជនទាំងអស់គ្នាត្រូវចងចាំ និងដឹងច្បាស់ថា តើត្រូវធ្វើយ៉ាងណាកុំឲ្យមានសង្គ្រាមកើតឡើងទៀត។ មើលពីគំរូអ្នកដឹកនាំកំពូលរបស់ប្រទេសកម្ពុជា គាត់លះបង់ណាស់ទម្រាំទទួលបានសន្តិភាព បើយុវជនមានការធ្វេសប្រហែស នឹងធ្វើឲ្យមានសង្គ្រាមកើតឡើងម្តងទៀតពិបាកណាស់។



ក្រុមការងារថតខ្សែភាពយន្តឯកសារក្រសួងព័ត៌មាន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មធ្វើបទបង្ហាញទៅកាន់ក្រុមការងារថតខ្សែភាពយន្តឯកសារក្រសួងព័ត៌មាន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មធ្វើបទបង្ហាញទៅកាន់ក្រុមការងារថតខ្សែភាពយន្តឯកសារក្រសួងព័ត៌មាន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## «ទួលពិឃាដ» (ត)

# ៩. ផែនការអង្គការកៀរសម្លាប់ចុងក្រោយ

## ទឹកភ្នែកអ្នកឃុំព្រៃស្រឡិត

### *ជីវិតលើវិថីមរណៈ ទឹកដីបូព៌ា*

ការរស់នៅរបស់ប្រជាជនឃុំព្រៃស្រឡិតក្នុងជំរំគុកភក់ជ្រាំបដិវត្តន៍មានការធ្វើទុក្ខបុកម្នេញហួងហែងចង់អាឃាតមិនស្រាកស្រាន្តពីសំណាក់កម្មាភិបាលមេកង និងកងឈ្លបខ្មែរក្រហមគ្រប់ជាន់ថ្នាក់ ដោយខំប្រឹងធ្វើការដែលអង្គការដាក់ឲ្យ មិនហ៊ានប្រកែក ទោះជាហូបមិនគ្រប់គ្រាន់។ តស៊ូលេបថ្ម លេបក្រួស ព្រោះខ្លាចគេយកទៅសម្លាប់។ មិនហ៊ានមើល ធ្វើមិនដឹង ធ្វើមិនឮនិងមិននិយាយអ្វីទាំងអស់។

ថ្ងៃណាក៏ដូចថ្ងៃណាដែរ ឮតែឈ្មោះប្រជាជននេះ ប្រជាជននោះ នៅភូមិនេះ នៅភូមិនោះ គេហៅយកទៅអប់រំ ទៅធ្វើការ ឬទៅរស់នៅទួលស្វាំង ទាំងគ្រួសារៗ ថែមទៀត។ ម្នាក់ៗដឹងថា គេយកទៅសម្លាប់តែមិនហ៊ានប្រកែកនិងសំងំរស់នៅតាមយថាកម្ម។ រួចមួយថ្ងៃ គឺបានរស់មួយថ្ងៃស្អែកឡើងចាប់ផ្ដើមគិតឡើងវិញនូវជីវិតដូចកូនឈ្លូសដែលរស់ក្នុងហ្វូងឆ្កែចចក រង់ចាំការខាំហែកស៊ីតែប៉ុណ្ណោះ។

ជីវិតចុងក្រោយត្រូវពួកកងឈ្លបខ្មែរក្រហមកៀរប្រជាជនអ្នកភូមិជាច្រើនក្នុងឃុំព្រៃស្រឡិតទាំងអស់ឲ្យមកប្រមូលផ្ដុំគ្នានៅទួលតាទិក ជាផែនការកៀរសម្លាប់ចុងក្រោយ។

យប់ព្រលប់ៗមើលគ្នាមិនស្គាល់ កងឈ្លបខ្មែរក្រហមពីរបីនាក់ដើរកាត់ហ្វូងមនុស្សស្ពាយកាំភ្លើងអាកា និងបេ៤០ ដោយមិនខ្វីមើលមុខប្រជាជនធ្វើមុខមាំ ចាត់ទុកខ្លួនគេជាកម្មាភិបាលជាន់ខ្ពស់។

ម្នាក់ៗមិនហ៊ាននិយាយរកគ្នា។ ស្ងាត់ច្រៀប គ្រាន់តែមើលមុខគ្នាភ្លឹះៗបន្តុប់ដោយអារម្មណ៍ភ័យខ្លាច។ ម្នាក់ៗសញ្ជឹងគិតថា ពួកកងឈ្លបខ្មែរក្រហមនឹងបាញ់រះសម្លាប់ នៅលើទួលនេះហើយ។ ពេលនោះខ្ញុំសម្លឹងឃើញធំតែម តាយាយ និងចាស់ៗនៅភូមិផ្សេងទៀត កំពុងសូត្រធម៌ខ្សឹបៗ។

មិនយូរប៉ុន្មាន សំឡេងគ្រាប់បេ៤០ បាញ់ផ្ទុះដំបូកមួយឮខ្ទរញ័ររន្ធើពេញទួល មានភ្លើងជះប៉ុនពំនូកចំបើងផ្អើលអស់បក្សី ហើរស្រែកយំពេញមេឃ។ ខ្ញុំភ្ញាក់ផ្អាក់អស្រែកពីលើស្មា ភ័យឡើងរាកអាចម៍ រាកនោម។ ក្នុងចិត្តយំលាយឡំ ទឹកភ្នែកមើលទៅទួលស្វាំង លើកដៃសំបួងសង្រ្វួងដល់ព្រលឹងឪពុកម្ដាយ ជួយថែរក្សាកូនៗ តាយាយ ឲ្យរួចផុតពីការសម្លាប់នេះ។ ម្នាក់ៗក្រាបផ្ទាល់ដីស្រែករកតែពុទ្ធោ។ បេះដូងញ័រកន្ត្រាក់ស្ទើរដាច់ដង្ហើមរាកអាចម៍រាកនោមគ្រប់គ្នាដោយអំណាចភ័យខ្លាច។

មួយស្របក់ក្រោយមកឃើញកងឈ្លបទាំងនោះមកប្រាប់យើងថា "អង្គការឲ្យប្រជាជនទាំងអស់សម្រាកនៅលើទួលនេះមួយយប់សិន ហើយមិនត្រូវដើររហេតរហូត ចេញពីទួលនេះឡើយ។" គ្រប់ៗគ្នាដេកមិនលក់ គិតថា ច្បាស់ជាគេរកវិធីសម្លាប់នៅទីនេះហើយ។

## អ្នកភូមិ យោគ លាក់ខ្លួនក្នុងព្រៃរនាមចំឡក់បឹងឫស្សី

បន្ទាប់ពីដឹងថា ពួកខោអាវត្រួយចេកកៀរប្រជាជនឃុំព្រៃស្រឡិតចេញពីភូមិអស់។ អ្នកភូមិយោគមានការភ័យខ្លាចនាំគ្នាបោះបង់ផ្ទះសំបែងជិះទូក ខ្លះទៀតហែលឆ្លងទន្លេតូច រត់ទៅលាក់ខ្លួនកណ្តាលទ្រូងព្រៃរនាមចំឡក់បឹងឫស្សី លាតសន្ធឹងពីភូមិបារាយរហូតដល់ត្រើយម្ខាងទន្លេតូច។

នៅពេលយប់អ្នកភូមិខ្លះផ្សងនឹងគ្រោះថ្នាក់លួចចូលក្នុងភូមិលួចយកស្រូវអង្ករក្នុងសហករណ៍ មកបុកអុំយកអង្ករដាំបាយ។ ក្នុងភូមិស្ងាត់ជ្រងំ មិនឃើញពួកខ្មែរក្រហមទេ គឺមានផ្ទះឥតមនុស្សនៅ។

ប្រជាជនភូមិយោគនៅពួនក្នុងព្រៃរនាម គេចពីពួកខោអាវត្រួយចេករហូតដល់ថ្ងៃរំដោះទើបនាំគ្នាចូលក្នុងភូមិយោគវិញ។

---

## ខ្មាំងកុមារលួចកាច់អំពៅអង្គការ

ស្អែកឡើងថ្ងៃថ្មី ពេលព្រឹកព្រលឹមស្រាងៗ ពួកកងឈ្លបបានកៀរប្រជាជនឲ្យចេញពីទួលតាឡិក ធ្វើដំណើរទៅទន្លេបិទ ខេត្តកំពង់ចាម ដោយឆ្លងកាត់ភូមិទាន្លេជ្រៃ ភូមិកញ្ចំ ភូមិព្រៃទំពូង ភូមិបាទី ភូមិបាទឹង ភូមិបឹងជ័រ ភូមិព្រៃឈាង និងភូមិស្វាយទាប។ល។

ការកៀរចេញពីភូមិក្រាំង លើកចុងក្រោយ គឺការធ្វើដំណើរផ្សងព្រេងមានសភាពលំបាកវេទនាណាស់ ដោយគ្មានគោលដៅច្បាស់លាស់ មិនដឹងថាគេសម្លាប់នៅពេលណា និងកន្លែងណានោះទេ។

ពេលកៀរប្រជាជនមកជិតដល់ភូមិស្វាយទាបឆ្ពោះទៅអូររាំងឪ។ ការធ្វើដំណើរម្នាក់ៗ ហាក់ដូចជាអស់កម្លាំងស្ទើរដើរមិនរួច។ អ្នកភូមិជាច្រើនគេធ្វើដំណើរទៅមុខអស់នៅសល់ប្រហែលជា ៧ ទៅ ៨ នាក់ មានទាំងជីដូនខ្ញុំផង អង្គុយលើគាវរទេះគោ ផ្ញើជាមួយអ្នកភូមិ។

ដាច់ពីអ្នកភូមិប្រហែលបួនប្រាំស្រែ យើងបានឈប់សម្រាក ពេលនោះបងស្រីខ្ញុំ បានលាន់មាត់ថា "នុះ! ដើមអំពៅច្រើនណាស់!" ដោយឥទ្ធិពលនៃការស្រេកទឹកហេវហត់អស់កម្លាំង មានទម្ងន់ពពោះកូនដំបូងផង ក្នុងចិត្តមានអារម្មណ៍ចង់ហូបអំពៅ។ ប្អូនវ៉ា ឃើញដូចនោះ បានដើរពីរនាក់បងស្រីសំដៅទៅចម្ការអំពៅ មើលឆ្វេងស្តាំ ដូចមិនឃើញនរណាសោះ ក៏ចូលទៅកាច់ដើមអំពៅពុសូរផស់ យកទៅឲ្យបងស្រីដែលកំពុងអង្គុយចាំ។

បងស្រីខាំបកអំពៅបម្រុងទំពាពុសំឡេងស្រែកចេញពីស្រែម្ខាងមកថា "ដេញចាប់វាឲ្យបាន អាខ្មាំងលួចកាច់អំពៅ" ប្អូនវ៉ាស្ទុះរត់ចេញពីវាលស្រែគេចពីពួកគេយ៉ាងលឿនត្របាញ់ជើងហុយដីទ្រលោម ដោយមានកងឈ្លបពីរនាក់កាន់ដំបងគល់ឫស្សីដេញតាមពីក្រោយ។ ឃើញដូចនោះ ប្អូនវ៉ា បន្ថែមល្បឿនកាន់តែលឿនឆ្ពោះទៅមុខក្បែរភូមិស្វាយទាប។

បងស្រីងាកមើលឃើញដូចនោះ មានចិត្តតក់ស្លុតយ៉ាងខ្លាំងយកជាយក្រមាជូតទឹកភ្នែក ដើរមករកកន្លែងដើមវិញ បោះអំពៅចោល ងាកលួចមើលកងឈ្លបដេញប្អូនៗ ក្នុងចិត្តអស់សង្ឃឹមថា ប្អូនប្រាកដជាកងឈ្លបចាប់បានវាយសម្លាប់ជាមិនខានហើយ ចោទសួរទៅក្នុងចិត្តគាត់ថា គង់តែគេសម្លាប់ជាមួយគ្នា ហេតុអ្វីបានជាប្អូនត្រូវគេសម្លាប់មុនបង?

មិនយូរប៉ុន្មាន ឃើញកងឈ្លបម្នាក់ទៀតស្ពាយកាំភ្លើងអាកាស្ទើរ

អូសដីជួយដេញតាមពីក្រោយ។ បងស្រីគ្មានអ្វីក្រៅពីបិទភ្នែកបួងសួងឲ្យប្អូនបានរួចផុតពីការតាមសម្លាប់នេះ។ មួយភ្លែតនោះ ពេលបើកភ្នែកស្រាប់តែឃើញកងឈ្លបទាំងនោះបកក្រោយវិញ ហើយប្អូនវ៉ារត់ចូលក្នុងហ្វូងប្រជាជនដែលគេជម្លៀស។

កំពុងតែគិតពីប្អូនស្រាប់តែឮសំឡេងស្រែកមកថា "ដើរទៅ!ៗ កុំឈប់ ដើរឲ្យទាន់គេឯង!" ជាសំឡេងកងឈ្លបប្អូនប្រាំនាក់ មានកាំភ្លើងគ្រប់ដៃ។ ពួកយើងក៏ចេញដំណើរមួយៗ ក្នុងចិត្តអស់សង្ឃឹម គិតថា បើគេសម្លាប់ល្អជាង។

ពេលមកដល់ហ្វូងអ្នកភូមិប្អូនវ៉ារត់មកកាន់ដៃបងស្រីស្រក់ទឹកភ្នែកខ្លួនប្រឡាក់សុទ្ធតែដី និងស្នាមមុតស្លឹកអំពៅ ឈាមប្រឡាក់ពេញខ្លួន។ ខ្លួនញ័រដង្ហក់ ដូចកូនចាបធ្លាក់ទឹក។ បន្ទាប់មកបងស្រីក៏យកក្រមារុំខ្លួនឲ្យប្អូន ហើយឲ្យអង្គុយលាក់ខ្លួនខ្លាចកងឈ្លបតាមរកឃើញ។

ពេលដែលយើងស្រែកឃ្លានពិតជាបាត់បង់អស់នូវការភ័យខ្លាច ហ៊ានបំពាននឹងច្បាប់របស់អង្គការដែលគេអាចចោទយើងថាជាខ្មាំងនិងអាចប្រហារជីវិតយើងគ្មានស្តាយស្រណោះដែលអង្គការនិយាយថា "ស៊ូសម្លាប់ប្រជាជនស្លូតត្រង់មួយរយអ្នកខុស កុំឲ្យតែលែងមនុស្សម្នាក់ខុស"។

សំណល់មរតកគ្រួសារមួយនេះបានជួបរឿងរ៉ាវអាក្រក់ៗរាប់មិនអស់នៅក្រោមដំបូលឆ្អឹងឆត្រធ្លុះធ្លាយនៃបដិវត្តន៍ឈាមក្រហមប្រាលមហាស្រណោះ។ ពិតជាអស្ចារ្យណាស់រកលេខដាក់គ្មានខាងសម្លាប់ សូម្បីទារកក្នុងអង្រឹងក៏ចាប់ជើងបោកឲ្យតែជាប់សែស្រឡាយខ្មាំងប្រឆាំងនឹងអង្គការបដិវត្តន៍។

---

# កំណើតជីវិតទី ២ លើវាលស្រែ

ធ្វើដំណើរមកដល់ភូមិស្វាយទាបមិនទាន់បានប៉ុន្មានផង ពួកវាកៀរឱ្យត្រឡប់ទៅក្រោយវិញ ហើយស្រែកថា ប្រញាប់ឡើងៗ។

ពេលនោះយើងឮសូរស្នូរគ្រាប់កាំភ្លើងតូចធំបាញ់តគ្នាលាន់រំពង។ មានអ្នកជិះសេះម្នាក់ មិនដឹងជាខាងណាមកប្រាប់ថា "កងទ័ពយៀកណាមវាយជាមួយកងទ័ពខ្មែរក្រហម ដូច្នេះត្រូវរត់គេចជាបន្ទាន់។

ពួកយើងប្រញាប់ប្រញាល់រត់គេចគ្រាប់ ក្រោមការបាញ់រះសម្លាប់ចុងក្រោយពីពួកកងឈ្លបអាវខ្មៅខ្មែរក្រហមលើប្រជាជន។ គ្រួសារខ្លះត្រូវស្លាប់ទាំងអស់ ខ្លះទៀតត្រូវរបួសដែលមិនហ៊ានមើលនឹងភ្នែកទេ។ គួរឱ្យអាណិតជាពន់ពេក។ តាមផ្លូវឮតែសំឡេងកាំភ្លើង និងសម្រែកអ្នករបួសស្រែកជួយផងៗ ថ្ងូរពេញវាលស្រែ មើលឃើញអាណោចអាធ័មខ្លាំងណាស់។ គ្មានអ្នកណាជួយអ្នកណាទេ គឺម្នាក់ៗរត់រកតែព្រះអាយុរៀងៗខ្លួន។

ចំណែកគ្រួសារខ្ញុំ ធំតែម កូនៗគាត់ និងគ្រួសារពូអិ ត្រូវបានរត់ចេញពីការបាញ់រះដោយមានគ្នាប្រហែល ១០នាក់ រសាត់អណ្តែតជង្រង់ព្រៃកាត់វាលរហោឋាន សោកអាល័យស្វាត់ជ្រងំដាច់កន្ទុយភ្នែក គ្មានកោះត្រើយ។ ក្នុងក្តីសង្ឃឹមនៅឆ្ងាយហួសពីជើងមេឃ។

ឃើញតែរណ្តៅសាកសពនៅមានក្លិនអសោច និងសត្វស្អែកកាយពាំ



ទិដ្ឋភាព៖ ក្រុមគ្រួសារខ្ញុំ ដែលមានបងណាតបងស្រី និងប្អូនវ៉ា ធំតែម កូនៗគាត់ ចៅ និងពូអិ រត់ចេញពីការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហមនៅភូមិបុស្សស្បីសាញ់ គ្រួសារខ្លះត្រូវរបួស ខ្លះទៀតស្លាប់ដែលពិបាកមើលនឹងភ្នែកណាស់ ម្នាក់ៗរត់យកតែព្រះអាយុរៀងៗខ្លួន។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

បំណែកសាកសពដែលឆ្កែទាំងនោះម្ចាស់វាយកទៅបំបោះបង់ចោលនៅវាលស្រែ ក្រោយពីអង្គការបដិវត្តន៍មិនអនុញ្ញាតឱ្យចិញ្ចឹម ឬយកប្រគល់ជូនអង្គការបដិវត្តន៍។ សត្វឆ្កែទាំងអស់ត្រូវបានសម្លាប់ចោល តែម្ចាស់ដទៃទៀត មានការអាណិតឆ្កែរបស់ខ្លួនត្រូវយកទៅបោះបង់ចោល។អង្គការបដិវត្តន៍ធ្វើរបៀបនេះងាយស្រួលចូលឈ្លបយកការណ៍នៅក្រោមផ្ទះប្រជាជន។

នៅតាមផ្លូវឮតែសត្វក្អែកស្រែកបួលយំទាររព្រលឹងគួរឱ្យព្រឺព្រួចនៃជីវិតកម្មវាសនាងងឹតសូន្យសុងនេះ។ ខោអាវខ្មៅនៅរាយប៉ាយតាមកន្លែងដំបូកៗ ធ្វើដំណើរភ័យខ្លាចជួបពួកកងឈ្លបខ្មែរក្រហម ប្រាកដជាវាសម្លាប់ចោលទាំងអស់។

ធ្វើដំណើរវែងឆ្ងាយ ទូលវែកពុនអស់កម្លាំងនៅសម្រាកក្រោមដើមត្នោត អង្គុយមើលមុខគ្នា ដូចជាអស់សង្ឃឹមថា មិនដឹងធ្វើដំណើរទៅណាទៀត គ្មានអាហារ រកទឹកផឹកគ្មាន។

ព្រះអាទិត្យបញ្ចេញកម្ដៅមើលទៅឃើញថ្ងៃបណ្ដើរកូនព្រាកៗ។ សម្រាកបានមួយស្របក់ ក៏សម្រេចចិត្តធ្វើដំណើរសំដៅទៅភូមិមួយក្បែរនោះ ទាំងអស់កម្លាំងរហិតរហៃដៃជើង និងជង្រងព្រេងជាទីបំផុត។

មកដល់ទួលមួយ បងណាតគាត់ភ្លាត់សំឡេងហើយលើកដៃចង្អុលថា នោះជាភូមិបឹងឡែង ស្រុកកំណើតបងប្អូនគាត់។ កម្លាំងចិត្តមិនដឹងជាមកពីណា។ គាត់ប្រាប់ឱ្យពួកខ្ញុំនៅចាំខាងក្រៅភូមិសិន។ គាត់ដើរចូលទៅក្នុងភូមិទាំងប្រថុយនឹងគ្រោះថ្នាក់។

ឆ្លៀតពេលនោះខ្ញុំ និងប្អូនវ៉ា ដើរចូលស្រែក្បែរនោះ ដើម្បីស្វែងរកទឹកដក់ក្នុងចង្អូរស្រែ មកផឹក ប៉ុន្តែទឹកហួតអស់ពីស្រែ ដើរចុះឡើង ឃើញថ្លុកមួយមានទឹកភក់ៗ។ ក្នុងថ្លុកនោះសុទ្ធតែកំពឹស ខ្ញុំក្បង់វាដាក់បានមួយថ្នក់ក្រមា។

មួយស្របក់ក្រោយមកបងណាតគាត់ចេញពីភូមិមកវិញ មានបងប្អូនគាត់ម្នាក់មកជាមួយ ដើម្បីជួយរែកអីវ៉ាន់ទៅភូមិនោះ។

ទម្រាំតែធ្វើដំណើរបានមកដល់ភូមិបឹងឡែងនេះ ពិបាកខ្លាំងណាស់មិនអាចពណ៌នាបានទេ។ យើងព្រលឹងចុងសក់គ្រប់ៗគ្នា ទាំងនេះប្រហែលមកពីព្រលឹងឪពុកម្ដាយតាមជួយថែរក្សាដល់កូនៗហើយ។



ទិដ្ឋភាព៖ បន្ទាប់ពីរត់ចេញពីគ្រាប់កាំភ្លើងបាញ់គ្នារវាងកងទ័ពវៀតណាម និងខ្មែរក្រហមគ្រួសារខ្ញុំបានរសាត់អណ្ដែតធ្វើដំណើរសំដៅទៅភូមិកំណើតវិញ ឆ្លងកាត់ភូមិទួលនីមួយៗឃើញតែរណ្ដៅសាកសពដែលឆ្កែទាញយកបំណែកសាកសពមកស៊ី ដែលមានក្លិនអសោចពេកក្រៃ និងសត្វក្អែកហើរពីលើយំទាររព្រលឹងគួរឱ្យព្រឺព្រួច។
(ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

អ្វីៗនៅតែមិនយល់ពីកលល្បិចនយោបាយរបស់ពួកគេ គឺប្រឆាំងជាមួយប្រជាជនឯង ដោយឱ្យប្រជាជនធ្វើស្រែចម្ការគ្មានពេលស្រាកស្រាន្ត ពេលបានផលមកមិនដឹងយកទៅណា។ ប្រជាជននៅតែអត់បាយ ហូបមិនគ្រប់គ្រាន់ និងចោទថាជាខ្មាំងប្រឆាំងបដិវត្តន៍ ហើយសម្លាប់រាល់ថ្ងៃ។ ម្ល៉េៗឮតែតាមខឃោសនសព្ទបំពងថា “បដិវត្តន៍កម្ពុជាមហាលោតផ្លោះមហាអស្ចារ្យ” ចង់សួរថា តើភាពអស្ចារ្យនោះនៅកន្លែងណា?

ថ្នាក់ដឹកនាំទាំងនោះពោរពេញទៅដោយសក្ដានុពល នៃចំណេះដឹងដែលបានបញ្ចប់ការសិក្សានៅបស្ចិមប្រទេស តែមានជំនាញខ្លៅខាងបំផ្លាញ គំរាម សម្លាប់ គ្មានការខ្មាសអៀនតែប៉ុណ្ណោះ!។ តើប្រជាជនខ្មែរ បានធ្វើអ្វីខុសចំពោះអ្នក បានជាអ្នកចងគំនុំនឹងឈាមឯងដូច្នេះ? ខ្ញុំនឹងប្រជាជនខ្មែរទាំងមូលស្រក់ទឹកភ្នែកទទូចអង្វរសួរអ្នកថា “ភាពអមនុស្សធម៌ដែលអ្នកបានធ្វើលើប្រជាជនដូចនេះ គឺដើម្បីអ្វី?”។

# ថ្ងៃរះ

## ភូមិបឹងឡែង, ឈាមរត់រកឈាម



ទិដ្ឋភាព៖ ពេលពួកយើងបានជួបតាយាយវិញ។ (ឡុង វង្សសមិទ្ធ/សៀវភៅទូលពិឃាដ)

មកដល់ភូមិបឹងឡែង បងប្អូនបានដាំបាយឲ្យហូប និងកំពីសលីង មហាឆ្ងាញ់អើយឆ្ងាញ់ ព្រោះដាច់បាយពីរទៅបីថ្ងៃហើយ។

បងប្រុសបានរ៉ាយរ៉ាប់ប្រាប់រឿងនេះទៅបងប្អូនគាត់ គេក៏ហួសចិត្តដោយមិនបានដឹងពីការកៀរប្រជាជនចេញពីភូមិ។

បងប្រុសបងស្រី គាត់កំពុងគិតពីតាយាយដែលផ្ញើជាមួយអ្នកភូមិ មិនដឹងរសាត់អណ្តែតដល់ណា ឬត្រូវពួកខ្មែរក្រហមបាញ់សម្លាប់ សួរនាំអ្នកណាក៏មិនដឹង។

ថ្ងៃរៀបអស្តង្គត មានរទេះគោបួនដប់បានចូលមកក្នុងភូមិ ហុយដីទ្រលោម ភ័ព្វសំណាងល្អ ក្នុងនោះមានតាយាយខ្ញុំដែរ។ គ្រាន់តែក្រឡេកឃើញភ្លាមបងប្រុសបងស្រីបានស្ទុះទៅឱបគាត់ទាំងពីរ ទាំងទឹកភ្នែកដោយអាណិតតាយាយប្រឡាក់សុទ្ធតែដីហុយប្រឡាក់ស្រម៉កពេញខ្លួន។ តាយាយមានទឹកភ្នែករលីងរលោង គិតពីចៅៗសុខទុក្ខយ៉ាងណាដែរ ពេលនោះបងស្រី បានគ្រាហ៍តាយាយចេញពីរទេះ និងគាវរួចគាត់លើកដៃសំពះអរគុណអ្នកភូមិដែលបានឲ្យគាត់ជិះរទេះដោយសារ។ យើងបានស្នាក់នៅភូមិនេះបណ្តោះអាសន្នសិន។

យប់ឡើងបងប្រុសស្រីនិងតាយាយបានពិគ្រោះគ្នាថា យើងគួរតែទៅរករទេះនិងគោមកដឹកតាយាយនិងចាស់ៗទៅភូមិកំណើតវិញ ព្រោះពួកគាត់ដើរមិនបានឆ្ងាយទេ ហើយម្យ៉ាងទៀត បងស្រីមានសភាពស្លេកស្លាំងខ្វះអាហារដោយគាត់មានទម្ងន់ពពោះកូនដំបូង។ គិតរួចបងស្រីប្រាប់ខ្ញុំថា "ស្អែកព្រឹកប្អូនធ្វើដំណើរចូលភូមិក្រាំងយើងជាមួយបងប្រុសគ្រាន់បានជាគ្នា ព្រោះគ្មានអ្នកណាធំជាងប្អូនទេ។" ខ្ញុំងក់ក្បាលយល់ព្រមតាមបងស្រី។

ដេកមិនទាន់លក់មួយស្រឡេតផង ស្រាប់តែឮសំឡេងស្រែកពីអ្នកជិះសេះពីបីនាក់មកថា "ប្រជាជនក្នុងភូមិទាំងអស់ ត្រូវចាកចេញពីភូមិឲ្យលឿន ព្រោះពួកខោអាវត្រួយចេកមកដល់ភូមិស្គា ហើយ"។ ពេលនោះអ្នកភូមិទាំងអស់ព្រមទាំងគ្រួសារខ្ញុំផងបានរៀបចំអីវ៉ាន់ទូល សែង រែក ពុន ចាកចេញយ៉ាងលឿន។

ធ្វើដំណើរទាំងយប់គេចចេញពីពួកខោអាវត្រួយចេក ឆ្លងកាត់ភូមិព្រៃស្លា ព្រែកសណ្តែកៗល។ ថ្ងៃក្រហមព្រឿងៗនាទិសបូព៌ យើងមកដល់ភូមិអំបែងបេស។ មិនយូរប៉ុន្មានឮសំឡេងប្រជាជននៅខាងមុខរត់បកថយក្រោយវិញហើយស្រែកថា ពួកយើងបកទៅក្រោយវិញឲ្យលឿន ពួកខ្មែរក្រហមបាក់ទ័ពរត់តាមផ្លូវនេះ។ ប្រជាជនទាំងអស់ បានរត់បកក្រោយវិញទាំងភ័យស្ទន់ស្លោ គោក្របីផ្អើលប្រាលចុះឡើងស្ទើរកាច់បាក់នឹម បន្ទាប់មកប្រជាជនអ្នកភូមិបឹងឡែង ទាំងអស់ដើរត្រឡប់ចូលភូមិវិញទាំងថ្ងៃមិនទាន់រះស្រួលបួលផង ដាច់ដំណេកមួយយប់។

# ដំណើរផ្សងព្រេងចុងក្រោយ

ព្រលឹមព្រឹកនោះ ខ្ញុំពីរនាក់បងប្រុសចេញដំណើរឆ្ពោះទៅភូមិក្រាំងតែម្តងមានតែខោខ្លីអត់អាវចេញពីភូមិកាត់វាលចូលព្រៃជ្រលងអូរប្រឡាយ។

មុនឆ្លងកាត់ព្រៃរនាម បងប្រុសងាកមកក្រោយមើលមុខខ្ញុំក្នុងក្តីអាណិត ហើយនិយាយជាមួយខ្ញុំថា "ប្អូន! បើសិនជាជួបពួកខ្មែរក្រហមតាមផ្លូវ ចូរប្អូនរត់រកតែរួចខ្លួនទៅ កុំគិតពីបងអី ហើយយើងមិនត្រូវរត់ជុំគ្នាទេ"។ បន្ទាប់មកគាត់ក៏ហុចក្រមាមកឲ្យព្រមទាំងអង្អែលក្បាលខ្ញុំហើយពោលថា "ប្អូនយកក្រមានេះទៅ ការពារក្រែងលោជួបកងឈ្លបខ្មែរក្រហម យើងរត់បែកគ្នា ហើយបើប្អូនវង្វេងផ្លូវនៅក្នុងព្រៃរនាមត្រូវចងវាជាអង្រឹងដេកលើដើមឈើ កុំដេកផ្ទាល់ដី ខ្លាចសត្វពស់ចឹក"។" គ្រាន់តែពោលចប់ ខ្ញុំមានអារម្មណ៍ភ័យបុកពោះ ហើយបានដើរចូលទៅក្នុងព្រៃរនាមទាំងអស់គ្នា។

មកដល់មាត់ស្ទឹងគ្រៀងបងឈររេរាមើលនាយអាយ និងរកកន្លែងដែលមានទឹករាក់ងាយស្រួលហែលឆាប់ដល់ត្រើយ ចំណែកខ្ញុំឈរសម្លឹងមើលទឹកស្ទឹងខែប្រាំងថ្លាយង់មើលឃើញដល់បាតដី នឹកហួសនិស្ស័យនឹងនាវាជីវិតខ្ញុំ ដែលមិនអាចកម្រិតឲ្យយើងមើលឃើញអ៊ីឡើយ។ បន្ទាប់មកខ្ញុំក្បង់ទឹកស្ទឹងដឹកប្អូនប្រាំក្អឹក។

ទឹកថ្លាចាំងឆ្លុះមើលឃើញស្រមោលខ្លួនឯងស្ទើរស្រក់ទឹកភ្នែកដែលបានឃ្លាតឆ្ងាយពីបងស្រី ប្អូន"វ៉ាតាយាយ ក្នុងដំណើរផ្សងព្រេងចូលក្នុងភូមិកំណើតជីវិត ជាមួយបងប្រុសប្រកបដោយគ្រោះថ្នាក់ថានឹងបានមកជួបគ្នាវិញឬយ៉ាងណា? រួចបងប្រាប់ឲ្យខ្ញុំហែលទឹកស្ទឹងតាមក្រោយគាត់។ ខ្ញុំយកក្រមាមកជួតនឹងក្បាលហើយហែលតាមពីក្រោយគាត់តាមព្រៃរនាមលិចទឹក។

ពេលឡើងគោក បង និងខ្ញុំបេះឈ្លើងចេញពីជើង និងខ្លួនប្រាណដែលវាទាមបឺតជញ្ជក់យកឈាម។ យើងមិនខ្លាចញញើតនឹងវាទេ ព្រោះវាជារឿងធម្មតាទៅហើយ។

យើងឈរយកដៃបាំងថ្ងៃសម្លឹងរកមើលផ្លូវដែលត្រូវធ្វើដំណើរដោយសុវត្ថិភាព។ ភ្នែកយើងទាំងគូរេរាមើលក្រែងមានពួកខ្មែរក្រហម។

គាត់ដើរខាងមុខ ខ្ញុំនៅពីក្រោយលួចមើលក្រោយម្តងៗ ដោយភ័យព្រលឹងចុងសក់គិតថាខបសគ្គជីវិតមិនទាន់ចប់ទេ។ បាតជើងមុតអស់ហើយនូវបន្លាស្បូវដែលឆេះនៅសល់តែគល់។ តែទោះជាយ៉ាងណាវាដូចជាធម្មតា ព្រោះការគិតពីភាពភ័យខ្លាចបានគ្របដណ្តប់លើការឈឺផ្សានោះរួចទៅហើយ។

មិនយូរប៉ុន្មានយើងបានមើលឃើញទួលស្វាំង និងភូមិក្រាំងកំណើតជីវិតលឹមៗពីចម្ងាយ។



ទិដ្ឋភាព៖ ខ្ញុំ និងបងណាតហែលឆ្លងកាត់ស្ទឹង គ្រៀង ដើម្បីចូលមកភូមិក្រាំងកំណើតជីវិតក្នុងភាពភ័យខ្លាច។
(ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)



ទិដ្ឋភាព៖ ខ្ញុំនឹងបងណាត បេះឈ្លើងទាមចេញពីជើង។
(ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

# ភូមិជីវិតរហោឋាន

ការធ្វើដំណើរមានសភាពស្ងាត់ជ្រងំ មិនមានឃើញមនុស្សណាម្នាក់ទេ ឮតែសត្វបក្សីស្រែកច្រៀងឆ្លងឆ្លើយគ្នាកងរំពងពេញព្រៃ ហាក់ដូចជាសប្បាយណាស់នឹងសេរីភាពពេញលេញរបស់ពួកគេៗ ខុសពីរូបខ្ញុំ ដែលកំពុងរត់ពួនសំងំរែកពុនទម្ងន់ទុក្ខព្រួយ ឲ្យផុតពីព្រានមនុស្សតាមប្រមាញ់សម្លាប់លើដងវិថី នៃពន្ទកជីវិតដំបូងពិតជាជូរចត់ណាស់សម្រាប់កុមារដូចរូបខ្ញុំនេះៗ ដើរបណ្ដើរយកដៃជូតញើសហូរមកដូចឈាមនៅក្រោមកម្ដៅព្រះអាទិត្យបញ្ចេញរស្មីមិនបន្ធង់ៗ

បន្តិចក្រោយមកខ្ញុំពីរនាក់បងប្រុសបានមកកៀកនឹងភូមិ ហើយឈរនៅអែបបាំងខ្លួននឹងដើមត្នោតពីរបីដើមក្នុងចម្ការតាម៉ុកៗ បងគាត់ងាកមើលមុខខ្ញុំស្ទើរស្រក់ទឹកភ្នែកដោយក្ដីអាណិតយកដៃអង្អែលក្បាលខ្ញុំ ហើយនិយាយថា "ប្អូននៅចាំលាក់ខ្លួននៅទីនេះចុះ បងលួចចូលទៅក្នុងភូមិម្នាក់ឯង បើសភាពការណ៍ល្អបងនឹងចេញមកយកប្អូនភ្លាម តែបើមិនឃើញមកទេ សូមប្អូនត្រឡប់ទៅភូមិបឹងឡែងវិញចុះ នោះបងប្រហែលជួបគ្រោះថ្នាក់ហើយ និងប្រាប់តាយាយបងស្រីប្អូនឲ្យដឹងផង សូមប្អូនធ្វើដំណើរដោយប្រុងប្រយ័ត្នណា"ៗ

គាត់មិនបាននិយាយរ៉ាយរ៉ាប់វែងឆ្ងាយទេ រួចដើរលបៗមើលមុខមើលក្រោយ ចំណែកខ្ញុំអង្គុយក្នុងកន្ទុករណ្ដៅជាប់ដើមត្នោត ហើយនឹកគិតថា បើសិនជួបខ្មែរក្រហម តើត្រូវរត់គេចទៅទិសខាងណា? ក្នុងចិត្តគិតវិលវល់អស់ហើយគិតអ្វីក៏មិនចេញដែរៗ

ចាំបាត់ៗរយៈពេលយ៉ាងយូរដោយស្ងាត់រងំនៅមិនឃើញគាត់មក ខ្ញុំគិតថាត្រូវត្រឡប់ថយក្រោយវិញ ប៉ុយ៉ាងណា? ថ្ងៃក៏ជ្រេទាបទៅៗ ក្នុងចិត្តគិតភ័យស្ទើរផុតដង្ហើមម្ដងៗៗ ភ្នែកទាំងគូសម្លឹងទៅរកទួលស្វាំងពិយាដក្រោមក្រសែភ្នែកដិតដាមទៅដោយទឹកភ្នែកឥតគណនា លួចខ្សឹបប្រាប់ក្នុងចិត្តថា កូននឹងមានវាសនាដូចលោកឪពុកអ្នកម្ដាយដែរ យើងនឹងរស់នៅជាមួយគ្នាម្ដងទៀតប្រកបដោយភាពស្ងប់ស្ងាត់ក្នុងពិភពដ៏ផ្សេងៗ

កាន់តែមើលកាន់តែសម្លឹង ក៏នឹករលឹកឃើញឪពុកម្ដាយ និងប្អូន ម៉ាប់ប្អូនសុទ្ធបានបង្ហើរសំឡេងក្នុងចិត្តតាមវាយោថា "កូនពិតជាមានការនឹករលឹកដល់អ្នកទាំងអស់គ្នាណាស់" រួចនិយាយលើកដៃបួងសួងដល់ព្រលឹងអ្នកមានគុណទាំងពីរថា "សូមព្រលឹងលោកឪពុកម្ដាយជួយថែរក្សា និងបង្ហាញផ្លូវកូនដង់ឲ្យរួចផុតគ្រោះភ័យជាពិសេស ឲ្យបងណាតគាត់ត្រឡប់មកវិញឆាប់ៗនេះដោយសុវត្ថិភាព"ៗ

កំពុងតែស្ពុងអារម្មណ៍ស្រាប់តែឮសម្រឹបជើងមនុស្សដើរលើស្លឹកត្នោតសូរប្រឹបៗភ្លាមនោះខ្ញុំបានក្រាបនៅក្នុងរណ្ដៅក្នុងចិត្តភ័យរន្ធត់ឥតឧបមា ពិតជាកម្លាំងកង ឈ្លបខ្មែរក្រហមដើរកាត់ទីនេះៗ សំឡេងដើរលើស្លឹកត្នោតដែលធ្លាក់លើវាលស្រែ គឺកាន់តែជិតទៅៗ ហើយគិតថា គ្រោះជីវិតនឹងមកដល់ហើយ ដៃនៅតែលើកបួងសួងដល់អ្នកមានគុណទាំងពីរ បន្ទាប់មកសំឡេងសម្រឹបជើងមនុស្សដើរក៏បាត់ ខ្ញុំអើតក្បាលចេញពីរណ្ដៅមិនឃើញនរណាសោះ មួយប៉ប្រិចភ្នែកមនុស្សនោះនៅពីក្រោយខ្ញុំ ធ្វើឲ្យខ្ញុំភ្ញាក់ព្រើតលស់ព្រលឹង ហើយបន្លឺសំឡេងថា "គឺបងទេ!" "ហ៊ុ ខំតែភ័យ បងត្រឡប់មកហើយឬ" ខ្ញុំពោលទៅកាន់គាត់ៗ គាត់មានកាន់ចេកទុំមួយ ស្និតកំប្រុកស៊ីអស់ខ្លះ ហុចមកឲ្យខ្ញុំដោយទឹកមុខញញឹមលាយនឹងទឹកភ្នែកៗ

ចិត្តខ្ញុំរំភើបហើយយកចេកមួយញាត់ចូលក្នុងមាត់មហាផ្អែម ហើយគាត់និយាយមកកាន់ខ្ញុំថា "ក្នុងភូមិមិនមានមនុស្សណាម្នាក់ទេ ដូច្នេះយើងចូលទៅសំងំក្នុងផ្ទះសិនចុះៗ" ខ្ញុំពីរនាក់ធ្វើដំណើរចូលទៅក្នុងភូមិ ហើយសំងំនៅក្នុងផ្ទះរបស់អ៊ំតែមៗ

ល្ងាចថ្ងៃរៀបលិចយើងលបចេញពីក្នុងផ្ទះតាមដែនការដែលបានគ្រោងទុកៗ បងគាត់ដើររករទេះគោ ចំណែកខ្ញុំដើរប្រមូលស្រូវក្នុងជង្រុកមកបុកដើម្បីយកអង្ករដាំបាយហូបៗ

ចេញពីផ្ទះមិនបានប៉ុន្មានដំហានផងឃើញស្រមោលមនុស្សនៅអែបនឹងពំនូកចំបើងៗ បងណាត គាត់ប្រាប់ថា "ប្រុងប្រយ័ត្នៗ!" ភ័យញ័រស្ទើរលស់ព្រលឹងធ្លាក់ក្រមាចេញពីដៃៗ យើងទាំងពីរនាក់រកកន្លែងបាំងខ្លួនដើម្បីសុវត្ថិភាព ហើយចាំមើល



ទិដ្ឋភាព៖ ខ្ញុំអង្គុយចាំបងណាតក្នុងរណ្តៅក្បែរចម្ការតាម៉ុក។
(ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

សកម្មភាពគេបន្តទៀតជានរណា? តាមពិតគេក៏គេចចេញពីយើងដែរ។ បងណាត គាត់គិតថា ប្រហែលជាអ្នកភូមិត្រូវជាបងប្អូនគាត់ទៀត រួចគាត់ប្រថុយស្រែកទៅកាន់មនុស្សនោះថា “ពូអិ មែនទេពូ?” ស្រែកពីរបីដងនៅតែមិនបង្ហាញខ្លួន យើងទាំងពីរនាក់មើលមុខគ្នារកកន្លែងពួនដោយប្រុងប្រយ័ត្ន។

មិនយូរមនុស្សនោះក៏ចេញពីពំនូកចំបើងមក ហើយនិយាយថា “យីខំតែភ័យ ស្មានតែកងឈ្លបខ្មែរក្រហម តាមពិតគឺក្មួយវង្ស និងក្មួយណាតសោះ?” គាត់ទាំងពីរនិងខ្ញុំមានទឹកមុខត្រេកអរសប្បាយហៀរទឹកភ្នែកមកមិនដឹងខ្លួន។ ពូអិ គាត់និយាយទៀតថា “ក្មួយមកពីពេលណា?” បងណាតបានរ៉ាយរ៉ាប់ដំណើររឿងប្រាប់ដល់គាត់ ហើយ ពូអិ បន្តថា “អូអ៊ីចឹងល្អហើយ យើងដើររករទេះនិងគោមកទឹម ចំណែកក្មួយវង្សតូចនៅលាក់ខ្លួននៅទីនេះចុះ ហើយប្រុងប្រយ័ត្នផង”។

ខ្ញុំមានអារម្មណ៍សប្បាយដោយមានសុវត្ថិភាព និងមានគ្នីគ្នានៅជាមួយ។ ពេលនោះបាតជើងខ្ញុំចាប់ផ្តើមឈឺកន្លែងបន្លាស្បូវមុតសុសពេញបាតជើង រួចចាប់ផ្តើមដកវាចេញបានខ្លះមិនបានខ្លះ ហើយដើរប្រមូលស្រូវតាមជង្រុកបានមួយថ្នក់ក្រមា មកបុកបក់អង្កាមចេញយកអង្ករដើម្បីដាំបាយ។ បានអង្ករហើយ មិនដឹងបានភ្លើងឯណាដាំបាយ។ មួយសន្ទុះខ្ញុំដើររកវានៅកន្លែងកន្លៀតជញ្ជាំង ចង្ក្រានបាយឃើញដែលបុកមួយវាយយកភ្លើង និងសម្លីគ ពេលនោះទម្រាំបានភ្លើងជិតមួយល្ងាច។

ក្នុងភូមិស្ងាត់ជ្រងំ ដូចជាភូមិពិឃាដវន្តាលរហោឋាន ដែលគេតែងតែនិយាយថា “មានផ្ទះអត់មនុស្សនៅ មានផ្លូវអត់មនុស្សដើរ” សូម្បីសត្វមាន់ទារត់គេចចេញពីមនុស្ស ខ្លាចគេចាប់ធ្វើអាហារប្រៀបបានយើងរត់ចេញពីពួកខ្មែរក្រហមដូច្នេះដែរ។

យប់ងងឹតព្រាលៗឃើញបងនិងពូបររទេះក្របីមួយនឹមរួចហុចពងទាបីបួនគ្រាប់ឲ្យខ្ញុំ ហើយបានចោមរោមហូបបាយជុំគ្នា។ យើងស្នាក់នៅទីនេះមួយយប់ព្រឹកឡើងចេញដំណើរជាមួយរទេះក្របីចំណាស់សំដៅទៅភូមិបឹងឡែងវិញដើម្បីយកដីដូនជីតាបងប្អូនដែលចាំនៅទីនោះ។

ចេញពីភូមិបានបន្តិច បានឃើញអ្នកភូមិចូលមកបណ្តើរៗ ហើយស្រែកសួរគ្នាថា “ម៉េចហើយតាមផ្លូវសុខសប្បាយទេ?” រួចញញឹមញញែមដាក់គ្នាយ៉ាងស្រស់ស្រាយ។

(តនៅលេខក្រោយ)

**ឡុង វង្សសមិទ្ធ**

រូបក្របមុខ៖

សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ត្រូវបានក្រុមប្រឹក្សារាជសម្បត្តិបោះឆ្នោតជាផ្លូវការជ្រើសរើសជា
ព្រះមហាក្សត្រនៃប្រទេសកម្ពុជា នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៤១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ មុនិនាថ សីហនុ ព្រះរាជដំណាក់នៅប្រទេសចិន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 274, October 2022 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.